ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៦ លេខ០៧ ត្រីមាសទី០១ ឆ្នាំ២០២៦

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ២០-១-២០២៦ | -ព្រះរាជក្រម នស/រកម/០១២៦/០០១ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា | ៧៣៩ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៣-១-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០១២៦/០៧១ ស្តីពី ការតែងតាំងសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា | ៧៨៩ |
| ១៣-១-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០១២៦/០៧២ ស្តីពី ការតែងតាំងសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា | ៧៩១ |
| ១៣-១-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០១២៦/០៧៣ ស្តីពី ការតែងតាំងក្រុមអ្នកច្បាប់ប្រចាំក្រសួងការពារជាតិ ជាទីប្រឹក្សា ក្រសួងការពារជាតិ ដោយពុំទទួលប្រាក់បំណាច់មុខងារ ៣រូប | ៧៩៣ |
| ១៣-១-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០១២៦/០៧៤ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តមឧត្តមសេនីយ៍ទោ **ងួន ច័ន្ទ** ជាអនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | ៧៩៤ |


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ៥-១-២០២៦ | -អនុក្រឹត្យលេខ ០១ អនក្រ.បក ស្តីពី ការធ្វើអនុប្បយោគ និងប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ | ៧៩៥ |
| ៥-១-២០២៦ | -អនុក្រឹត្យលេខ ២៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ *(តទៅរាជកិច្ចលេខ ០៨)* | ៧៩៧ |


## III~ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ១២-១-២០២៦ | -សារាចរលេខ ០០១ សហវ.សរ.អថ ស្តីពី ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧ | ៨៧១ |

# ព្រះរាជក្រម

នស/រកម/០១២៦/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៤ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា



## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-** គោលបំណង

ច្បាប់នេះកំណត់អំពីការគ្រប់គ្រងវិស័យអាកាសចរណ៍ស៊ីវិលក្នុងគោលបំណងដើម្បីធានាសុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់នៃប្រតិបត្តិការអាកាសចរណ៍ស៊ីវិល ជំរុញការអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវអាកាសប្រកបដោយចីរភាព កាលានុវត្តភាពវិនិយោគ ការប្រកួតប្រជែង និងរួមចំណែកការពារបរិស្ថាន ព្រមទាំងលើកកម្ពស់ផលប្រយោជន៍សមស្របរបស់អ្នកប្រើប្រាស់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-** វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលគ្រប់រូប ប្រតិបត្តិករ បុគ្គលិក អាកាសយាន អាកាសយានដ្ឋាន ផលិតផលអាកាសចរណ៍ ការនាំផ្លូវអាកាស សេវាកម្មអាកាសចរណ៍ សេវាកម្មគាំទ្រ សេវាកម្មពាក់ព័ន្ធវិស័យអាកាសចរណ៍ ការដឹកជញ្ជូនតាមផ្លូវអាកាស ការងារពីលើអាកាស អង្គភាពថែទាំ ការបណ្ដុះបណ្ដាលនិងអង្គភាពបណ្ដុះបណ្ដាល និងសកម្មភាពនិង/ឬប្រតិបត្តិការផ្សេងទៀតក្នុងវិស័យអាកាសចរណ៍ស៊ីវិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចំពោះបុគ្គលកាន់ឯកសារអាកាសចរណ៍កម្ពុជាដែលកំពុងអនុវត្តបុព្វសិទ្ធិឬមានបំណងអនុវត្តបុព្វសិទ្ធិទាំងក្នុងនិងក្រៅដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់នេះមិនអនុវត្តចំពោះអាកាសយានរដ្ឋ លើកលែងតែក្នុងករណីដែលអាកាសយានរដ្ឋនោះធ្វើប្រតិបត្តិការហោះហើរជាលក្ខណៈស៊ីវិល ស្របតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលនិងក្រោមការត្រួតពិនិត្យតាមដានរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដូចមានចែងក្នុងច្បាប់នេះ។

ព្រះរាជាណាចក្រកម្ពុជាមានអធិបតេយ្យភាពនិងយុត្តាធិការពេញលេញនិងផ្ដាច់មុខចំពោះដែនអាកាសនៅលើដែនដីរបស់ខ្លួន។

**មាត្រា៣ .-** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៤ .-** រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានសមត្ថកិច្ចគ្រប់គ្រងវិស័យអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចប្រគល់ភារកិច្ចឬធ្វើប្រតិភូកម្មមុខងារទាក់ទងនឹងការងារបច្ចេកទេសដល់អគ្គនាយកនិងប្រធានអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល តាមការចាំបាច់។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានសិទ្ធិដូចខាងក្រោម៖

[illegible]មួយអាជ្ញាធរស៊ើបអង្កេតសុវត្ថិភាពអាកាសយានកម្ពុជាដែលទទួលបន្ទុកស៊ើបអង្កេត [illegible]ឧប្បត្តិហេតុអាកាសយានស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការស៊ើបអង្កេតអាកាសយានកម្ពុជា។

២- សហការជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងប្រតិបត្តិការអាកាសចរណ៍ស៊ីវិល តាមការចាំបាច់។

៣- អាចចេញបទប្បញ្ញត្តិនិងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងបញ្ហាណាមួយកើតឡើងនៅក្រោមច្បាប់នេះ ក្នុងដែនយុត្តាធិការរបស់ខ្លួន និងត្រៀមចូលរួមសហប្រតិបត្តិការលើសេវាកម្មកំណត់ត្រា និងបបនីយកណ្ឌនៃក្រសួង ស្ថាប័នទាំងនោះ ដើម្បីដំណើរការនិងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះឱ្យមានប្រសិទ្ធភាព តាមការចាំបាច់។

៤- រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចៈ
- ផ្ទេរទៅអាជ្ញាធរអាកាសចរណ៍ស៊ីវិលបរទេសនៃប្រតិបត្តិករបរទេសនូវការទទួលខុសត្រូវផ្នែកណាមួយឬទាំងស្រុង ចំពោះអាកាសយានដែលបានចុះបញ្ជីនៅកម្ពុជាដូចមានកំណត់ក្នុងកិច្ចព្រមព្រៀងស្តីពីមាត្រា៨៣ស្ទួន ដែលធ្វើប្រតិបត្តិការដោយប្រតិបត្តិករបរទេសនោះ
- ទទួលយកនូវការទទួលខុសត្រូវផ្នែកណាមួយឬទាំងស្រុង ចំពោះអាកាសយានដែលបានចុះបញ្ជីនៅបរទេស ដែលស្ថិតក្រោមកិច្ចព្រមព្រៀងស្តីពីមាត្រា៨៣ស្ទួន ដែលធ្វើប្រតិបត្តិការដោយប្រតិបត្តិករកម្ពុជា ដែលមានចែងនៅក្នុងច្បាប់នេះ
- ទទួលស្គាល់សុពលភាពនៃកិច្ចព្រមព្រៀងស្តីពីមាត្រា៨៣ស្ទួន ដែលធ្វើឡើងរវាងរដ្ឋដទៃទៀត
- ផ្ទេរសិទ្ធិអំណាចនិងតួនាទីភារកិច្ចផ្នែកណាមួយឬទាំងស្រុង របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដែលពាក់ព័ន្ធនឹងសេវាកម្មនាំផ្លូវអាកាសទៅឱ្យអាជ្ញាធរអាកាសចរណ៍បរទេសណាមួយ
- ផ្ទេរសិទ្ធិអំណាចនិងតួនាទីភារកិច្ចផ្នែកណាមួយឬទាំងស្រុង របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដែលពាក់ព័ន្ធនឹងការរុករកនិងសង្គ្រោះ ទៅឱ្យអាជ្ញាធរអាកាសចរណ៍បរទេសណាមួយ។

## ជំពូកទី៣
## គោលការណ៍

**មាត្រា៥ .-** គោលការណ៍

គោលការណ៍នៃការគ្រប់គ្រងអាកាសចរណ៍ស៊ីវិល មានដូចខាងក្រោមៈ
- អនុលោមតាមច្បាប់ជាតិនិងអន្តរជាតិទាក់ទងនឹងសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងបរិស្ថានក្នុងវិស័យអាកាសចរណ៍ស៊ីវិល
- ធានាការប្រកួតប្រជែងដោយយុត្តិធម៌ សមធម៌ តម្លាភាព ទំនុកចិត្ត ភាពធន់ បរិយាបន្ន និងមានលក្ខណៈសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌច្បាប់ជាតិនិងអន្តរជាតិ
- ធានាឱ្យមានតុល្យភាព សុខដុមនីយកម្ម និងអនុលោមភាពរវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់និងអ្នកផ្តល់សេវា ព្រមទាំងរវាងផលប្រយោជន៍ឯកជននិងសាធារណៈ។

## ជំពូកទី៤
## បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល

**មាត្រា៦ .-** បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវរៀបចំបង្កើតបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលឱ្យស្របតាមបច្ចេកវិទ្យាថ្មីៗនិងការតម្រូវបច្ចេកទេសផ្សេងទៀតឆ្លើយតបនឹងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដើម្បីបម្រើឱ្យកិច្ចប្រតិបត្តិការអាកាសចរណ៍ស៊ីវិល។

បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល មានជាអាទិ៍៖

- បទប្បញ្ញត្តិបច្ចេកទេសអាជ្ញាបណ្ណបុគ្គលិក
- បទប្បញ្ញត្តិបច្ចេកទេសបទបញ្ជាដែនអាកាស
- បទប្បញ្ញត្តិបច្ចេកទេសសេវាកម្មឧតុនិយមសម្រាប់ការនាំផ្លូវអាកាស
- បទប្បញ្ញត្តិបច្ចេកទេសគំនូសផែនទីអាកាសចរណ៍
- បទប្បញ្ញត្តិបច្ចេកទេសឯកតារង្វាស់រង្វាល់ដែលត្រូវប្រើប្រាស់នៅក្នុងប្រតិបត្តិការលើផ្ទៃអាកាសនិងផ្ទៃដី
- បទប្បញ្ញត្តិបច្ចេកទេសប្រតិបត្តិការអាកាសយាន
- បទប្បញ្ញត្តិបច្ចេកទេសឌីហ្សាញបទដ្ឋានហោះហើរ
- បទប្បញ្ញត្តិបច្ចេកទេសសញ្ជាតិអាកាសយាននិងសញ្ញាសម្គាល់អាកាសយាន
- បទប្បញ្ញត្តិបច្ចេកទេសលទ្ធភាពហោះហើរអាកាសយាន
- បទប្បញ្ញត្តិបច្ចេកទេសការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស
- បទប្បញ្ញត្តិបច្ចេកទេសទូរគមនាគមន៍អាកាសចរណ៍
- បទប្បញ្ញត្តិបច្ចេកទេសសេវាកម្មចរាចរណ៍ផ្លូវអាកាស
- បទប្បញ្ញត្តិបច្ចេកទេសការរុករកនិងសង្គ្រោះ
- បទប្បញ្ញត្តិបច្ចេកទេសអាកាសយានដ្ឋាន
- បទប្បញ្ញត្តិបច្ចេកទេសសេវាកម្មផ្តល់ព័ត៌មានអាកាសចរណ៍
- បទប្បញ្ញត្តិបច្ចេកទេសការការពារបរិស្ថាន
- បទប្បញ្ញត្តិបច្ចេកទេសសន្តិសុខអាកាសចរណ៍ស៊ីវិល
- បទប្បញ្ញត្តិបច្ចេកទេសការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាសដោយសុវត្ថិភាព
- បទប្បញ្ញត្តិបច្ចេកទេសការគ្រប់គ្រងសុវត្ថិភាពអាកាសចរណ៍ស៊ីវិល
- បទប្បញ្ញត្តិបច្ចេកទេសសេដ្ឋកិច្ចអាកាសចរណ៍ស៊ីវិល
- បទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតដែលពាក់ព័ន្ធនឹងអាកាសចរណ៍ស៊ីវិល។

បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលនីមួយៗត្រូវដាក់ឱ្យប្រើដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។ បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលដែលអាចមានផលប៉ះពាល់ជាសារវន្តដល់ការអនុវត្តច្បាប់ជាធរមាននិងក្រៅក្របខ័ណ្ឌកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៥
## កម្មវិធីនិងផែនការសុវត្ថិភាពនិងសន្តិសុខអាកាសចរណ៍ស៊ីវិល

**មាត្រា [illegible] -** កម្មវិធីនិងផែនការសុវត្ថិភាពនិងសន្តិសុខអាកាសចរណ៍ស៊ីវិល

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវរៀបចំនិងបង្កើតកម្មវិធីនិងផែនការនានាពាក់ព័ន្ធនឹងសុវត្ថិភាពនិងសន្តិសុខអាកាសចរណ៍ស៊ីវិល ជាអាទិ៍កម្មវិធីសុវត្ថិភាពអាកាសចរណ៍ស៊ីវិល ផែនការជាតិសុវត្ថិភាពអាកាសចរណ៍ស៊ីវិល កម្មវិធីសម្របសម្រួលការដឹកជញ្ជូនតាមផ្លូវអាកាស និងកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល។

## ជំពូកទី៦
## ការលើកលែង

**មាត្រា៨ ._** ការលើកលែង

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដោយអនុលោមតាមអនុសញ្ញាអន្តរជាតិឬយោងលើភាពបដិការអន្តរជាតិ អាចស្នើសុំលើកលែងឬបន្ធូរបន្ថយខ្លះចំពោះលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ក្នុងគោលបំណងមនុស្សធម៌ សង្គ្រោះបន្ទាន់ ភាពមានអាសន្ន ឬការបម្រើផលប្រយោជន៍សាធារណៈ បន្ទាប់ពីទទួលបានការឯកភាពពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៧
## អាកាសយាន

**មាត្រា៩ ._** ប្រតិបត្តិការហោះហើរ

គ្មានអាកាសយានស៊ីវិលណាមួយត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការហោះហើរចេញ ចូល នៅក្នុង ឬឆ្លងកាត់ដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជាឡើយ លើកលែងតែប្រតិបត្តិការនោះអនុវត្តស្របតាមច្បាប់នេះ។

**មាត្រា១០ ._** ការចុះបញ្ជីអាកាសយាននិងសញ្ញាសម្គាល់សញ្ជាតិ

ប្រតិបត្តិការហោះហើរអាកាសយានស៊ីវិលនៅក្នុង ឬឆ្លងកាត់ដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើទៅបាន លុះត្រាតែអាកាសយាននោះបានចុះបញ្ជីស្របតាមច្បាប់នេះ។

មុននឹងអនុញ្ញាតឱ្យអាកាសយានណាមួយធ្វើប្រតិបត្តិការហោះហើរនៅក្នុង ឬឆ្លងកាត់ដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា អាកាសយាននោះត្រូវមានការចុះបញ្ជីត្រឹមត្រូវនិងនៅមានសុពលភាព និងត្រូវពាក់សញ្ញាសម្គាល់សញ្ជាតិនិងសញ្ញាចុះបញ្ជីរបស់អាកាសយាននោះ។

**មាត្រា១១ ._** សញ្ជាតិអាកាសយាន

អាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបានសញ្ជាតិកម្ពុជា ហើយក្នុងកំឡុងពេលដែលការចុះបញ្ជីនៅមានសុពលភាព អាកាសយាននោះមិនអាចចុះបញ្ជីនៅរដ្ឋផ្សេងទៀតបានឡើយ។

អាកាសយានដែលបានចុះបញ្ជីនៅរដ្ឋផ្សេងមិនមានសិទ្ធិចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាបានទេ ប្រសិនបើការចុះបញ្ជីនៅរដ្ឋផ្សេងនោះនៅមានសុពលភាពនៅឡើយ។

**មាត្រា១២ ._** នីតិវិធីនៃការចុះបញ្ជី

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវរក្សាទុកកំណត់ត្រាទាំងអស់ដែលទាក់ទងនឹងការចុះបញ្ជីអាកាសយានទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅពេលមានសំណើសុំចុះបញ្ជីពីម្ចាស់អាកាសយានដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់និងបានគោរពតាមបទប្បញ្ញត្តិទាំងអស់នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវចុះបញ្ជីអាកាសយាននោះ និងផ្តល់វិញ្ញាបនបត្រចុះបញ្ជីអាកាសយានជូនម្ចាស់អាកាសយាន។

បញ្ជីអាកាសយានត្រូវធ្វើជាសាធារណៈ ហើយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវ៖

- ផ្តល់លិខិតចម្លងវិញ្ញាបនបត្រចុះបញ្ជីដែលមានការបញ្ជាក់ភាពត្រឹមត្រូវ ជូនបុគ្គលណាម្នាក់តាមសំណើ បន្ទាប់ពីបានបង់កម្រៃសេវារួចហើយ

- ផ្តល់ព័ត៌មានស្តីពីអាកាសយានដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ឬទៅរដ្ឋភាគីកិច្ចសន្យាណាមួយនៃអនុសញ្ញាស៊ីកាហ្គោ តាមការស្នើសុំ។

វិញ្ញាបនបត្រចុះបញ្ជីត្រូវអស់សុពលភាព ទៅតាមព្រឹត្តិការណ៍ណាមួយដែលបានកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ឬផ្ទេរវិញ្ញាបនបត្រចុះបញ្ជីអាកាសយាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលស្តីពីសញ្ជាតិអាកាសយាននិងសញ្ញាសម្គាល់ចុះបញ្ជីអាកាសយាន។

**មាត្រា១៣ .–** ការកត់ត្រាសិទ្ធិនិងផលប្រយោជន៍អាកាសយាន

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវបង្កើតនិងថែរក្សាប្រព័ន្ធកត់ត្រាថ្នាក់ជាតិសម្រាប់ឯកសារទាំងឡាយដែលមានអានុភាពលើកម្មសិទ្ធិ សិទ្ធិ ឬផលប្រយោជន៍ចំពោះអាកាសយានស៊ីវិល រួមទាំងម៉ាស៊ីនអាកាសយាន កង្ហារ គ្រឿងបរិក្ខារ ឬគ្រឿងបន្លាស់អាកាសយានដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គ្មានឯកសារណាមួយដែលមានអានុភាពលើកម្មសិទ្ធិ សិទ្ធិ ឬផលប្រយោជន៍ចំពោះអាកាសយានណាដែលបានចុះបញ្ជីអាកាសយាន រួមទាំងការកត់ត្រាម៉ាស៊ីនអាកាសយាន កង្ហារ គ្រឿងបរិក្ខារ ឬគ្រឿងបន្លាស់អាកាសយាន មានសុពលភាពឡើយ លុះត្រាតែឯកសារនោះត្រូវបានកត់ត្រាចូលក្នុងប្រព័ន្ធកត់ត្រាថ្នាក់ជាតិ។

សុពលភាពនៃឯកសារណាមួយដែលបានកត់ត្រាទុក ត្រូវកំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែត្រូវបានកំណត់ដោយគូភាគី។

លក្ខខណ្ឌតម្រូវសម្រាប់កត់ត្រាឯកសារ ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលស្តីពីសញ្ជាតិអាកាសយាននិងសញ្ញាសម្គាល់ការចុះបញ្ជីអាកាសយាន។

**មាត្រា១៤ .–** វិញ្ញាបនបត្រលទ្ធភាពហោះហើរ

វិញ្ញាបនបត្រលទ្ធភាពហោះហើរមានសុពលភាពសម្រាប់ប្រតិបត្តិការអាកាសយាននៅក្នុងដែនអាកាស និងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជាដែលចេញដោយរដ្ឋភាគីកិច្ចសន្យាដទៃទៀត ត្រូវបានទទួលស្គាល់សុពលភាពដោយព្រះរាជាណាចក្រកម្ពុជាផងដែរ ក្នុងករណីអាកាសយាននោះបានចុះបញ្ជីត្រឹមត្រូវ។

វិញ្ញាបនបត្រលទ្ធភាពហោះហើរ ដែលផ្តល់ឬទទួលស្គាល់សុពលភាពដោយរដ្ឋភាគីកិច្ចសន្យាដទៃទៀត ត្រូវបានទទួលស្គាល់សុពលភាពដោយព្រះរាជាណាចក្រកម្ពុជា ប្រសិនបើលក្ខខណ្ឌតម្រូវនៃការផ្តល់ឬទទួលស្គាល់សុពលភាពវិញ្ញាបនបត្រដោយរដ្ឋនោះមានកម្រិតស្មើឬលើសស្តង់ដាលទ្ធភាពហោះហើរអប្បបរមាដែលបង្កើតឡើងជាបន្តបន្ទាប់ក្រោមអនុសញ្ញាស៊ីកាហ្គោ។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលមានសិទ្ធិផ្តល់ ព្យួរ កែប្រែ ឬដកហូតវិញ្ញាបនបត្រលទ្ធភាពហោះហើរចំពោះអាកាសយានដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា និងត្រូវអនុវត្តតាមស្តង់ដា និងនីតិវិធីដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

នៅពេលទទួលបានវិញ្ញាបនបត្រចុះបញ្ជី ម្ចាស់អាកាសយានត្រូវដាក់ពាក្យស្នើសុំមករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីធ្វើការត្រួតពិនិត្យអាកាសយាន។

វិញ្ញាបនបត្រលទ្ធភាពហោះហើរត្រូវបានផ្តល់តែក្នុងករណីអាកាសយាននោះបានឆ្លងកាត់ការត្រួតពិនិត្យនិងគោលការណ៍ស្តង់ដារដែលកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

ទោះបីមានបទប្បញ្ញត្តិចែងក្នុងមាត្រា១៤នេះក៏ដោយ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចចេញលិខិតអនុញ្ញាតបណ្តោះអាសន្នសម្រាប់ការហោះហើរពិសេសចំពោះអាកាសយានជាក់លាក់ណាមួយស្របតាមលក្ខខណ្ឌដែលត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

វិញ្ញាបនបត្រលទ្ធភាពហោះហើរត្រូវអស់សុពលភាពទៅតាមព្រឹត្តិការណ៍ណាមួយដែលបានកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

លក្ខខណ្ឌ បែបបទ និងនីតិវិធីទាក់ទងនឹងវិញ្ញាបនបត្រលទ្ធភាពហោះហើរត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

**មាត្រា១៥ .-** កិច្ចព្រមព្រៀងស្ដីពីមាត្រា៨៣ស្ទួន

បទប្បញ្ញត្តិនៃច្បាប់នេះឬលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ត្រូវអនុវត្តចំពោះអាកាសយានដែលចុះបញ្ជីនៅរដ្ឋភាគីកិច្ចសន្យាដទៃ ដូចអាកាសយានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាដែរ ក្នុងករណី៖

- ព្រះរាជាណាចក្រកម្ពុជាគឺជាភាគីនៃកិច្ចព្រមព្រៀងស្ដីពីមាត្រា៨៣ស្ទួននៅជាធរមាន ដែលក្នុងកិច្ចព្រមព្រៀងនោះមានចែងអំពីការផ្ទេរមុខងាររបស់រដ្ឋភាគីកិច្ចសន្យា ដែលជារដ្ឋចុះបញ្ជីអាកាសយានមកព្រះរាជាណាចក្រកម្ពុជា
- កិច្ចព្រមព្រៀងចែងថា បទប្បញ្ញត្តិពាក់ព័ន្ធនឹងមុខងារបានផ្ទេរមកព្រះរាជាណាចក្រកម្ពុជា។

បទប្បញ្ញត្តិនៃច្បាប់នេះឬលិខិតបទដ្ឋានគតិយុត្តទាំងឡាយ មិនត្រូវអនុវត្តចំពោះអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាទេ ក្នុងករណី៖

- ព្រះរាជាណាចក្រកម្ពុជាគឺជាភាគីនៃកិច្ចព្រមព្រៀងស្ដីពីមាត្រា៨៣ស្ទួននៅជាធរមាន ដែលក្នុងកិច្ចព្រមព្រៀងនោះមានចែងអំពីការផ្ទេរមុខងាររបស់ព្រះរាជាណាចក្រកម្ពុជាដែលជារដ្ឋចុះបញ្ជីអាកាសយានទៅរដ្ឋភាគីកិច្ចសន្យាដទៃទៀត
- កិច្ចព្រមព្រៀងចែងថា បទប្បញ្ញត្តិពាក់ព័ន្ធនឹងមុខងារបានផ្ទេរទៅរដ្ឋភាគីកិច្ចសន្យាដទៃទៀត។

សេចក្ដីយោងបញ្ជាក់តាមច្បាប់នេះដែលសំដៅចំពោះឬទាក់ទងនឹងរដ្ឋភាគីកិច្ចសន្យាដែលអាកាសយានបានចុះបញ្ជី រួមបញ្ចូលទាំងសេចក្ដីយោងបញ្ជាក់នៃច្បាប់ពាក់ព័ន្ធនឹងកិច្ចសន្យាដទៃទៀតនូវមុខងារនៃរដ្ឋចុះបញ្ជីដែលបានផ្ទេរស្របតាមមាត្រា៨៣ស្ទួននៃអនុសញ្ញាស៊ីកាហ្គោ មានប្រសិទ្ធភាពអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីព្រះរាជាណាចក្រកម្ពុជាចុះកិច្ចព្រមព្រៀងស្ដីពីមាត្រា៨៣ស្ទួន ឬធ្វើការកែប្រែកិច្ចព្រមព្រៀងដែលមានស្រាប់ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវផ្សព្វផ្សាយឱ្យបានឆាប់រហ័សនៅលើគេហទំព័ររបស់ខ្លួននូវចំណុចសម្គាល់និងខ្លឹមសារសំខាន់ៗដែលមានចែងដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

ប្រសិនបើកិច្ចព្រមព្រៀងស្ដីពីមាត្រា៨៣ស្ទួនអស់សុពលភាព រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវផ្សព្វផ្សាយឱ្យបានឆាប់រហ័សនៅលើគេហទំព័ររបស់ខ្លួននូវចំណុចសម្គាល់និងខ្លឹមសារសំខាន់ៗនៃការអស់សុពលភាពនៃកិច្ចព្រមព្រៀងនោះ។

ក្រោមកិច្ចព្រមព្រៀងស្ដីពីមាត្រា៨៣ស្ទួន មុខងារនិងភារកិច្ចអាចត្រូវបានផ្ទេរពីរដ្ឋចុះបញ្ជីទៅរដ្ឋប្រតិបត្តិករដូចខាងក្រោម៖

- បទបញ្ជាដែនអាកាស : ធានាថាអាកាសយានអនុលោមតាមវិធាននិងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលដែលមានសុពលភាពទាំងឡាយ ដែលទាក់ទងនឹងការហោះហើរនិងចលនាអាកាសយានជាធរមាន ទោះបីជាអាកាសយាននោះស្ថិតនៅទីកន្លែងណាក៏ដោយ និងធានាថាមេបញ្ជាការអាកាសយាននឹងទទួលខុសត្រូវចំពោះប្រតិបត្តិការអាកាសយាន ស្របតាមបទបញ្ជាដែនអាកាសនិងការដាក់ទោសទណ្ឌដល់បុគ្គលទាំងឡាយណាដែលរំលោភបំពានវិធាននិងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលទាំងនេះ
- សេវាវិទ្យុអាកាសចរណ៍ ការផ្ដល់អាជ្ញាបណ្ណដើម្បីដំឡើងនិងប្រើប្រាស់វិទ្យុអាកាសចរណ៍

- អាជ្ញាបណ្ណបុគ្គលិក : ការផ្តល់អាជ្ញាបណ្ណឬការទទួលស្គាល់សុពលភាពអាជ្ញាបណ្ណ និងវិញ្ញាបនបត្របញ្ជាក់សមត្ថភាពចំពោះអាកាសយានិកនិងសមាជិកក្រុមអាកាសយានិកដទៃទៀត រួមទាំងអ្នកប្រើប្រាស់វិទ្យុអាកាសចរណ៍របស់អាកាសយានដែលធ្វើការហោះហើរជាលក្ខណៈអន្តរជាតិ
- វិញ្ញាបនបត្រលទ្ធភាពហោះហើរនិងលទ្ធភាពហោះហើររបស់អាកាសយាន : ការផ្តល់ឬការទទួលស្គាល់សុពលភាពវិញ្ញាបនបត្រលទ្ធភាពហោះហើរ ព្រមទាំងការពិនិត្យតាមដានជាប្រចាំលើលទ្ធភាពហោះហើររបស់អាកាសយាន ដំណើរការនិងការកម្រិតកំណត់អាកាសយាន ឧបករណ៍អាកាសយាន សៀវភៅណែនាំអំពីគ្រឿងបរិក្ខារនិងការហោះហើរ ការថែទាំបច្ចេកទេសអាកាសយាន និងវិញ្ញាបនបត្រសំឡេង។

**មាត្រា១៦ .-** ឧបករណ៍វិទ្យុអាកាសចរណ៍

គ្រប់អាកាសយានទាំងអស់ដែលកំពុងធ្វើប្រតិបត្តិការហោះហើរក្នុងដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបំពាក់ឧបករណ៍វិទ្យុអាកាសចរណ៍ដែលមានអាជ្ញាបណ្ណនិងបានដំឡើងស្របតាមច្បាប់នៃរដ្ឋចុះបញ្ជីអាកាសយាន និងប្រតិបត្តិស្របតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលដែលធ្វើឡើងតាមច្បាប់នេះ ព្រមទាំងវិធាននានាដែលបង្កើតឡើងដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ឧបករណ៍វិទ្យុអាកាសចរណ៍ប្រើប្រាស់ក្នុងអាកាសយានដែលចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានអាជ្ញាបណ្ណឬការអនុញ្ញាតក្នុងការប្រើប្រាស់ហ្វ្រេកង់វិទ្យុចេញដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ឧបករណ៍វិទ្យុអាកាសចរណ៍ផ្ទៃដីដែលជាឋបនីយភ័ណ្ឌនាំផ្លូវអាកាសត្រូវមានអាជ្ញាបណ្ណហ្វ្រេកង់វិទ្យុដែលចេញដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បន្ទាប់ពីទទួលបានការពិនិត្យនិងការបញ្ជាក់យថាប្រភេទនិងវិញ្ញាបនបត្រស្ថានីយ៍អាកាសចរណ៍ចេញដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវមានការត្រួតពិនិត្យបច្ចេកទេសលើស្តង់ដានៃការដំឡើងនិងការថែទាំ៖

- ឧបករណ៍វិទ្យុអាកាសចរណ៍ក្នុងអាកាសយានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ប្រព័ន្ធនិងឧបករណ៍វិទ្យុអាកាសចរណ៍និងឧបករណ៍ជំនួយនាំផ្លូវអាកាស ដែលមានស្រាប់ឬដែលត្រូវបង្កើតឡើង។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវគ្រប់គ្រងនិងត្រួតពិនិត្យតាមដាននីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជននានា ដែលទទួលខុសត្រូវបង្កើតនិងថែទាំបណ្តាញទូរគមនាគមន៍អាកាសចរណ៍និងឧបករណ៍ជំនួយផ្នែកនាំផ្លូវអាកាស ដើម្បីធានាថានីតិបុគ្គលទាំងនោះចាត់វិធានការចាំបាច់ដើម្បីអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវធានានូវការចុះហត្ថលេខា និងតាមដានអនុវត្តកិច្ចព្រមព្រៀងផ្លូវការដើម្បីបង្កើតការទទួលខុសត្រូវរៀងៗខ្លួន ទាំងសម្រាប់ទិដ្ឋភាពនិយ័តកម្ម និងការផ្តល់សេវាកម្មទូរគមនាគមន៍នានា។

លើកលែងតែទទួលបានការអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលនិងអនុវត្តស្របតាមរយៈពេលកម្រិតកំណត់និងលក្ខខណ្ឌនៃការអនុញ្ញាតដែលមានចែងនៅក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល និងលក្ខខណ្ឌនិងស្តង់ដាហ្វ្រេកង់វិទ្យុដែលកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងលើកលែងតែឧប[illegible]ដែលមិនស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ហើយរំខានដល់ដំណើរការ[illegible]ហ្វ្រេកង់វិទ្យុអាកាសចរណ៍នានា រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវស្នើសុំកិច្ចសហការពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ គ្មានបុគ្គលណាមួយអាច៖

- [illegible]បញ្ជូននិង/ឬទទួលសញ្ញាវិទ្យុពីអាកាសយាន
- ប្រើគ្រឿងម៉ាស៊ីននានា ឬបរិក្ខារ ឬឧបករណ៍ដែលរំខានដល់ឧបករណ៍វិទ្យុអាកាសចរណ៍។

**មាត្រា១៧ ._** សៀវភៅកត់ត្រាការហោះហើរនិងឯកសារតម្រូវក្នុងពេលហោះហើរ

អាកាសយានទាំងអស់ដែលប្រតិបត្តិការហោះហើរនៅក្នុងដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរក្សាទុកសៀវភៅកត់ត្រាការហោះហើរ និងត្រូវបំពេញព័ត៌មានអំពីភិនភាគអាកាសយាន ក្រុមហោះ និងជើងហោះហើរនីមួយៗ ក្នុងទម្រង់ដែលតម្រូវដោយច្បាប់របស់រដ្ឋចុះបញ្ជីអាកាសយាន។

លើកលែងតែប្រភេទអាកាសយានខ្លះដែលមិនតម្រូវដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល អាកាសយានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ក្នុងពេលហោះហើរត្រូវយកតាមជាមួយនៅលើអាកាសយាននូវឯកសារដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះបញ្ជី
- វិញ្ញាបនបត្រលទ្ធភាពហោះហើរ
- អាជ្ញាបណ្ណសម្រាប់សមាជិកនីមួយៗនៃក្រុមអាកាសយានិក
- សៀវភៅកត់ត្រាហោះហើរ
- អាជ្ញាបណ្ណវិទ្យុអាកាសចរណ៍
- សៀវភៅប្រតិបត្តិការហោះហើរ
- បញ្ជីឈ្មោះអ្នកដំណើរឬបញ្ជីមុខទំនិញដែលដឹកជញ្ជូនតាមផ្លូវអាកាស
- វិញ្ញាបនបត្រធានារ៉ាប់រង។

ឯកសារតម្រូវក្នុងពេលហោះហើរផ្សេងៗទៀត ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

ឯកសារនានាដែលដាក់តាមអាកាសយានដែលចុះបញ្ជីនៅរដ្ឋផ្សេង ត្រូវអនុវត្តស្របតាមលក្ខខណ្ឌតម្រូវរបស់រដ្ឋនោះ។ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានសិទ្ធិតម្រូវឱ្យផលិតនិងពិនិត្យឯកសារទាំងនោះដែលត្រូវយកតាមជាមួយនៅលើអាកាសយាន ដើម្បីអនុលោមតាមច្បាប់នេះ។

ទម្រង់និងមាតិកាលម្អិតនៃសៀវភៅកត់ត្រាការហោះហើរ ដែលពាក់ព័ន្ធនឹងអាកាសយានចុះបញ្ជីនៅកម្ពុជា ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

## ជំពូកទី៨

## បុគ្គលិក

**មាត្រា១៨ ._** បុគ្គលិកអាកាសចរណ៍ស៊ីវិល

បុគ្គលិកអាកាសចរណ៍ស៊ីវិល មានជាអាទិ៍អ្នកបញ្ជាចរាចរណ៍ផ្លូវអាកាស ក្រុមអាកាសយានិក ក្រុមបាហុនិកា អ្នកបច្ចេកទេស ឬអ្នកឯកទេសសេវាកម្មផ្ទៃដី មិនត្រូវបានអនុញ្ញាតឱ្យបំពេញភារកិច្ចរបស់ខ្លួនឡើយ ប្រសិនបើបុគ្គលទាំងនោះពុំមានអាជ្ញាបណ្ណដែលផ្តល់ឬទទួលស្គាល់សុពលភាពស្របតាមច្បាប់នេះ។

ប្រតិបត្តិករអាកាសយានមិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការអាកាសយានទេ ប្រសិនបើស្តង់ដាដែលបានចែងសម្រាប់ប្រភេទប្រតិបត្តិការនីមួយៗមិនត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់ដោយក្រុមអាកាសយានិក និងប្រសិនបើសមាជិកនីមួយៗនៃក្រុមហោះមិនបំពេញបាននូវស្តង់ដាមុខងារនិងភារកិច្ចរបស់ខ្លួន។

ស្តង់ដារដែលត្រូវអនុវត្តចំពោះសមាជិកក្រុមអាកាសយានិក មានជាអាទិ៍ថេរវេលាបំពេញភារកិច្ចអតិបរមា និងរយៈពេលសម្រាក រចនាសម្ព័ន្ធអង្គការចាត់តាំង ការរៀបចំ ការបណ្តុះបណ្តាល និងការប្រឡងរបស់ក្រុមអាកាសយានិកដែលបំពេញភារកិច្ចលើអាកាសយានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

**មាត្រា១៩ .-** អាជ្ញាបណ្ណឬវិញ្ញាបនបត្រ

សមាជិកក្រុមហោះនៃអាកាសយានដែលកំពុងប្រតិបត្តិការហោះហើរក្នុងដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រនៅមានសុពលភាពដែលផ្តល់ឬទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាបណ្ណឬវិញ្ញាបនបត្រដែលផ្តល់ឬទទួលស្គាល់សុពលភាពដោយរដ្ឋដទៃ ត្រូវបានទទួលស្គាល់សុពលភាពដោយព្រះរាជាណាចក្រកម្ពុជា ប្រសិនបើលក្ខខណ្ឌតម្រូវនៃការផ្តល់ឬទទួលស្គាល់សុពលភាពអាជ្ញាបណ្ណឬវិញ្ញាបនបត្រដោយរដ្ឋនោះមានកម្រិតស្មើនឹងឬលើសស្តង់ដាអប្បបរមាដែលបង្កើតឡើងជាបន្តបន្ទាប់ក្រោមអនុសញ្ញាស៊ីកាហ្គោ។

ពាក់ព័ន្ធនឹងអាជ្ញាបណ្ណឬវិញ្ញាបនបត្រដែលផ្តល់ដោយរដ្ឋដទៃ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចៈ

- ផ្តល់វិញ្ញាបនបត្របញ្ជាក់សមត្ថភាព
- ប្តូរទម្រង់មកជាអាជ្ញាបណ្ណកម្ពុជា
- បញ្ចូលលក្ខខណ្ឌឬការកម្រិតកំណត់ផ្សេងៗលើអាជ្ញាបណ្ណឬវិញ្ញាបនបត្រដែលមានលក្ខណៈចាំបាច់ចំពោះសុវត្ថិភាពឬសន្តិសុខ
- ព្យួរឬដកហូតអាជ្ញាបណ្ណឬវិញ្ញាបនបត្រទាំងនោះ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណឬវិញ្ញាបនបត្របញ្ជាក់សមត្ថភាពជូនសមាជិកក្រុមអាកាសយានិកនិងបុគ្គលិកអាកាសចរណ៍ស៊ីវិលដទៃទៀត ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

បុគ្គលដែលកាន់កាប់អាជ្ញាបណ្ណឬវិញ្ញាបនបត្រ ហើយដែលចូលរួមក្នុងប្រតិបត្តិការអាកាសយានឬអនុវត្តភារកិច្ចពាក់ព័ន្ធនឹងអាកាសយាន មិនត្រូវធ្វើសកម្មភាពឱ្យហួសពីកម្រិតកំណត់នៃអាជ្ញាបណ្ណឬវិញ្ញាបនបត្រឡើយ លើកលែងតែក្នុងករណីប្រធានសក្តិ។

អាកាសយានិកដែលធ្វើប្រតិបត្តិការអាកាសយាន ត្រូវមានវិញ្ញាបនបត្របញ្ជាក់សុខភាពដែលមានសុពលភាពឬបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌតម្រូវរបស់អាជ្ញាបណ្ណ។

សមាជិកក្រុមអាកាសយានិក ត្រូវបង្ហាញអាជ្ញាបណ្ណរបស់ខ្លួនសម្រាប់ការធ្វើអធិការកិច្ចតាមលក្ខខណ្ឌតម្រូវរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលឬអាជ្ញាធរអាកាសចរណ៍ស៊ីវិលនៃរដ្ឋដទៃ។

**មាត្រា២០ .-** មេបញ្ជាការអាកាសយាន

សម្រាប់ដំណាក់អាកាសវិថីនីមួយៗ ប្រតិបត្តិករអាកាសយានត្រូវចាត់តាំងសមាជិកក្រុមអាកាសយានិកណាម្នាក់ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាមេបញ្ជាការអាកាសយាន ហើយសមាជិកក្រុមអាកាសយានិកម្នាក់ទៀតជាជំនួយការដែលបំពេញតួនាទីជាមេបញ្ជាការអាកាសយាននៅពេលចាំបាច់។

មេបញ្ជាការអាកាសយាន ត្រូវទទួលខុសត្រូវទាំងស្រុងលើកិច្ចប្រតិបត្តិការអាកាសយានដោយអនុលោមតាមវិធាននៃប្រតិបត្តិការក្នុងពេលហោះហើរនិងរក្សាការពារអាកាសយាន មនុស្ស និងទ្រព្យសម្បត្តិនៅលើអាកាសយាននោះ។ មេបញ្ជាការអាកាសយាន ត្រូវអនុវត្តតាមបទបញ្ជាដែនអាកាសនិងការបញ្ជាណែនាំសមស្របរបស់អ្នកបញ្ជាចរាចរណ៍អាកាស ព្រមទាំងលក្ខខណ្ឌតម្រូវមួយចំនួនទៀត ដែលតម្រូវដោយច្បាប់នេះឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មេបញ្ជាការអាកាសយាន គឺជាបុគ្គលដែលមានសិទ្ធិសម្រេចខ្ពស់បំផុតនៅលើអាកាសយាន ហើយត្រូវបានផ្ដល់នូវសិទ្ធិអំណាចចាំបាច់ ជាពិសេសគឺសិទ្ធិដែលបានរៀបរាប់នៅក្នុងជំពូក៣នៃអនុសញ្ញាតូក្យូឆ្នាំ១៩៦៣ស្ដីពីការប្រព្រឹត្តបទល្មើសនិងការប៉ុនប៉ងប្រព្រឹត្តបទល្មើសផ្សេងៗទៀតលើអាកាសយានដែលមានចែងលម្អិតនៅក្នុងច្បាប់ស្ដីពីការប្រឆាំងនឹងភេរវកម្ម ដើម្បីប្រកាន់យកសកម្មភាពតាមដំណាក់កាលដែលយល់ថាសមស្របចាំបាច់ ក្នុងភារកិច្ចទទួលខុសត្រូវរបស់ខ្លួន។

ក្នុងពេលបំពេញភារកិច្ចនិងធ្វើសកម្មភាពតាមសមត្ថភាពជាផ្លូវការរបស់ខ្លួន នៅពេលកំពុងហោះហើរ មេបញ្ជាការអាកាសយានដែលអាកាសយាននោះត្រូវបានប្រតិបត្តិការដោយសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស មិនទទួលខុសត្រូវដោយផ្ទាល់ខ្លួនឯងទេ ហើយត្រូវរួចផុតពីការទទួលខុសត្រូវចំពោះការខូចខាតបណ្ដាលមកពីសកម្មភាពឬការខកខានរបស់មេបញ្ជាការអាកាសយានឬរបស់បុគ្គលិកណាម្នាក់ដែលអនុវត្តតាមបញ្ជារបស់ខ្លួន ប្រសិនបើការងារនិងសកម្មភាពនោះសមស្របចាំបាច់ក្នុងការសង្គ្រោះនិងថែរក្សាសុវត្ថិភាពអាកាសយាន មនុស្ស ឬទ្រព្យសម្បត្តិនៅលើអាកាសយាននោះ។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចប្រគល់ភារកិច្ចនិងការទទួលខុសត្រូវបន្ថែមទៅឱ្យមេបញ្ជាការអាកាសយានតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ក្នុងករណីចាំបាច់សម្រាប់ផលប្រយោជន៍សុវត្ថិភាព និងសន្តិសុខ។

**មាត្រា២១ ._** ការរាយការណ៍

បុគ្គលពាក់ព័ន្ធដែលត្រូវរាយការណ៍ រួមមាន៖

- ម្ចាស់កម្មសិទ្ធិ ប្រតិបត្តិករ ឬមេបញ្ជាការអាកាសយាន ក្នុងពេលកើតមានការរំលោភបំពានច្បាប់ គ្រោះថ្នាក់ ឧប្បត្តិហេតុ ឬអំពើនានា
- ប្រតិបត្តិករអាកាសយានដ្ឋាន ក្នុងករណីការរំលោភបំពានច្បាប់ គ្រោះថ្នាក់ ឧប្បត្តិហេតុ ឬអំពើនានាកើតឡើងក្នុងបរិវេណនិងជុំវិញអាកាសយានដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា
- អ្នកផ្ដល់សេវាកម្មចរាចរណ៍ផ្លូវអាកាស ក្នុងករណីការរំលោភបំពានច្បាប់ គ្រោះថ្នាក់ ឧប្បត្តិហេតុ ឬអំពើនានាកើតឡើងនៅក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា
- អ្នករៀបចំការសម្ដែងការហោះហើរ ក្នុងករណីរំលោភច្បាប់ គ្រោះថ្នាក់ ឧប្បត្តិហេតុ ឬអំពើនានាកើតមាននៅក្នុងកំឡុងពេលការសម្ដែងការហោះហើរក្នុងព្រះរាជាណាចក្រកម្ពុជា
- បុគ្គលទាំងអស់ដែលកាន់ឯកសារអាកាសចរណ៍ចេញដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬទទួលស្គាល់សុពលភាពដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬបុគ្គលដទៃទៀតដែលអនុវត្តមុខងារប្រតិបត្តិការអាកាសចរណ៍ស៊ីវិល មានជាអាទិ៍ក្រុមអាកាសយានិក អ្នកបច្ចេកទេសអាកាសយាន អ្នកបញ្ជាចរាចរណ៍ផ្លូវអាកាស ឬនិយោជិតក្រុមហ៊ុនអាកាសចរណ៍ ឬអាកាសយានដ្ឋាន និងបុគ្គលដទៃទៀតដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលនានា សម្រាប់គោលបំណងនៃច្បាប់នេះ ក្នុងករណីមានការរំលោភបំពានច្បាប់ គ្រោះថ្នាក់ ឧប្បត្តិហេតុ ឬអំពើទាំងឡាយ កើតឡើងក្រៅពីករណីដែលបានរៀបរាប់ក្នុងកថាខណ្ឌនេះ។

បុគ្គលពាក់ព័ន្ធដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវរាយការណ៍ឱ្យបានទាន់ពេលវេលាអំពី៖

- ការរំលោភច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ទៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- [illegible]និងទម្រង់ដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនោះ និងលក្ខខណ្ឌតម្រូវ[illegible]លេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

- គ្រោះថ្នាក់និងឧប្បត្តិហេតុអាកាសយានឬអំពើណាមួយដែលមានឥទ្ធិពលអាក្រក់ដល់សុវត្ថិភាពអាកាសចរណ៍ស៊ីវិល ទៅអាជ្ញាធរស៊ើបអង្កេតសុវត្ថិភាពអាកាសយាននៃព្រះរាជាណាចក្រកម្ពុជាតាមបែបបទនិងទម្រង់ដែលបានកំណត់។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលនិងអាជ្ញាធរទទួលបន្ទុកស៊ើបអង្កេតសុវត្ថិភាពអាកាសយាននៃព្រះរាជាណាចក្រកម្ពុជាត្រូវជូនដំណឹងឱ្យគ្នាទៅវិញទៅមកជាបន្ទាន់ បន្ទាប់ពីទទួលបានការរាយការណ៍ដូចមានចែងក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើនេះ។

របាយការណ៍ដែលមានចែងក្នុងមាត្រា២១នេះ គឺជាកម្មវត្ថុនៃការសម្រេចចិត្តបន្ទាន់របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលឬអាជ្ញាធរទទួលបន្ទុកស៊ើបអង្កេតសុវត្ថិភាពអាកាសយាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកំណត់វិធានការអនុវត្តបន្តក្នុងករណីចាំបាច់។

## ជំពូកទី៩
## កិច្ចប្រតិបត្តិការអាកាសយាននិងការនាំផ្លូវអាកាស

**មាត្រា២២ .-** បទបញ្ជាដែនអាកាស

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវចេញនិងផ្សព្វផ្សាយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលស្តីពីបទបញ្ជាដែនអាកាសដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញាស៊ីកាហ្គោ។ បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលចែងផ្សេងពីបទប្បញ្ញត្តិនៃអនុសញ្ញាស៊ីកាហ្គោ ត្រូវផ្សព្វផ្សាយនៅក្នុងសៀវភៅព័ត៌មានអាកាសចរណ៍ស៊ីវិល។

មេបញ្ជាការអាកាសយាននៃអាកាសយានដែលធ្វើប្រតិបត្តិការអាកាសយាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាឬក្នុងតំបន់គ្រប់គ្រងព័ត៌មានហោះហើរនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុលោមតាមបទប្បញ្ញត្តិនាំផ្លូវអាកាសជាតិនិងអន្តរជាតិ ហើយបទប្បញ្ញត្តិទាំងនេះក៏ត្រូវគោរពតាមផងដែរដោយអាកាសយានយោធានៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រតិបត្តិការអាកាសយាននោះមានបេសកកម្មជាលក្ខណៈយោធា។

មេបញ្ជាការអាកាសយាននៃអាកាសយានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាដែលធ្វើប្រតិបត្តិការនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីបទបញ្ជាដែនអាកាសជាធរមាននៃរដ្ឋដែលបានហោះហើរឆ្លងកាត់ និងនៅពេលហោះហើរលើដែនសមុទ្រអន្តរជាតិ ត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយដែលបង្កើតឡើងជាបន្តបន្ទាប់នៃអនុសញ្ញាស៊ីកាហ្គោ។

**មាត្រា២៣ .-** ឋបនីយកណ្ឌនាំផ្លូវអាកាសនិងសេវាកម្មនាំផ្លូវអាកាស

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវបង្កើតនិងថែរក្សាឋបនីយកណ្ឌនាំផ្លូវអាកាស និងផ្តល់សេវាកម្មនាំផ្លូវអាកាសនៅក្នុងដែនអាកាសគ្រប់គ្រងដោយព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាសុវត្ថិភាពរបស់អាកាសយានដែលធ្វើប្រតិបត្តិការហោះហើរក្នុងដែនអាកាសរបស់ខ្លួន។ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចអនុវត្តកាតព្វកិច្ចនេះ ដោយខ្លួនឯងផ្ទាល់ ឬតាមរយៈការចុះកិច្ចព្រមព្រៀងជាមួយនីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជនដទៃទៀត។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវគ្រប់គ្រងនិងត្រួតពិនិត្យតាមដាននីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជនដែលជាប្រតិបត្តិករសេវាកម្មនាំផ្លូវអាកាសនិងបុគ្គលដែលទទួលបន្ទុកក្នុងការបង្កើត ថែរក្សា និងធ្វើទំនើបកម្មឋបនីយកណ្ឌនាំផ្លូវអាកាស ប្រព័ន្ធទូរគមនាគមន៍អាកាសចរណ៍ ឧបករណ៍ជំនួយ គ្រឿងបរិក្ខារ និងប្រព័ន្ធនាំផ្លូវអាកាសនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាអនុលោមភាពនៃច្បាប់នេះ។

នីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជន មិនអាចធ្វើប្រតិបត្តិការផ្តល់សេវាកម្មនាំផ្លូវអាកាសបានទេ លុះត្រាតែទទួលបានការអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អនុលោមតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ស្របតាមច្បាប់នេះ ហើយការអនុញ្ញាតនេះត្រូវអស់សុពលភាពទៅតាមព្រឹត្តិការណ៍ណាមួយដែលបានកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

ស្តង់ដាសម្រាប់បុគ្គលិកនាំផ្លូវអាកាស បបនីយកណ្ឌនាំផ្លូវអាកាស និងសេវាកម្មនាំផ្លូវអាកាស និងឧបករណ៍វិទ្យុអាកាសចរណ៍ ដែលត្រូវប្រើប្រាស់ក្នុងការនាំផ្លូវអាកាស ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ដោយអនុលោមតាមស្តង់ដានិងអនុសាសន៍ណែនាំដែលបង្កើតឡើងក្រោមអនុសញ្ញាស៊ីកាហ្គោ។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលមានសិទ្ធិទទួល បែងចែក និងប្រើប្រាស់ហ្វ្រេកង់ស៍អាកាសចរណ៍ដែលកំណត់ឬផ្តល់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយអនុលោមទៅតាមលក្ខខណ្ឌនិងស្តង់ដារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សហភាពទូរគមនាគមន៍អន្តរជាតិ និងអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដើម្បីធានាសុវត្ថិភាពនិងគុណភាពនៃសេវាកម្មនាំផ្លូវអាកាស។

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសទាំងអស់ ត្រូវបង់កម្រៃសេវាជូនទៅប្រតិបត្តិករផ្តល់សេវាកម្មនាំផ្លូវអាកាស ទៅតាមតារាងកម្មវិធីហោះហើររបស់ខ្លួន ដើម្បីធានាបាននូវសុវត្ថិភាពនិងប្រសិទ្ធភាពនៃការដឹកជញ្ជូនតាមផ្លូវអាកាស។

**មាត្រា២៤ .-** ការគ្រប់គ្រងដែនអាកាស

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចបង្កើតអាកាសវិថីនិងកំណត់តំបន់ហាមឃាត់ តំបន់កម្រិតការហោះហើរ ឬតំបន់គ្រោះថ្នាក់ ដែលអាកាសយានស៊ីវិលត្រូវអនុលោមតាមពេលធ្វើប្រតិបត្តិការហោះហើរក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចាំបាច់របស់មូលដ្ឋានយោធាឬសុវត្ថិភាពសាធារណៈ និងសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា។

មេបញ្ជាការអាកាសយាននៃអាកាសយានណាមួយដែលកំពុងធ្វើប្រតិបត្តិការហោះហើរឬធ្វើសកម្មភាពនៅក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពទៅតាមអាកាសវិថី ដូចដែលរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលបានបង្កើត ហើយត្រូវជៀសវាងតំបន់ទាំងឡាយណាដែលបានកំណត់ជាតំបន់ហាមឃាត់ តំបន់កម្រិតការហោះហើរ ឬតំបន់គ្រោះថ្នាក់។

មេបញ្ជាការអាកាសយាននៃអាកាសយានណាមួយដែលហោះឃ្លាតពីអាកាសវិថី ដែលបានកំណត់នោះ ឬចូលតំបន់ហាមឃាត់ តំបន់កម្រិតការហោះហើរ ឬតំបន់គ្រោះថ្នាក់ ត្រូវបានចាត់ទុកជាប្រតិបត្តិការខុសច្បាប់ ហើយត្រូវចាត់វិធានការកែតម្រូវជាបន្ទាន់។

មេបញ្ជាការអាកាសយាននៃអាកាសយានណាមួយដែលទទួលបានបទបញ្ជាឱ្យចុះចតនៅអាកាសយានដ្ឋានណាមួយដែលបានកំណត់ពីមេបញ្ជាការអាកាសយានកងទ័ពជើងអាកាស នគរបាល គយ ឬពីបុគ្គលិកបញ្ជាហោះហើរផ្នែកយោធា នគរបាល គយ ត្រូវតែគោរពតាមបទបញ្ជានេះ ក្នុងលក្ខខណ្ឌបទបញ្ជានេះធ្វើឡើងដោយមានការពិភាក្សានិងការសម្របសម្រួលជាមុនពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

លើកលែងតែក្នុងករណីការពារខ្លួនជាធម្មានុរូប ការអនុវត្តអធិបតេយ្យភាពលើដែនអាកាសរបស់ខ្លួននៅពេលមានការបំពានលើអធិបតេយ្យកើតឡើង ព្រះរាជាណាចក្រកម្ពុជាត្រូវជៀសវាងការប្រើប្រាស់អាវុធប្រឆាំងនឹងអាកាសយានស៊ីវិលក្នុងពេលហោះហើរ។

**មាត្រា២៥ .-** ការគ្រប់គ្រងនិងផ្សព្វផ្សាយព័ត៌មានអាកាសចរណ៍

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវទទួលខុសត្រូវចំពោះសេវាកម្មព័ត៌មានអាកាសចរណ៍ដោយខ្លួនឯងផ្ទាល់ឬតាមរយៈការចុះកិច្ចព្រមព្រៀងជាមួយនីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជនដទៃទៀត ដែលក្នុងករណីនេះ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវគ្រប់គ្រងនិងត្រួតពិនិត្យតាមដាននីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជននោះ មានជាអាទិ៍ការប្រមូល ការបោះពុម្ពផ្សាយ ការចែកចាយ និងការធ្វើបច្ចុប្បន្នកម្មព័ត៌មានអាកាសចរណ៍ ការណែនាំ និងការចេញការជូនដំណឹងទៅអ្នកប្រើប្រាស់ព័ត៌មានអាកាសចរណ៍ និងអនុលោមតាមបទប្បញ្ញត្តិអន្តរជាតិជាធរមាន។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចបោះពុម្ពផ្សាយព័ត៌មានស្តីពីការងារអាកាសចរណ៍ផ្សេងៗដូចជាការងារអាជ្ញាបណ្ណ ការថែទាំបច្ចេកទេសជាដើម ឬការងារផ្សេងទៀត ដូចជាព្រឹត្តិបត្រអាកាសចរណ៍ស៊ីវិល សេចក្តីណែនាំព័ត៌មានអាកាសចរណ៍ សេចក្តីណែនាំលទ្ធភាពហោះហើរជាដើម។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចចេញសេចក្តីណែនាំស្តីពីការអនុវត្តបញ្ញត្តិទាំងឡាយដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ក្នុងគោលបំណងផ្តល់នូវមធ្យោបាយអនុលោមភាពដែលអាចទទួលយកបាន ឬផ្តល់ការបកស្រាយ ឬការពន្យល់សម្រាប់អនុវត្តបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលទាំងនោះ។

លិខិតបទដ្ឋានទាំងឡាយដែលចេញដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវរៀបចំនិងបោះពុម្ពផ្សាយ ហើយត្រូវមានអានុភាពអនុវត្តតាមផ្លូវច្បាប់។

ប្រតិបត្តិករអាកាសយានដ្ឋានអន្តរជាតិឬអាកាសយានដ្ឋានដទៃទៀតដែលកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ត្រូវបង្កើតការិយាល័យព័ត៌មានមួយក្រោមការត្រួតពិនិត្យបច្ចេកទេសពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីផ្តល់ព័ត៌មានសំខាន់ៗដល់ក្រុមហោះនិងប្រតិបត្តិករសម្រាប់ការហោះហើរ និងមានសារៈសំខាន់សម្រាប់សុវត្ថិភាព ប្រក្រតីភាព និងមានប្រសិទ្ធភាពនៃការនាំផ្លូវអាកាសលើអាកាសវិថីចេញដំណើរពីអាកាសយានដ្ឋាន។

**មាត្រា២៦ .-** ឧតុនិយមអាកាសចរណ៍

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ទទួលខុសត្រូវលើការផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍ដោយខ្លួនឯងផ្ទាល់ឬតាមរយៈការចុះកិច្ចព្រមព្រៀងជាមួយនីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជនដទៃទៀត ដែលក្នុងករណីនេះ ដោយពិគ្រោះយោបល់ជាមួយក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវគ្រប់គ្រងនិងត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់នីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជននេះ ដែលបានបញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀង ស្របតាមច្បាប់និងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

ក្រសួងធនធានទឹកនិងឧតុនិយមមានកាតព្វកិច្ចផ្តល់ទិន្នន័យចាំបាច់និងគ្រប់គ្រាន់ដល់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍ឱ្យមានប្រសិទ្ធភាព។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬនីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជនដែលផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍ ត្រូវរៀបចំបញ្ចូលព័ត៌មានលម្អិតដែលពាក់ព័ន្ធនឹងអាជ្ញាធរដែលផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍ទៅក្នុងសៀវភៅព័ត៌មានអាកាសចរណ៍។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬនីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជនដែលផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ក្រសួងធនធានទឹកនិងឧតុនិយមនិងអង្គការឧតុនិយមពិភពលោកពាក់ព័ន្ធនឹងគុណវុឌ្ឍិ សមត្ថភាព ការអប់រំនិងបណ្តុះបណ្តាលរបស់បុគ្គលិកឧតុនិយមដែលផ្តល់សេវាកម្មសម្រាប់ការនាំផ្លូវអាកាសជាតិនិងអន្តរជាតិ ដូចមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលទាំងឡាយនៃច្បាប់នេះ។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬនីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជនដែលផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍ ត្រូវបង្កើតនិងអនុវត្តប្រព័ន្ធគ្រប់គ្រងគុណភាពសមស្របមួយដែលរួមបញ្ចូលនូវនីតិវិធីដំណើរការ ទម្រង់ និងធនធានចាំបាច់ដើម្បីផ្តល់ការគ្រប់គ្រងគុណភាពព័ត៌មានឧតុនិយម។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្នុងពេលផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍ដោយខ្លួនឯងផ្ទាល់ត្រូវធានាថា៖

- ស្តង់ដាដែលកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ត្រូវបានអនុវត្ត
- អង្គភាពណាមួយនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដែលមិនពាក់ព័ន្ធនឹងការផ្តល់សេវាកម្មខាងលើ មានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យតាមដានការផ្តល់សេវាកម្មឧតុនិយមអាកាសចរណ៍ដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១០

## ការរុករកនិងសង្គ្រោះ

**មាត្រា២៧ .-** ការជួយប្រតិបត្តិការគាំទ្រដល់អាកាសយានបាត់ដំណឹងឬជួបគ្រោះអាសន្ន

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវបង្កើត ថែរក្សា និងផ្តល់សេវាកម្មរុករកនិងសង្គ្រោះ និងត្រូវផ្តល់ការជួយប្រតិបត្តិការគាំទ្រអាកាសយានបាត់ដំណឹងឬជួបគ្រោះអាសន្ននិងមនុស្សនៅលើអាកាសយាន នៅក្នុងព្រះរាជាណាចក្រកម្ពុជានិងតំបន់ដទៃទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលខុសត្រូវក្នុងការផ្តល់សេវាកម្មរុករកនិងសង្គ្រោះ ដោយផ្អែកលើកិច្ចព្រមព្រៀងនាំផ្លូវអាកាសក្នុងតំបន់។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវផ្តល់សេវាកម្មរុករកនិងសង្គ្រោះឱ្យបានឆាប់រហ័សលើមូលដ្ឋាន២៤ម៉ោងលើ២៤ម៉ោង និងមានគំរូវិធីសាស្ត្រ ផែនការប្រតិបត្តិការរបស់ខ្លួននិងមធ្យោបាយនានា សម្រាប់អនុវត្តសេវាកម្មរុករកនិងសង្គ្រោះដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចពិចារណាលើសំណើរបស់រដ្ឋដទៃឬអង្គការអន្តរជាតិនានាស្តីពីការជួយប្រតិបត្តិការដល់ការរុករកនិងសង្គ្រោះអាកាសយានដែលបាត់ដំណឹងឬមានគ្រោះថ្នាក់នៅក្នុងដែនដីនៃប្រទេសជិតខាងឬដែនសមុទ្រអន្តរជាតិ។

ក្នុងករណីអាកាសយានដែលចុះបញ្ជីនៅរដ្ឋដទៃបាត់ដំណឹងឬមានគ្រោះអាសន្ននៅក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវអនុញ្ញាតឱ្យអង្គភាពរុករកនិងសង្គ្រោះរបស់រដ្ឋនោះ ផ្តល់នូវសេវាការជួយប្រតិបត្តិការគាំទ្រតាមការចាំបាច់ទៅតាមកាលៈទេសៈ ក្នុងគោលបំណងស្វែងរកទីតាំងគ្រោះថ្នាក់អាកាសយាននិងជួយសង្គ្រោះអ្នកមានជីវិតពីគ្រោះថ្នាក់នោះ

- អាជ្ញាធរមានសមត្ថកិច្ចទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា យោងតាមលក្ខខណ្ឌកំណត់នានា ត្រូវចាត់វិធានការដើម្បីជួយសម្រួលតាមដែលអាចធ្វើបាននូវការឆ្លងដែនរបស់បុគ្គលិកនិងការនាំចូលសម្ភារៈរបស់រដ្ឋដទៃចូលក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមប្រតិបត្តិការរុករកនិងសង្គ្រោះ ហើយដែលការជួយប្រតិបត្តិការគាំទ្រទាំងនោះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាគ្រប់ពេល។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចៈ

- ចេញបញ្ជាពាក់ព័ន្ធនឹងការប្រើប្រាស់អាកាសយាន យានយន្ត ឬយានដទៃទៀត និងគ្រឿងបំពាក់នានា ដោយសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ អាជ្ញាធរអាកាសយានដ្ឋាន កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរដែនដី និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត តាមការចាំបាច់
- ចុះកិច្ចព្រមព្រៀងស្តីពីការជួយប្រតិបត្តិការគាំទ្រជាមួយអាជ្ញាធរដែនដីនៅក្រៅយុត្តាធិការកម្ពុជា ឬរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជននានា
- សហការលើសកម្មភាពសម្របសម្រួល ដែលមានចែងឬណែនាំក្រោមអនុសញ្ញាស៊ីកាហ្គោ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីឬពហុភាគីស្តីពីការផ្តល់សេវាកម្មរុករកនិងសង្គ្រោះក្នុងតំបន់ ដោយមានការយល់ព្រមជាមុនពីរាជរដ្ឋាភិបាល។

ក្នុងការអនុវត្តរាល់កាតព្វកិច្ចខាងលើ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

ម្ចាស់កម្មសិទ្ធិ ឬប្រតិបត្តិករអាកាសយាន ឬសន្តតិជន ត្រូវទូទាត់សំណងរាល់ការចំណាយលើការរុករកនិងសង្គ្រោះនិងការចំណាយលើការយកចេញឬការកម្ទេចចោលនូវបំណែកនានា ដល់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

បែបបទនិងនីតិវិធីនៃការទូទាត់សំណងដូចមានចែងក្នុងកថាខណ្ឌទី៦ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា២៨ ._** មជ្ឈមណ្ឌលសម្របសម្រួលនិងសង្គ្រោះ

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវបង្កើតមជ្ឈមណ្ឌលសម្របសម្រួលនិងសង្គ្រោះ ដើម្បីជំរុញការរៀបចំប្រកបដោយប្រសិទ្ធភាពនូវសេវាកម្មរុករកនិងសង្គ្រោះ និងដើម្បីសម្របសម្រួលកិច្ចប្រតិបត្តិការ រុករកនិងសង្គ្រោះ ដែលតម្រូវឱ្យមានបុគ្គលិកប្រចាំការ២៤ម៉ោងលើ២៤ម៉ោង ដែលមានការបណ្តុះបណ្តាលនិងលក្ខណសម្បត្តិគ្រប់គ្រាន់។

ការបង្កើតមជ្ឈមណ្ឌលសម្របសម្រួលនិងសង្គ្រោះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា២៩ ._** ការត្រួតពិនិត្យតាមដានការផ្តល់សេវាកម្មរុករកនិងសង្គ្រោះ

នៅពេលផ្តល់សេវាកម្មរុករកនិងសង្គ្រោះ និងដំណើរការមជ្ឈមណ្ឌលសម្របសម្រួលនិងសង្គ្រោះ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវធានាថា៖

- ស្តង់ដារដែលកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ត្រូវបានអនុវត្ត
- អង្គភាពណាមួយនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដែលមិនពាក់ព័ន្ធនឹងការផ្តល់សេវាកម្ម [illegible] មានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យតាមដានការផ្តល់សេវាកម្មរុករកនិងសង្គ្រោះដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១១
## ទំនិញគ្រោះថ្នាក់

**មាត្រា៣០ .-** ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាស

ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាសចេញ ចូល ឬនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានហាមឃាត់ លើកលែងតែមានចែងក្នុងកថាខណ្ឌទី៣និងទី៤នៃមាត្រា៣០នេះ។

ទំនិញគ្រោះថ្នាក់ដែលត្រូវបានហាមឃាត់ក្នុងកថាខណ្ឌទី១ មានជាអាទិ៍៖

- អង្គធាតុផ្ទុះគ្រប់ប្រភេទ ព្រមទាំងអាវុធយុទ្ធភណ្ឌ
- ឧស្ម័នកំហាប់ឬឧស្ម័នរាវដែលអាចបង្កឱ្យមានជាតិពុលឬឆាបឆេះ
- សារធាតុរាវងាយឆាបឆេះ រួមមាន ប្រេងឥន្ធនៈ ថ្នាំបាញ់ឱ្យភ្លឺ ទឹកថ្នាំសម្រាប់លាងសម្អាតពណ៌ថ្នាំ
- សារធាតុរឹងងាយឆាបឆេះ ដោយគ្រាន់តែមានប្រតិកម្មជាមួយទឹកបង្កើតបានជាឧស្ម័នឆាបឆេះជាភ្លើង
- សារធាតុអុកស៊ីតកម្មនិងថ្នាំពុលដែលមានសារធាតុស៊ីកាត់
- សារធាតុពុល រួមមាន ថ្នាំបំពុលសត្វល្អិត សមាសធាតុដែលមានបារ៉ត និងសារធាតុបង្ករោគឆ្លង
- ឧបករណ៍ សម្ភារៈ បរិក្ខារ និងសារធាតុមានជាតិវិទ្យុសកម្ម ព្រមទាំងសមាសភាពគីមីនៃអាតូមវិទ្យុសកម្ម និងឧបករណ៍ស្រង់ក្លិនផ្សេង
- សារធាតុស៊ីកាត់បង្កគ្រោះថ្នាក់ដល់ជាលិកាមនុស្សឬដល់គ្រឿងបង្គុំអាកាសយាន
- ឧបករណ៍ សម្ភារៈ បរិក្ខារ និងសារធាតុផ្សេងៗទៀត ដែលបង្កឱ្យមានហានិភ័យខ្ពស់ដល់ការដឹកជញ្ជូនតាមផ្លូវអាកាស។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលនិងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគ្រប់គ្រងនិងត្រួតពិនិត្យការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាស ដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល និងបទដ្ឋានបច្ចេកទេសស្តីពីសុវត្ថិភាពដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាសរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

ប្រតិបត្តិករដែលមានបំណងដឹកជញ្ជូនតាមផ្លូវអាកាសនូវទំនិញគ្រោះថ្នាក់ ដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវដាក់ពាក្យស្នើសុំមករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ស្របតាមបទប្បញ្ញត្តិជាធរមាន។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលនិងក្រសួង ស្ថាប័នពាក់ព័ន្ធ មានសិទ្ធិផ្តល់ការយល់ព្រម ឬដាក់លក្ខខណ្ឌបន្ថែម ឬបដិសេធចំពោះការស្នើសុំដែលមានចែងក្នុងកថាខណ្ឌទី៤នៃមាត្រានេះ។ ក្នុងករណីបដិសេធ ឬដាក់លក្ខខណ្ឌបន្ថែមលើពាក្យស្នើសុំ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលស្នើសុំអំពីមូលហេតុនៃការដាក់លក្ខខណ្ឌបន្ថែមឬការបដិសេធលើការស្នើសុំនេះ។

## ជំពូកទី១២
## អាកាសយានគ្មានមនុស្សបើកនិងការងារពីលើអាកាស

**មាត្រា៣១ .-** អាកាសយានគ្មានមនុស្សបើក

លើកលែងតែមានការអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងអនុវត្តស្របតាមកម្រិត [illegible]ទាំងឡាយនៃការអនុញ្ញាតដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល [illegible]នេះ៖

[illegible]ការឬធ្វើប្រតិបត្តិការហោះហើរអាកាសយានគ្មានមនុស្សបើកឬធ្វើប្រតិបត្តិការ [illegible]សយានបញ្ជាពីចម្ងាយ

- ថតរូប ឬបង្ហោះរូបភាព ឬរូបភាពវីដេអូ ឬប្រើឧបករណ៍ក្រាហ្វិកវីដេអូផ្សេងៗ ចេញពីអាកាសយានគ្មានមនុស្សបើក។

**មាត្រា៣២ .-** ការងារពីលើអាកាស

បុគ្គលគ្រប់រូបមិនត្រូវធ្វើសកម្មភាពការងារពីលើអាកាសឬធ្វើប្រតិបត្តិការអាជីវកម្មការងារពីលើអាកាស លើកលែងតែមានការអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលនិងអនុវត្តស្របតាមកម្រិតកំណត់និងលក្ខខណ្ឌទាំងឡាយនៃការអនុញ្ញាតដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

**មាត្រា៣៣ .-** ការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក

ការគ្រប់គ្រងអាកាសយានគ្មានមនុស្សបើក ត្រូវកំណត់ដោយច្បាប់ដោយឡែក។

## ជំពូកទី១៣
## គ្រឹះស្ថានបណ្តុះបណ្តាលវិស័យអាកាសចរណ៍ស៊ីវិល

**មាត្រា៣៤ .-** គ្រឹះស្ថានបណ្តុះបណ្តាលវិស័យអាកាសចរណ៍ស៊ីវិល

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចរៀបចំឬអនុញ្ញាតឱ្យវិនិយោគឯកជនបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិស័យអាកាសចរណ៍ស៊ីវិល។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យអាកាសចរណ៍ស៊ីវិល ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣៥ .-** សាលាបង្រៀនហោះហើរអាកាសយានស៊ីវិល

បុគ្គលគ្រប់រូបមិនត្រូវបង្កើតឬធ្វើប្រតិបត្តិការសាលាបង្រៀនហោះហើរអាកាសយានស៊ីវិលឬឧបករណ៍ហោះគ្រាប់ណាមួយទេ លើកលែងតែបុគ្គលនោះទទួលបានវិញ្ញាបនបត្រដែលមានសុពលភាពចេញដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលឬចេញដោយរដ្ឋភាគីកិច្ចសន្យាដទៃទៀតនិងទទួលស្គាល់សុពលភាពដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលជាធរមាន។

បែបបទនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណឬវិញ្ញាបនបត្រ និងការត្រួតពិនិត្យតាមដានសាលាបង្រៀនហោះហើរអាកាសយានស៊ីវិលឬឧបករណ៍ហោះគ្រាប់ ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

ដំណើរការផ្តល់អាជ្ញាបណ្ណឬវិញ្ញាបនបត្ររបស់សាលាបង្រៀនហោះហើរអាកាសយានស៊ីវិល ត្រូវផ្អែកលើលក្ខខណ្ឌ ជាពិសេសលក្ខខណ្ឌផ្តល់ការយល់ព្រមលើកម្មវិធីបង្រៀនពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៣៦ .-** សាលាបណ្តុះបណ្តាលថែទាំអាកាសយាន

បុគ្គលគ្រប់រូបមិនត្រូវបង្កើតឬធ្វើប្រតិបត្តិការសាលាបណ្តុះបណ្តាលថែទាំអាកាសយានណាមួយទេ លើកលែងតែបុគ្គលនោះទទួលបានវិញ្ញាបនបត្រ ដែលមានសុពលភាពផ្តល់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលឬចេញដោយរដ្ឋភាគីកិច្ចសន្យាដទៃទៀត និងទទួលស្គាល់សុពលភាពដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលជាធរមាន។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចផ្ដល់ការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់សាលាបណ្ដុះបណ្ដាលជំនាញជួសជុល ផ្លាស់ប្ដូរ ឬថែទាំបច្ចេកទេស និងរុះរើជួសជុលអាកាសយាន ឬម៉ាស៊ីនអាកាសយាន ឬកង្ហារ និងឧបករណ៍ដទៃទៀត ដោយយោងទៅលើភាពគ្រប់គ្រាន់នៃការហ្វឹកហាត់លើមុខវិជ្ជា ភាពសមស្រប និងលទ្ធភាពហោះហើរនៃគ្រឿងបរិក្ខារ និងសមត្ថភាពគ្រូបង្ហាត់។

បែបបទនិងនីតិវិធីនៃការផ្ដល់អាជ្ញាបណ្ណឬវិញ្ញាបនបត្រ និងការត្រួតពិនិត្យតាមដានសាលាបណ្ដុះបណ្ដាលថែទាំអាកាសយានស៊ីវិល ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

**មាត្រា៣៧ .-** ការផ្ដល់ឬទទួលស្គាល់សុពលភាពវិញ្ញាបនបត្រ

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចផ្ដល់វិញ្ញាបនបត្រ ឬទទួលស្គាល់សុពលភាពវិញ្ញាបនបត្រដែលផ្ដល់ដោយរដ្ឋភាគីកិច្ចសន្យាដទៃសម្រាប់គ្រឹះស្ថានបណ្ដុះបណ្ដាលវិស័យអាកាសចរណ៍ស៊ីវិលដែលប្រតិបត្តិការដោយនីតិបុគ្គលសាធារណៈឬនីតិបុគ្គលឯកជនណាមួយ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ទោះបីគ្រឹះស្ថានបណ្ដុះបណ្ដាលនោះមានទីតាំងនៅទីណាក៏ដោយ។

## ជំពូកទី១៤

## រោងចក្រផលិតអាកាសយាននិងអង្គភាពថែទាំអាកាសយាន

**មាត្រា៣៨ .-** រោងចក្រផលិតអាកាសយាននិងអង្គភាពថែទាំអាកាសយាន

បុគ្គលគ្រប់រូបមិនត្រូវបង្កើតឬធ្វើប្រតិបត្តិការរោងចក្រផលិត កែច្នៃ ថែទាំបច្ចេកទេស ឬស្ថានីយជួសជុលអាកាសយាន ម៉ាស៊ីនអាកាសយាន ឬកង្ហារ រួមទាំងគ្រឿងបន្លាស់ និងផ្នែកសំខាន់ៗផ្សេងទៀតរបស់អាកាសយានណាមួយទេ លើកលែងតែបុគ្គលនោះទទួលបានវិញ្ញាបនបត្រដែលមានសុពលភាពផ្ដល់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលឬផ្ដល់ដោយរដ្ឋភាគីកិច្ចសន្យាដទៃទៀតនិងទទួលស្គាល់សុពលភាពដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលជាធរមាន។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចផ្ដល់ការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់អង្គភាពថែទាំអាកាសយាន រោងជាងជួសជុល ផ្លាស់ប្ដូរ ថែទាំ និងរុះរើជួសជុលអាកាសយាន ម៉ាស៊ីនអាកាសយាន កង្ហារ និងឧបករណ៍ដទៃទៀត ដោយយោងតាមភាពគ្រប់គ្រាន់ ភាពសមស្របនៃគ្រឿងបរិក្ខារ បបនីយភណ្ឌ សម្ភារៈ និងវិធីសាស្ត្រនៃការជួសជុលឬរុះរើ និងសមត្ថភាពនៃបុគ្គលិកពាក់ព័ន្ធនឹងការងារឬដឹកនាំហ្វឹកហាត់។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចផ្ដល់វិញ្ញាបនបត្រ ឬទទួលស្គាល់សុពលភាពវិញ្ញាបនបត្រដែលចេញដោយរដ្ឋភាគីកិច្ចសន្យាដទៃ សម្រាប់អង្គភាពថែទាំអាកាសយានណាមួយ អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលជាធរមាន ទោះបីជាអង្គភាពនោះមានទីតាំងនៅទីណាក៏ដោយ។

## ជំពូកទី១៥

## អាកាសយានដ្ឋាន

**មាត្រា៣៩ .-** ការកំណត់ទីតាំង

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវកំណត់នូវតំបន់ទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលអាចប្រើប្រាស់ធ្វើជាអាកាសយានដ្ឋានស៊ីវិលឬដែលអាចប្រើប្រាស់ជាទីតាំងបណ្ដោះអាសន្ន សម្រាប់អាកាសយានស៊ីវិលសម្រាប់ចុះចត និងហោះឡើង។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចកំណត់ចំណាត់ថ្នាក់ផ្សេងៗនៃអាកាសយានដ្ឋាន ហើយអាចកំណត់អាកាសយានដ្ឋានមួយចំនួនជាអាកាសយានដ្ឋានអន្តរជាតិសម្រាប់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកនិងបរទេសធ្វើប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាសជាលក្ខណៈអន្តរជាតិ។

អាកាសយានស៊ីវិលទាំងអស់ត្រូវធ្វើប្រតិបត្តិការហោះហើរចេញឬចូលអាកាសយានដ្ឋានដែលបានកំណត់ ឬទីតាំងបណ្ដោះអាសន្នណាមួយកំណត់សម្រាប់ធ្វើការចុះចតនិងហោះឡើងរបស់អាកាសយានស៊ីវិល លើកលែងតែមានការកំណត់ដោយឡែកក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ឬមានការលើកលែងផ្ដល់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤០ .-** ការទទួលបានសិទ្ធិ

មានតែរាជរដ្ឋាភិបាលឬបុគ្គលដែលមានសញ្ជាតិខ្មែរ អាចធ្វើជាម្ចាស់អាកាសយានដ្ឋានបាន លើកលែងតែមានការកំណត់ផ្សេងដោយរាជរដ្ឋាភិបាល។

បុគ្គលគ្រប់រូបអាចធ្វើប្រតិបត្តិការឬគ្រប់គ្រងអាកាសយានដ្ឋានបានស្របតាមច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤១ .-** លក្ខខណ្ឌអាជ្ញាបណ្ណឬវិញ្ញាបនបត្រ

ការបង្កើតអាកាសយានដ្ឋានអន្តរជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការបង្កើតអាកាសយានដ្ឋានមូលដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បន្ទាប់ពីទទួលបានការឯកភាពពីរាជរដ្ឋាភិបាល។

ការធ្វើប្រតិបត្តិការ ការគ្រប់គ្រងអាកាសយានដ្ឋាន ការប្រើប្រាស់ចំណែកដីណាមួយធ្វើជាអាកាសយានដ្ឋាន ឬការពង្រីកអាកាសយានដ្ឋាន ត្រូវមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រដែលផ្ដល់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បន្ទាប់ពីទទួលបានការឯកភាពពីរាជរដ្ឋាភិបាល។

ក្នុងករណីអាកាសយានដ្ឋានខ្វះនូវមធ្យោបាយបច្ចេកទេសដើម្បីធានាសុវត្ថិភាពឬសន្តិសុខ ឬដោយមូលហេតុដទៃទៀតដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចកែប្រែ ព្យួរ ឬដកហូតអាជ្ញាបណ្ណឬវិញ្ញាបនបត្រអាកាសយានដ្ឋានបាន។

បែបបទនិងនីតិវិធីនៃការផ្ដល់ឬការកែប្រែអាជ្ញាបណ្ណឬវិញ្ញាបនបត្រ ដូចមានចែងក្នុងកថាខណ្ឌទី៣ ខាងលើនេះ ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

**មាត្រា៤២ .-** ភារកិច្ចរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលទាក់ទងនឹងអាកាសយានដ្ឋាន

ទាក់ទងនឹងអាកាសយានដ្ឋាន រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវ៖

- ផ្ដល់អាជ្ញាបណ្ណឬវិញ្ញាបនបត្រសម្រាប់អាកាសយានដ្ឋាន សេវាកម្មលើផ្ទៃដី និងសេវាកម្មគាំទ្រនានា
- អនុម័តយល់ព្រមនិងត្រួតពិនិត្យផែនការនិងកម្មវិធីអាកាសយានដ្ឋានដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល
- ត្រួតពិនិត្យលើកម្រិតដែលផែនការកែតម្រូវរចនាសម្ព័ន្ធអនុលោមតាមគោលនយោបាយរាជរដ្ឋាភិបាល ស្របតាមច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- កំណត់តម្លៃសេវាកម្មអាកាសយានដ្ឋានមូលដ្ឋាននិងអាកាសយានដ្ឋានអន្តរជាតិ ឬត្រួតពិនិត្យនិងផ្ដល់ការយល់ព្រមលើកម្រៃសេវាកម្មអាកាសយានដ្ឋានមូលដ្ឋាននិងអាកាសយានដ្ឋានអន្តរជាតិ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង។

## ជំពូកទី១៦
## កិច្ចគាំពារបរិស្ថាន

**មាត្រា៤៣ .-** កិច្ចគាំពារបរិស្ថាន

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចចេញបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលដែលមានស្តង់ដាអប្បបរមាសម្រាប់អនុវត្តចំពោះអាកាសយាន អាកាសយានដ្ឋាន និងវត្ថុទាំងឡាយដែលប្រើប្រាស់នៅក្នុងវិស័យអាកាសចរណ៍ស៊ីវិល ក្នុងគោលបំណងការពារបរិស្ថាន ដោយពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនិងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវពិគ្រោះយោបល់និងសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យកិច្ចការពារបរិស្ថាន ក្នុងវិស័យអាកាសចរណ៍ ដូចជាផែនការគ្រប់គ្រងបរិស្ថាន និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនូវបទប្បញ្ញត្តិទាំងឡាយណាដែលមានសុពលភាពនៅព្រះរាជាណាចក្រកម្ពុជាទាក់ទងទៅនឹងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលកើតចេញពី៖

- សំឡេងអាកាសយាន
- ការប៉ះពាល់គុណភាពបរិស្ថានដោយសារសំណល់រឹង សំណល់រាវ និងសំណល់គ្រោះថ្នាក់បង្កើតឡើងដោយអាកាសយាននិងអាកាសយានដ្ឋាន
- ការបំភាយឧស្ម័នចេញពីម៉ាស៊ីនអាកាសយាន
- ការបំភាយឧស្ម័នកាបូនិកពីអាកាសយាន
- ការទូទាត់ផលប៉ះពាល់បរិស្ថាននិងកាត់បន្ថយកាបូនក្នុងវិស័យអាកាសចរណ៍អន្តរជាតិ។

បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលធ្វើឡើងតាមច្បាប់នេះ បានដាក់លក្ខខណ្ឌលើសំឡេងនិងរំញ័រនិងការគ្រប់គ្រងសំណល់ផ្សេងៗទៀត ដែលបង្កឡើងដោយអាកាសយាននៅក្នុងឬជុំវិញបរិវេណអាកាសយានដ្ឋាន ហើយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលទាំងនោះត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

ប្រតិបត្តិករអាកាសយាន ត្រូវរៀបចំរបាយការណ៍អំពីការបំភាយឧស្ម័នកាបូនិកសម្រាប់ប្រតិបត្តិការជាអន្តរជាតិឱ្យបានទៀងទាត់ដូចបានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលមករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីពិនិត្យនិងរៀបចំរបាយការណ៍សរុបទៅកាន់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

គ្មានបុគ្គលណាមួយអាចបង្កើត ធ្វើប្រតិបត្តិការ ឬគ្រប់គ្រងអាកាសយានដ្ឋាន ឬប្រើប្រាស់ចំណែកដីណាមួយធ្វើជាអាកាសយានដ្ឋាន ឬពង្រីកអាកាសយានដ្ឋានបានទេ ប្រសិនបើពុំទាន់មានផែនការគ្រប់គ្រងបរិស្ថានដែលរួមមានប្រព័ន្ធគ្រប់គ្រងបរិស្ថាននិងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអនុលោមតាមច្បាប់ជាធរមាន និងផែនការគ្រប់គ្រងសត្វបង្កគ្រោះថ្នាក់ ព្រមទាំងការវាយតម្លៃហានិភ័យនៃសត្វបង្កគ្រោះថ្នាក់អនុលោមតាមអនុសញ្ញាស៊ីកាហ្គោ និងឧបសម្ព័ន្ធទាំងឡាយជាធរមាន។

## ជំពូកទី១៧
## ការគ្រប់គ្រងឧបសគ្គនិងសត្វបង្កគ្រោះថ្នាក់នៅតំបន់ជុំវិញអាកាសយានដ្ឋាន

**មាត្រា៤៤ .-** តួនាទីនិងការទទួលខុសត្រូវនៅតំបន់ជុំវិញអាកាសយានដ្ឋាន

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានតួនាទីនិងការទទួលខុសត្រូវនៅតំបន់ជុំវិញអាកាសយានដ្ឋាន ដូចខាងក្រោម៖

- ការកំណត់កម្ពស់ឧបសគ្គដែលជាការកំណត់កម្រិតកម្ពស់នៃវត្ថុទាំងឡាយដែលស្ថិតនៅក្នុងតំបន់ជុំវិញអាកាសយានដ្ឋាន ដើម្បីធានាមិនឱ្យមានឧបសគ្គដល់ការធ្វើប្រតិបត្តិការអាកាសយានប្រកបដោយសុវត្ថិភាព
- ការដាក់សញ្ញាសម្គាល់និងភ្លើងបំភ្លឺនៅលើផ្ទៃដីដែលមិនបម្រើឱ្យប្រតិបត្តិការអាកាសចរណ៍ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អាកាសយានកំពុងហោះហើរក្នុងតំបន់ជុំវិញអាកាសយានដ្ឋាននៅក្នុងសភាពងងឹតឬក្នុងស្ថានភាពមើលមិនច្បាស់
- ការអភិវឌ្ឍឡបបនីយកណ្ឌនិងប្រភពនានាដែលទាក់ទាញសត្វបង្កគ្រោះថ្នាក់នៅលើឬនៅក្នុងតំបន់ជុំវិញអាកាសយានដ្ឋាន ដើម្បីកាត់បន្ថយលទ្ធភាពដែលអាចកើតឡើងនូវការប៉ះទង្គិចរវាងសត្វបង្កគ្រោះថ្នាក់និងអាកាសយាន
- ការដាក់ឧបករណ៍ចំណាំងផ្លាតដែលបង្កការរំខានដល់អាកាសយានកំពុងហោះហើរឬការបញ្ជាចរាចរណ៍ផ្លូវអាកាសនៅក្នុងតំបន់ហោះហើរនិងក្នុងតំបន់ជុំវិញអាកាសយានដ្ឋាន។

តួនាទីនិងការទទួលខុសត្រូវដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ មិនអាចជំទាស់បានដោយតតិយជនរួមទាំងប្រតិបត្តិករអាកាសយានដ្ឋាន អាជ្ញាធរមានសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ហោះហើរនិងការប្រើប្រាស់ដីតំបន់ជុំវិញអាកាសយានដ្ឋាន។

**មាត្រា៤៥ .-** សេចក្តីប្រកាសស្តីពីតំបន់គ្រប់គ្រងនិងបញ្ញត្តិកម្មលើសំណង់ ភ្លើងបំភ្លឺ ឧបករណ៍ចំណាំងផ្លាត រុក្ខជាតិ និងប្រភពនានាដែលអាចទាក់ទាញសត្វបង្កគ្រោះថ្នាក់

ក្នុងករណីចាំបាច់ ដើម្បីធានាសុវត្ថិភាពដល់ប្រតិបត្តិការអាកាសយាននិងការនាំផ្លូវអាកាសនៅក្នុងតំបន់ជុំវិញអាកាសយានដ្ឋាន ឬដើម្បីធានាប្រសិទ្ធភាពប្រតិបត្តិការនៃឧបករណ៍នាំផ្លូវអាកាស ទោះបីជាស្ថិតនៅក្នុង ឬនៅតំបន់ជុំវិញអាកាសយានដ្ឋាន ឬតំបន់ណាមួយក៏ដោយ ត្រូវរក្សាកុំឱ្យមានឧបសគ្គឬជាប្រភពទាក់ទាញសត្វបង្កគ្រោះថ្នាក់ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចៈ

ក- កំណត់តំបន់អាកាសយានដ្ឋាន ដែលក្នុងនោះដាក់កំហិតឬហាមឃាត់សកម្មភាពនិងការប្រើប្រាស់ដីនៅក្នុងតំបន់ដែលមានព្រំខណ្ឌកំណត់ច្បាស់លាស់ និងដែលត្រូវប្រកាសជាតំបន់គ្រប់គ្រងអាកាសយានដ្ឋាន។

ខ- ហាមឃាត់ដាច់ខាតឬដោយមានលក្ខខណ្ឌ ឬធ្វើបញ្ញត្តិកម្មលើតំបន់គ្រប់គ្រងអាកាសយានដ្ឋានឬផ្នែកណាមួយនៃតំបន់នេះលើៈ

- ការសាងសង់សំណង់ណាមួយ ដែលខ្ពស់ជាងកម្រិតកម្ពស់កំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលជាធរមាន
- ការបំពាក់ភ្លើងបំភ្លឺដែលអាចបង្កគ្រោះថ្នាក់ដល់ប្រតិបត្តិការអាកាសយាន
- ការដាំដើមឈើឬរុក្ខជាតិដែលលូតកម្ពស់ខ្ពស់
- ការដំឡើងឬបង្កើតឬថែរក្សានូវប្រភពណាមួយដែលទាក់ទាញសត្វបង្កគ្រោះថ្នាក់
- ការបំពាក់ឧបករណ៍ចំណាំងផ្លាតដែលបង្កការរំខានដល់អាកាសយាននិងការបញ្ជាចរាចរណ៍ដែនអាកាសក្នុងអាកាសយានដ្ឋាន។

[illegible]មានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤៦ ._** សិទ្ធិអំណាចចូលទៅក្នុងតំបន់គ្រប់គ្រង

បុគ្គលណាមួយដែលអនុញ្ញាតដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងបុគ្គលដទៃទៀតដែលបំពេញភារកិច្ចក្នុងនាមរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលនិងក្រោមការឃ្លាំមើលរបស់បុគ្គលទទួលបានការអនុញ្ញាតនេះ អាចចូលទៅក្នុងតំបន់គ្រប់គ្រងដើម្បីវាស់វែងនិងពិនិត្យរយៈកម្ពស់ និងអាចធ្វើសកម្មភាពចាំបាច់នានាដើម្បីវាស់វែងនិងក្នុងគោលបំណងកំណត់សញ្ញាសម្គាល់ព្រំខណ្ឌតំបន់គ្រប់គ្រងឬផ្នែកណាមួយនៃតំបន់នោះ។

បុគ្គលដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ មិនត្រូវចូលក្នុងអគារឬសួនច្បារដែលមានរបងបិទជិតឬទីធ្លានៃអគារណាមួយដោយមិនមានការយល់ព្រមពីអ្នកកាន់កាប់នោះឡើយ លើកលែងតែបុគ្គលនោះបានជូនដំណឹងជាលាយលក្ខណ៍អក្សរច្បាស់លាស់យ៉ាងតិច៣(បី)ថ្ងៃមុន ទៅដល់អ្នកកាន់កាប់នោះ។

ក្នុងករណីមានការខូចខាតដល់ទ្រព្យសម្បត្តិ ដែលបណ្តាលមកពីការអនុវត្តសិទ្ធិអំណាចកំណត់ដោយមាត្រា៤៦នេះ ម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ត្រូវទទួលបានសំណងទៅតាមកម្រិតនៃការខូចខាតទ្រព្យសម្បត្តិរបស់ខ្លួន។

**មាត្រា៤៧ ._** ការជូនដំណឹងស្តីពីការដកចេញ កែសម្រួលសំណង់ ឬភ្លើងបំភ្លឺ ឧបករណ៍ចំណាំងផ្លាត ឬដើមឈើ ឬរុក្ខជាតិផ្សេងៗ និងប្រភពនានាដែលទាក់ទាញសត្វបង្កគ្រោះថ្នាក់ក្នុងតំបន់គ្រប់គ្រង

អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលដែលធ្វើឡើងតាមច្បាប់នេះ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬបុគ្គលគ្រប់រូបដែលទទួលបានការអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចតម្រូវឱ្យម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ដីតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ អនុវត្តវិធានការខាងក្រោម ក្នុងរយៈពេលកំណត់ក្នុងលិខិតជូនដំណឹងនោះ៖

ក- ដកចេញឬកាត់បន្ថយកម្ពស់៖

- សំណង់ណាមួយនៅលើដីដែលមានកម្ពស់ខ្ពស់ជាងកម្រិតកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល
- ភ្លើងបំភ្លឺណាមួយ
- ឧបករណ៍ចាំងផ្លាត
- ដើមឈើឬរុក្ខជាតិដែលមានកម្ពស់ខ្ពស់
- ប្រភពនានាដែលអាចទាក់ទាញសត្វបង្កគ្រោះថ្នាក់

ដែលត្រូវបានសាងសង់ បំពាក់ ដាំ ថែរក្សា មុនពេលឬក្រោយពេលបង្កើតបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ឬអនុវត្តផ្ទុយនឹងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលនេះ ឬរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលយល់ឃើញថាអាចបង្កជាឧបសគ្គដល់ប្រតិបត្តិការអាកាសយានឬឧបករណ៍នាំផ្លូវអាកាស។

ខ- ធ្វើការកែសម្រួលទៅលើដីនៅក្នុងតំបន់គ្រប់គ្រង ឬផ្នែកណាមួយនៃតំបន់គ្រប់គ្រង តាមការចាំបាច់ដើម្បី[illegible]លក្ខខណ្ឌតម្រូវដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលជាធរមាន។

គ- អនុវត្ត [illegible] ថែរក្សា ប្រតិបត្តិការ ជួសជុល និងកែសម្រួលសកម្មភាពការងារទាំងនេះតាមការចាំបាច់ជាស[illegible]ដើម្បីជៀសគ្រោះថ្នាក់ដល់អាកាសយានកំពុងហោះហើរក្នុងតំបន់ជុំវិញក្នុងស្ថានភាពងងឹតឬក្នុងស្ថានភាពមើលមិនច្បាស់ដោយសារវត្តមាននៃសំណង់ឬរុក្ខជាតិនៅក្នុងតំបន់ជុំវិញអាកាសយានដ្ឋាននោះ។

ក្នុងករណីខកខានមិនបានអនុវត្តស្របតាមខ្លឹមសារនៃសេចក្តីជូនដំណឹងក្នុងរយៈពេលកំណត់ បុគ្គលដែលទទួលបានការអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចចូលទៅក្នុងតំបន់នោះ និងតម្រូវឱ្យម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ដី ចាត់វិធានការស្របតាមការជូនដំណឹង ហើយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចទាមទារសំណងមកវិញលើការចំណាយទាំងអស់ឬមួយផ្នែកលើវិធានការចាំបាច់របស់ខ្លួនពីជនប្រព្រឹត្តកំហុស។

**មាត្រា៤៨ .-** ការជូនដំណឹងស្តីពីការយកចេញឬកែសម្រួលសំណង់ ភ្លើងបំភ្លឺ រុក្ខជាតិ និងប្រភពទាក់ទាញសត្វបង្កគ្រោះថ្នាក់ នៅក្រៅតំបន់គ្រប់គ្រង

រាល់ការសាងសង់សំណង់ថ្មីឬប្រភពណាមួយដែលអាចទាក់ទាញសត្វបង្កគ្រោះថ្នាក់ នៅខាងក្រៅតំបន់គ្រប់គ្រង ដែលមានកម្ពស់ឬលក្ខណៈដែលអាចបង្កជាឧបសគ្គឬគ្រោះថ្នាក់ដល់ប្រតិបត្តិការអាកាសយាន ត្រូវមានការអនុញ្ញាតពិសេស ដែលត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។ ក្នុងករណីមានការពាក់ព័ន្ធនឹងសមត្ថកិច្ចក្រសួង ស្ថាប័នផ្សេងទៀត ការផ្តល់ការអនុញ្ញាតពិសេសនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួង។

**មាត្រា៤៩ .-** ការខូចខាតបណ្តាលមកពីការកាត់បន្ថយឬការដកចេញ

ក្នុងករណីដែលសំណង់ ភ្លើងបំភ្លឺ ឧបករណ៍ចាំងផ្លាត ដើមឈើឬរុក្ខជាតិមានតម្លៃ ឬប្រភពណាមួយត្រូវបានកាត់បន្ថយកម្ពស់ឬត្រូវបានដកចេញឬចំណាយសមស្របផ្សេងៗកើតមានក្នុងការអនុលោមតាមសេចក្តីជូនដំណឹងឬលក្ខខណ្ឌនៃសេចក្តីជូនដំណឹង ដែលធ្វើឡើងក្រោមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលណាមួយ ម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ ត្រូវទទួលបានសំណងទៅតាមទំហំខូចខាតដែលបណ្តាលមកពីការកាត់បន្ថយឬការដកចេញនោះ លើកលែងតែសំណង់នោះត្រូវបានធ្វើឡើង ដើមឈើឬរុក្ខជាតិមានតម្លៃនោះត្រូវបានដាំ ឬប្រភពនោះត្រូវបានថែរក្សា ផ្ទុយនឹងការជូនដំណឹង លក្ខខណ្ឌនៃសេចក្តីជូនដំណឹង ឬបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលនោះ។

**មាត្រា៥០ .-** សំណង

បុគ្គលណាមួយដែលមានសិទ្ធិទទួលបានសំណងយោងតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ទំហំនៃសំណងត្រូវកំណត់ដោយកិច្ចព្រមព្រៀងឬដោយសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច។

## ជំពូកទី១៨

## សន្តិសុខអាកាសចរណ៍ស៊ីវិល

**មាត្រា៥១ .-** ការអនុវត្ត

ក្នុងករណីដែលច្បាប់នេះមិនមានចែង រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តនិងធានាតាមគោលការណ៍សន្តិសុខអាកាសចរណ៍ស៊ីវិលនិងផលប្រយោជន៍សាធារណៈ អនុលោមតាមច្បាប់ជាធរមានដែលពាក់ព័ន្ធនឹងសន្តិសុខអាកាសចរណ៍ស៊ីវិល និងដោយអនុលោមតាមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសន្តិសុខអាកាសចរណ៍ស៊ីវិល ដែលត្រូវបានផ្តល់សច្ចាប័នដោយព្រះរាជាណាចក្រកម្ពុជា។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចចេញបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលទាំងឡាយផ្សេងៗដែលចាំបាច់ដើម្បីអនុវត្តតម្រូវការនានាដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ។

**មាត្រា៥២ ._** សេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល

រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬបុគ្គលណាម្នាក់ដែលទទួលបានការអនុញ្ញាតឱ្យបំពេញភារកិច្ចធ្វើជាតំណាងរដ្ឋមន្ត្រី អាចចេញសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិលជាលាយលក្ខណ៍អក្សរដល់ប្រតិបត្តិករអាកាសយានណាមួយឬច្រើនដែលបានចុះបញ្ជីឬប្រតិបត្តិការហោះហើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រតិបត្តិករអាកាសយានដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យប្រតិបត្តិករអនុវត្ត ដូចខាងក្រោមនេះ៖

ក- មិនអនុញ្ញាតឬជួយសម្រួលឱ្យបុគ្គលណាម្នាក់ឬទ្រព្យសម្បត្តិណាមួយយកចូលទៅក្នុងអាកាសយាន និងមិនអនុញ្ញាតឬជួយសម្រួលឱ្យបុគ្គលណាម្នាក់ឬទ្រព្យសម្បត្តិណាមួយយកមកឬនាំយកមកក្នុងបរិវេណក្បែរអាកាសយានដែលកំណត់ដោយសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល។

ខ- មិនអនុញ្ញាតឬជួយសម្រួលឱ្យបុគ្គលណាម្នាក់ឬទ្រព្យសម្បត្តិណាមួយយកចូលទៅក្នុងអាកាសយានណាមួយពាក់ព័ន្ធនឹងសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិលឬមិនអនុញ្ញាត ឬជួយសម្រួលឱ្យបុគ្គលណាម្នាក់ឬទ្រព្យសម្បត្តិណាមួយយកមកឬនាំយកមកក្នុងបរិវេណក្បែរអាកាសយាន លើកលែងតែមានការត្រួតពិនិត្យនិងឆែកឆេរ ចំពោះបុគ្គលឬទ្រព្យសម្បត្តិនោះ ដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិលអនុវត្តដោយមន្ត្រីដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ។

គ- មិនអនុញ្ញាតឱ្យអាកាសយានហោះហើរ លើកលែងតែមានការត្រួតពិនិត្យនិងឆែកឆេរអាកាសយានដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិលអនុវត្តដោយមន្ត្រីដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ។

ប្រសិនបើសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល ដូចមានចែងក្នុងចំណុច(ខ)នៃកថាខណ្ឌទី១ខាងលើនេះ តម្រូវឱ្យត្រួតពិនិត្យនិងឆែកឆេរបុគ្គលណាម្នាក់ បុគ្គលនោះមិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងអាកាសយានឬតំបន់ហាមឃាត់ឡើយ លុះត្រាតែបុគ្គលនោះអនុញ្ញាតឱ្យមានការត្រួតពិនិត្យនិងឆែកឆេរតាមតម្រូវការនៃសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល ដែលបានតម្រូវចំពោះ៖

ក- បុគ្គលនោះ។

ខ- ទំនិញដែលបុគ្គលនោះមានបំណងយកឬបានយកទៅក្នុងអាកាសយាន ឬករណីដែលទំនិញរបស់បុគ្គលនោះបានយកឬបានដាក់ទៅក្នុងអាកាសយាន ឬបានយកចូលទៅក្នុងតំបន់ហាមឃាត់សន្តិសុខ។

បញ្ញត្តិដូចមានចែងក្នុងចំណុច(ខ)នៃកថាខណ្ឌទី១នៃមាត្រា៥២នេះ ប្រតិបត្តិករអាកាសយានណាមួយឬប្រតិបត្តិករផ្សេងទៀតដែលបានចុះបញ្ជីឬប្រតិបត្តិការហោះហើរក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវដឹកជញ្ជូនបុគ្គលណាម្នាក់ដែលពុំបានត្រួតពិនិត្យនិងឆែកឆេរជាមុនតាមសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិលឡើយ។

**មាត្រា៥៣ ._** បណ្តឹងតវ៉ា

មនុស្សដែលត្រូវបានបដិសេធមិនឱ្យដឹកជញ្ជូនតាមសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិលក្នុងចំណុច(ខ)នៃកថាខណ្ឌទី១នៃមាត្រា៥២នៃច្បាប់នេះ បុគ្គលនោះអាចដាក់ពាក្យប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃទទួលសេចក្តីបដិសេធមិនឱ្យមានការដឹកជញ្ជូន ដើម្បីពិនិត្យឡើងវិញនូវសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល។

រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវផ្តល់លទ្ធភាពឱ្យអ្នកដាក់ពាក្យប្តឹងតវ៉ាមានឱកាសសមស្របដើម្បីផ្តល់អំណះអំណាង។

រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវសម្រេចលើពាក្យប្តឹងតវ៉ាក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យប្តឹងតវ៉ា ហើយត្រូវជូនដំណឹងអំពីការសម្រេចលើបណ្តឹងតវ៉ាដល់អ្នកប្តឹង។ ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បុគ្គលនោះអាចប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងអំពីការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៥៤ .–** ការហាមឃាត់ការធ្វើដំណើរដោយមន្ត្រីសន្តិសុខអាកាសយានដ្ឋានឬមន្ត្រីមានសមត្ថកិច្ច

ក្នុងករណីដែលមន្ត្រីសន្តិសុខអាកាសយានដ្ឋានឬមន្ត្រីមានសមត្ថកិច្ច មានមូលហេតុសមស្របណាមួយដែលសង្ស័យថា បុគ្គលដែលបម្រុងឡើងលើអាកាសយាននៅក្នុងព្រះរាជាណាចក្រកម្ពុជាឬបុគ្គលនៅលើអាកាសយានមានបំណងប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ ឬរំលោភបំពានច្បាប់ដទៃទៀត មន្ត្រីសន្តិសុខអាកាសយានដ្ឋានឬមន្ត្រីមានសមត្ថកិច្ច អាចហាមឃាត់បុគ្គលនោះមិនឱ្យធ្វើដំណើរតាមអាកាសយាន ដោយៈ

ក- រារាំងបុគ្គលនោះមិនឱ្យឡើងអាកាសយាន ឬនាំបុគ្គលនោះចេញពីអាកាសយាន។

ខ- ចាប់ខ្លួនបុគ្គលនោះ រួចនាំទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ដើម្បីអនុវត្តនីតិវិធីបន្តស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

**មាត្រា៥៥ .–** ការសាកសួរបុគ្គលនៅអាកាសយានដ្ឋាន

បុគ្គលដែលផ្តល់ចម្លើយមិនពិតដោយចេតនាឬផ្តល់ចម្លើយមិនពិតដោយធ្វេសប្រហែសឬខ្ជីខ្ជា នៅពេលឆ្លើយសំណួរដែលទាក់ទងទៅនឹងកញ្ចប់អីវ៉ាន់ឬទំនិញ ឬសម្ភារៈផ្គត់ផ្គង់ផ្សេងៗ ដែលខ្លួនបម្រុងដឹកជញ្ជូនតាមអាកាសយានស៊ីវិលចុះបញ្ជីឬប្រតិបត្តិការហោះហើរក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅពេលឆ្លើយសំណួរដែលសួរដោយបុគ្គលដែលមានសិទ្ធិអនុញ្ញាតត្រឹមត្រូវតាមកថាខណ្ឌទី២នៃមាត្រា៥៥នេះ ត្រូវបានចាត់ទុកថាប្រព្រឹត្តបទល្មើស។

បុគ្គលដែលមានសិទ្ធិអនុញ្ញាត ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ មានដូចជាៈ

ក- ប្រតិបត្តិករអាកាសយានដ្ឋាន។

ខ- ប្រតិបត្តិករនៃអាកាសយានមួយឬច្រើនដែលបានចុះបញ្ជីឬប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គ- បុគ្គលដែលមានសិទ្ធិចូលទៅក្នុងតំបន់ហាមឃាត់នៃអាកាសយានដ្ឋាន ហើយមានសិទ្ធិគ្រប់គ្រងអីវ៉ាន់ ទំនិញ ឬសម្ភារៈផ្គត់ផ្គង់នៅក្នុងតំបន់ហាមឃាត់។

ឃ- មន្ត្រីសន្តិសុខអាកាសយានដ្ឋានឬមន្ត្រីមានសមត្ថកិច្ច។

ង- និយោជិតឬភ្នាក់ងារក្រុមហ៊ុនដែលបុគ្គលនោះបម្រើការដូចមានចែងក្នុងចំណុច(ក) (ខ) ឬ(គ) នៃកថាខណ្ឌទី២នៃមាត្រា៥៥នេះ។

**មាត្រា៥៦ .–** វត្តមានអ្នកគ្មានសិទ្ធិអនុញ្ញាតនៅក្នុងតំបន់ហាមឃាត់

បុគ្គលដែលគ្មានសិទ្ធិមិនត្រូវចូលដោយមានឬគ្មានមធ្យោបាយគ្រប់ប្រភេទទៅក្នុងតំបន់ហាមឃាត់នៅអាកាសយានដ្ឋាន ឬតំបន់គ្រឿងបំពាក់នាំផ្លូវអាកាសដែលមិនមែនជាផ្នែកនៃអាកាសយានដ្ឋាន លើកលែងតែមានការអនុញ្ញាតពីប្រតិបត្តិករអាកាសយានដ្ឋាន ប្រតិបត្តិករគ្រឿងបំពាក់នាំផ្លូវអាកាសឬប្រតិបត្តិករនាំផ្លូវអាកាស ឬរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលឬអ្នកតំណាង។

បុគ្គលគ្រប់រូបមិនត្រូវនៅក្នុងតំបន់ហាមឃាត់ បន្ទាប់ពីមន្ត្រីមានសមត្ថកិច្ច ប្រតិបត្តិករអាកាសយានដ្ឋាន ប្រតិបត្តិករគ្រឿងបំពាក់នាំផ្លូវអាកាសឬប្រតិបត្តិករនាំផ្លូវអាកាស ឬរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលឬអ្នកតំណាងស្នើសុំឱ្យចាកចេញ។

មន្ត្រីមានសមត្ថកិច្ចឬប្រតិបត្តិករអាកាសយានដ្ឋាន ប្រតិបត្តិករគ្រឿងបំពាក់នាំផ្លូវអាកាសឬប្រតិបត្តិករនាំផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលឬអ្នកតំណាង អាចប្រើប្រាស់កម្លាំងសមស្របដើម្បីបណ្តេញបុគ្គលដែលមិនអនុវត្តតាមសំណើ ក្នុងកថាខណ្ឌទី២ខាងលើនេះ។

## ជំពូកទី១៩
## ការដឹកជញ្ជូនតាមផ្លូវអាកាស

**មាត្រា៥៧ ._** បទប្បញ្ញត្តិបច្ចេកទេសសេដ្ឋកិច្ចអាកាសចរណ៍ស៊ីវិល

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវអនុវត្តតួនាទីរបស់ខ្លួនពាក់ព័ន្ធនឹងបទប្បញ្ញត្តិបច្ចេកទេសសេដ្ឋកិច្ចអាកាសចរណ៍ស៊ីវិល តាមរយៈ៖

- ការអភិវឌ្ឍដឹកជញ្ជូនតាមផ្លូវអាកាសនិងសេវាកម្មគាំទ្រ
- ការធានាការប្រកួតប្រជែងដោយស្មើភាពគ្នា
- ការលើកកម្ពស់ផ្នែកសេដ្ឋកិច្ច និងប្រសិទ្ធភាពក្នុងការដឹកជញ្ជូនតាមផ្លូវអាកាស និងសេវាកម្មគាំទ្រ
- ការធានាឱ្យមានសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិចេញ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា
- ការពង្រីកទំនាក់ទំនងអន្តរជាតិតាមរយៈការចូលរួមសន្និសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ជាលក្ខណៈទ្វេភាគីនិងពហុភាគី
- ការបែងចែកសិទ្ធិហោះហើរដឹកជញ្ជូនតាមផ្លូវអាកាស និងអនុញ្ញាតការហោះហើរគ្រប់សកម្មភាព រួមមានពាណិជ្ជកម្ម ការទូត រដ្ឋាភិបាល សង្គ្រោះបន្ទាន់ មនុស្សធម៌ និងហ្វឹកហ្វឺន
- ការគ្រប់គ្រងការបែងចែកស្លុតហោះហើរ ដល់គ្រប់ក្រុមហ៊ុនអាកាសចរណ៍
- ការការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់ឬអតិថិជន
- ការដោះស្រាយវិវាទដល់គ្រប់ភាគីពាក់ព័ន្ធដែលផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចពិចារណាបាននៅពេលដែលមានតម្រូវការឬតាមការស្នើសុំទាក់ទងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ដូចខាងក្រោម៖

- ពិនិត្យលទ្ធភាពនៃការរៀបចំកិច្ចព្រមព្រៀងនានាស្តីពីសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ
- ការធ្វើសេរីភាវូបនីយកម្មសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ជាលក្ខណៈទ្វេភាគីឬពហុភាគី
- ការអនុវត្តកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ
- ពិនិត្យលទ្ធភាពការធ្វើសេរីភាវូបនីយកម្មលើបទប្បញ្ញត្តិសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិដោយផ្អែកលើមូលដ្ឋានសិក្សាសេដ្ឋកិច្ច
- ត្រួតពិនិត្យតម្លៃសំបុត្រធ្វើដំណើរនិងតម្លៃសេវាកម្មដឹកជញ្ជូនផ្សេងៗទៀត ដើម្បីចៀសវាងការប្រកួតប្រជែងដោយមិនស្មោះត្រង់
- ធានាថាកម្រៃសេវាកម្មនៅតាមអាកាសយានដ្ឋានអន្តរជាតិនិងក្នុងស្រុក សេវាកម្មចរាចរណ៍ដែនអាកាស និងកម្រៃសេវាកម្មផ្សេងៗទៀត មិនមានភាពរើសអើងគ្រប់អ្នកប្រើប្រាស់សេវាកម្មឬក្រុមហ៊ុនប្រើប្រាស់សេវាកម្ម

- សិក្សានិងវាយតម្លៃកម្រៃសេវាកម្មនៅតាមបណ្តាអាកាសយានដ្ឋានអន្តរជាតិនិងក្នុងស្រុក សេវាកម្មចរាចរណ៍ដែនអាកាស និងកម្រៃសេវាកម្មផ្សេងៗទៀត ដោយឈរលើមូលដ្ឋានស្តង់ដាដែលកំណត់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៥៨ ._** វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសមិនអាចធ្វើប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ លុះត្រាតែមានវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាសដែលមានសុពលភាពនិងផ្តល់ឬទទួលស្គាល់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ប្រភេទ លក្ខខណ្ឌ ទម្រង់ និងនីតិវិធីក្នុងការផ្តល់ឬទទួលស្គាល់វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាសត្រូវកំណត់ដោយបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

មុនពេលផ្តល់ឬទទួលស្គាល់វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាសទៅឱ្យប្រតិបត្តិករអាកាសយាន រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

- ប្រតិបត្តិករអាកាសយាននោះត្រូវមានក្រមសីលធម៌និងធានាមានមូលដ្ឋានហិរញ្ញវត្ថុនិងបច្ចេកទេសគ្រប់គ្រាន់ដែលបញ្ជាក់ដោយនីតិបុគ្គលពាក់ព័ន្ធ
- ប្រតិបត្តិករអាកាសយាននោះមានបំណងបង្កើតសេវាកម្មខាងផ្នែកដឹកជញ្ជូនតាមផ្លូវអាកាស។

ក្នុងការផ្តល់វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវតែភ្ជាប់មកជាមួយនូវលក្ខខណ្ឌតម្រូវនិងការកំណត់ផ្សេងៗ ដែលគិតថាចាំបាច់ដល់ផលប្រយោជន៍សាធារណៈ។

ចំពោះប្រតិបត្តិករដែលកាន់វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាសត្រូវតែធានាថា រាល់ការជួសជុលនិងការថែទាំអាកាសយាន និងការធ្វើប្រតិបត្តិការហោះហើរក្នុងនាមជាសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវដំណើរការដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល គោលការណ៍ណែនាំ និងលក្ខខណ្ឌតម្រូវនានាដែលមានភ្ជាប់មកជាមួយវិញ្ញាបនបត្រ ហើយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវធ្វើការត្រួតពិនិត្យជាប្រចាំលើការអនុវត្តរបស់ប្រតិបត្តិករ។

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសនិងក្រុមហ៊ុនផ្តល់សេវាកម្មអាកាសចរណ៍ពាក់ព័ន្ធ ត្រូវទទួលយកជាអាទិភាពនូវបុគ្គលិកសញ្ជាតិខ្មែរដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ឱ្យចូលបម្រើការងារក្នុងសហគ្រាសនិងក្រុមហ៊ុនរបស់ខ្លួន។ ដោយឡែក ចំនួនបុគ្គលិកជំនាញឯកទេសអាកាសចរណ៍ស៊ីវិលបរទេស ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៥៩ ._** ប្រតិបត្តិករដឹកជញ្ជូនតាមផ្លូវអាកាសក្នុងស្រុកនិងអន្តរជាតិ

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវត្រួតពិនិត្យនិងវាយតម្លៃទៅលើសមត្ថភាពនិងគុណភាពប្រតិបត្តិករដឹកជញ្ជូនតាមផ្លូវអាកាសក្នុងស្រុក មុននឹងផ្តល់ការអនុញ្ញាតធ្វើប្រតិបត្តិការហោះហើរដើម្បីបម្រើផលប្រយោជន៍ជាសាធារណៈ ស្របតាមច្បាប់និងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលជាធរមាន។

សម្រាប់ប្រតិបត្តិករអាកាសចរណ៍ដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ៖

- ចំពោះដំណើរការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិដោយប្រតិបត្តិករក្នុងស្រុក រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវពិចារណានិងអនុវត្តតាមអនុសញ្ញាអន្តរជាតិនិងកិច្ចព្រមព្រៀងទ្វេភាគីឬពហុភាគីដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគី

- ទាក់ទងទៅនឹងការដឹកជញ្ជូនតាមផ្លូវអាកាសដោយប្រតិបត្តិករបរទេស រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចផ្តល់វិញ្ញាបនបត្រ ឬអនុម័តចំពោះការស្នើសុំជើងហោះហើរប្រតិបត្តិការចេញ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមអនុសញ្ញាអន្តរជាតិនិងកិច្ចព្រមព្រៀងទ្វេភាគីឬពហុភាគីដែលប្រទេសកម្ពុជា ជារដ្ឋភាគី។

**មាត្រា៦០ .-** ការកែសម្រួល ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានសិទ្ធិតម្រូវឱ្យនិងអនុវត្តចំពោះប្រតិបត្តិករអាកាសចរណ៍ដែលកាន់វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាសឱ្យបំពេញតាមបទប្បញ្ញត្តិបច្ចេកទេសសេដ្ឋកិច្ចអាកាសចរណ៍ស៊ីវិល និងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចណែនាំឱ្យប្រតិបត្តិករអាកាសចរណ៍ដែលកាន់វិញ្ញាបនបត្រឱ្យអនុវត្តតាមលក្ខខណ្ឌក្នុងរយៈពេលណាមួយដែលសម្រេចដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលដើម្បីធ្វើការកែសម្រួល ព្យួរ និងដកហូតវិញ្ញាបនបត្រមកវិញ បន្ទាប់ពីមានការជូនដំណឹងជាមុនដល់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ដែលសេចក្តីជូនដំណឹងមានបញ្ជាក់ហេតុផលលើសកម្មភាពដែលកើតមានឡើងឬក្នុងករណីបន្ទាន់។

ក្នុងករណីការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិដែលប្រតិបត្តិការដោយប្រតិបត្តិករអាកាសចរណ៍បរទេស រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលអាចព្យួរ ឬដកហូតវិញ្ញាបនបត្រឬការអនុញ្ញាតចំពោះប្រតិបត្តិករអាកាសចរណ៍បរទេសដែលមិនអនុវត្តស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគី និងការអនុវត្តតាមច្បាប់របស់ប្រទេសនៃប្រតិបត្តិករអាកាសចរណ៍បរទេសនោះ។

**មាត្រា៦១ .-** កម្រៃ

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសមិនអាចផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសបានទេ លើកលែងតែសហគ្រាសដឹកជញ្ជូននោះ បានកំណត់កម្រៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ដែលត្រូវប្រកាសជូនអតិថិជន។

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសដែលកំពុងដំណើរការការដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវគោរពតាមលក្ខខណ្ឌនៃការដឹកជញ្ជូនដែលមានការទទួលស្គាល់ពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងកម្រៃសេវាកម្មដែលបានផ្សព្វផ្សាយជាសាធារណៈ។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អាចព្យួរការកំណត់កម្រៃសេវាកម្មដឹកជញ្ជូន ប្រសិនបើរកឃើញថាកម្រៃសេវាកម្មនោះមិនមានតម្លាភាព មានការរើសអើង ឬផ្ទុយពីការបម្រើផលប្រយោជន៍សាធារណៈ។

លើកលែងតែមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសសេដ្ឋកិច្ចអាកាសចរណ៍ស៊ីវិល ឬកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសទ្វេភាគីឬពហុភាគី កម្រៃសេវាកម្មដែលស្នើឡើងដោយសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវជូនដំណឹងទៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលមុនពេលអនុវត្ត។

## ជំពូកទី២០
## ការទទួលខុសត្រូវនិងធានារ៉ាប់រង

**មាត្រា៦២ .-** សន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិដែលមានសុពលភាពផ្លូវច្បាប់

ក្នុងគ្រប់ករណីសិទ្ធិនិងការទទួលខុសត្រូវនានារបស់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស អ្នកដំណើរ អ្នកផ្ញើអីវ៉ាន់ អ្នកទទួលអីវ៉ាន់បញ្ញើ និងបុគ្គលផ្សេងៗទៀត ដែលជាប់ទាក់ទងទៅនឹងការដឹកជញ្ជូនតាមផ្លូវអាកាសផ្សេងៗជាមួយ ត្រូវអនុលោមតាមលក្ខខណ្ឌនិងបទប្បញ្ញត្តិអនុសញ្ញាម៉ុងរេអាល់ឆ្នាំ១៩៩៩ និងសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិនានាទាក់ទងនឹងការទទួលខុសត្រូវនិងការធានារ៉ាប់រងដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគី។

ការទទួលខុសត្រូវនិងការធានារ៉ាប់រងលើការខូចខាតដែលត្រូវសងពីសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដោយអនុលោមតាម អនុសញ្ញាម៉ុងរេអាល់ឆ្នាំ១៩៩៩ និងសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិនានាទាក់ទងនឹងការទទួលខុសត្រូវនិង ការធានារ៉ាប់រងដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគី។

**មាត្រា៦៣ ._** ការទូទាត់សំណងចំពោះអ្នកដំណើរតាមផ្លូវអាកាស ក្នុងការដឹកជញ្ជូនក្នុងស្រុក ដែលមិនស្ថិតក្រោម សន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសដែលធ្វើការដឹកជញ្ជូនក្នុងស្រុកតាមផ្លូវអាកាស ដែលមិនស្ថិតក្រោម សន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិនានាដូចមានចែងក្នុងមាត្រា៦២នៃច្បាប់នេះ ត្រូវទូទាត់សំណងចំពោះការខូចខាត នៅក្នុងព្រឹត្តិការណ៍ដែលបណ្តាលឱ្យបាត់បង់ជីវិត ឬរងរបួស និងក្នុងករណីគ្រោះថ្នាក់ដែលបណ្តាលឱ្យមានការ ខូចខាតនោះបានកើតឡើងនៅលើអាកាសយាន ឬដំណើរការនៃប្រតិបត្តិការណាមួយក្នុងពេលហោះឡើង ឬចុះ ចតអាកាសយាន។

ប្រសិនបើសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសមានភស្តុតាងបង្ហាញឱ្យឃើញថា ការខូចខាតបណ្តាល មកពីការធ្វេសប្រហែសរបស់ជនរងគ្រោះផ្ទាល់ នោះការទូទាត់សំណងត្រូវគិតទៅតាមកម្រិតកំហុសអ្នកដំណើរ។

ការទទួលខុសត្រូវនិងការធានារ៉ាប់រងលើការខូចខាតដែលត្រូវសងពីសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ពាក្យ គ្រោះថ្នាក់ ដែលប្រើក្នុងមាត្រា៦៣នេះ សំដៅដល់ព្រឹត្តិការណ៍ដែលមិនអាចស្មានដឹងជាមុនបានឬ កើតឡើងពីកត្តាខាងក្រៅដល់អ្នកដំណើរតាមផ្លូវអាកាស ហើយមិនបានរួមបញ្ចូលការរងរបួសដែលបណ្តាលមក ពីសកម្មភាពរបស់អ្នកដំណើរខ្លួនឯងផ្ទាល់ នៅពេលដែលមានដំណើរការអាកាសយានជាប្រក្រតី និងតាម ការរំពឹងទុក។

**មាត្រា៦៤ ._** ការទូទាត់សំណងចំពោះអីវ៉ាន់និងទំនិញ

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសដែលធ្វើការដឹកជញ្ជូននៅក្នុងស្រុកតាមផ្លូវអាកាសដែលមិនស្ថិត ក្រោមសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិនានា ដូចមានចែងក្នុងមាត្រា៦២នៃច្បាប់នេះ ត្រូវទូទាត់សំណងចំពោះ ការខូចខាតនៅក្នុងព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានការបំផ្លាញ ការបាត់បង់ ឬការខូចខាតអីវ៉ាន់ផ្ញើឬទំនិញ ក្នុង ករណី បាតុភាពនោះបានបង្កឱ្យមានការខូចខាតស្ថិតនៅក្នុងកំឡុងពេលដឹកជញ្ជូនតាមផ្លូវអាកាស។

ការដឹកជញ្ជូនតាមផ្លូវអាកាស ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ កំឡុងពេលដឹកជញ្ជូនអីវ៉ាន់ ឬទំនិញ គឺជាបន្ទុករបស់សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ទោះបីក្នុងអាកាសយាន ឬក្នុងអាកាសយានដ្ឋាន ឬក្នុងករណីចុះចតក្រៅអាកាសយានដ្ឋាន ឬកន្លែងផ្សេងក៏ដោយ។

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសមិនទទួលខុសត្រូវចំពោះការទូទាត់សំណង លើការខូចខាតចំពោះ អីវ៉ាន់ឬទំនិញទាំងឡាយណា នៅពេលដែលបានកើតឡើងក្នុងករណី ដូចខាងក្រោម៖

- ដោយលក្ខណៈដើមរបស់អីវ៉ាន់ សម្ភារៈឬទំនិញ ឬការធ្វេសប្រហែស ឬការខ្វះចន្លោះ
- ដោយការវេចខ្ចប់មិនមានលក្ខណៈត្រឹមត្រូវ
- ដោយកំហុសឬធ្វេសប្រហែសរបស់អ្នកដំណើរ អ្នកផ្ញើ អ្នកទទួលបញ្ញើ ឬភ្នាក់ងារណាមួយដែលជាតំណាងឱ្យ ម្ចាស់ទំនិញ
- ដោយសកម្មភាពរបស់អាជ្ញាធរមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល
- ដោយសង្គ្រាមឬជម្លោះប្រដាប់អាវុធ។

ការទទួលខុសត្រូវនិងការធានារ៉ាប់រងលើការខូចខាតដែលត្រូវសងពីសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៦៥ .-** ការទូទាត់សំណងដោយសារការពន្យារពេលក្នុងការដឹកជញ្ជូនក្នុងស្រុក

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសដែលធ្វើការដឹកជញ្ជូននៅក្នុងស្រុក ដែលមិនស្ថិតក្រោមសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិនានា ដូចមានចែងក្នុងមាត្រា៦២នៃច្បាប់នេះ ត្រូវទូទាត់សំណងចំពោះការខូចខាតដែលបណ្តាលមកពីការពន្យារពេលក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសលើអ្នកដំណើរ ឬអីវ៉ាន់ ឬទំនិញ។

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសមិនទទួលខុសត្រូវទូទាត់សំណងទេ ប្រសិនបើមានភស្តុតាងបង្ហាញថា សហគ្រាសនិងភ្នាក់ងាររបស់ខ្លួនបានចាត់វិធានការដើម្បីជៀសវាងការខូចខាត ឬជាកត្តាពុំអាចចាត់វិធានការបាន ទោះបីមានការខិតខំប្រឹងប្រែងក៏ដោយ។

ការទទួលខុសត្រូវនិងការធានារ៉ាប់រងលើការខូចខាតដែលត្រូវសងពីសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៦៦ .-** ការធានារ៉ាប់រង

សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសដែលមានវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស ត្រូវមានធានារ៉ាប់រងលើសំណងសម្រាប់ការខូចខាតដល់តតិយជន និងការខូចខាតដល់អ្នកដំណើរ អីវ៉ាន់ និងទំនិញដែលខ្លួនបានដឹកជញ្ជូន និងគោលបំណងដទៃទៀតដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល មានសិទ្ធិឃាត់អាកាសយាន ឬមានសិទ្ធិដកហូត ឬព្យួរវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស ឬដាក់ទណ្ឌកម្មចំពោះសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសដែលមិនមានធានារ៉ាប់រង ឬធានារ៉ាប់រងមិនគ្រប់លក្ខណៈ ជាមួយចំនួនទឹកប្រាក់ធានាអប្បបរមាដែលកំណត់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

## ជំពូកទី២១
## អធិការកិច្ចអាកាសចរណ៍ស៊ីវិល

**មាត្រា៦៧ .-** ការតែងតាំងមន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល

រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវតែងតាំងមន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល ដែលជាមន្ត្រីរាជការក្របខ័ណ្ឌរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលឬបុគ្គលណាម្នាក់ដែលមិនមែនជាមន្ត្រីរាជការក្របខ័ណ្ឌរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីចុះតាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ។ លក្ខខណ្ឌនិងនីតិវិធីនៃការតែងតាំងមន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

មានតែមន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលដែលត្រូវបានតែងតាំងចេញពីមន្ត្រីរាជការក្របខ័ណ្ឌរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលតែប៉ុណ្ណោះ ទើបអាចទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌និងបែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលត្រូវស្លៀកពាក់ឯកសណ្ឋាន ដែលមានសញ្ញាសម្គាល់ និងសញ្ញាស័ក្តិ ព្រមទាំងមានបណ្ណសម្គាល់ខ្លួន និងត្រូវមានលិខិតបញ្ជាបេសកកម្ម។ ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាស័ក្តិរបស់មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល ត្រូវកំណត់ដោយអនុក្រឹត្យ។ ការប្រើប្រាស់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាស័ក្តិរបស់មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល មានសិទ្ធិស្នើសុំជំនួយនិងកិច្ចសហការពីក្រសួង ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរដែនដីគ្រប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ដើម្បីចូលរួមទប់ស្កាត់និងបង្ក្រាបបទល្មើស ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ តាមការចាំបាច់។

**មាត្រា៦៨ .- សិទ្ធិនិងភារកិច្ចរបស់មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល**

ក្នុងការអនុវត្តសិទ្ធិនិងភារកិច្ចរបស់ខ្លួន មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល អាចអន្តរាគមន៍ដោយផ្ទាល់ ជាមួយរូបវន្តបុគ្គល នីតិបុគ្គល អង្គភាពនានា សហគ្រាសឯកជននិងសាធារណៈ ដែលស្ថិតក្រោមការត្រួតពិនិត្យ តាមដានរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល មានសិទ្ធិនិងភារកិច្ច ដូចខាងក្រោម៖

ក- អនុវត្តការចុះត្រួតពិនិត្យឃ្លាំមើល ការធ្វើអធិការកិច្ច ការធ្វើអធិការកិច្ចឡើងវិញ ឬធ្វើសវនកម្មទៅតាមផែនការកំណត់ ឬធ្វើដោយឥតគ្រោងទុក ឬធ្វើជាប្រចាំចំពោះ៖

- បុគ្គលដែលកាន់ឯកសារអាកាសចរណ៍
- បុគ្គលដែលធ្វើប្រតិបត្តិការ ឬថែទាំបច្ចេកទេស ឬធ្វើសេវាកម្ម ឬធ្វើសកម្មភាពដទៃទៀតដែលពាក់ព័ន្ធនឹងអាកាសយានឬផលិតផលអាកាសចរណ៍ អង្គភាពអនុវត្តភារកិច្ចនិងសេវាកម្មដែលទាក់ទងនឹងវិស័យអាកាសចរណ៍ ឬអ្នកផ្តល់សេវាកម្មគាំទ្រផ្នែកអាកាសចរណ៍
- ទីកន្លែងឬវត្ថុស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ការអនុវត្តការងារខាងលើនេះអាចធ្វើឡើងនៅមុនពេលនិងក្រោយពេលចេញឯកសារអាកាសចរណ៍ ដែលមានជាអាទិ៍អាកាសយានដ្ឋាន រោងថែទាំ បច្ចេកទេសអាកាសយាន ឋបនីយកណ្តាលបញ្ជាចរាចរណ៍ផ្លូវអាកាស អាកាសយាន ឋបនីយកណ្តាលនានា ទីស្នាក់ការកណ្តាល ការិយាល័យ និងទីសំចតរបស់ប្រតិបត្តិករអាកាសយាន ស្ថានីយប្រេងឥន្ធនៈ អាកាសចរណ៍ ទីតាំងចំណតអាកាសយាន គ្រឿងបរិក្ខារបម្រើនៅលើផ្ទៃដី តំបន់ឃ្លាំងស្តុកទំនិញ អង្គភាពថែទាំបច្ចេកទេសអាកាសយាន អង្គភាពបណ្តុះបណ្តាល អាកាសចរណ៍ និងអង្គភាពនានាចំណុះរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដែលជាអ្នកផ្តល់សេវាកម្មអាកាសចរណ៍។

ខ- ស្នើសុំនិងផ្តល់ជូនតាមការស្នើសុំ ដើម្បីពិនិត្យឬផលិតឡើងវិញ នូវឯកសារនានាឬទិន្នន័យកុំព្យូទ័រ ក្នុងទម្រង់ជាឯកសារបោះពុម្ពឬក្នុងទម្រង់ផ្សេងៗទៀត ដើម្បីធ្វើការពិនិត្យឬផលិតឡើងវិញ ដែលមានផ្ទុកនូវព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តច្បាប់នេះ មានជាអាទិ៍កម្មវិធីបណ្តុះបណ្តាល កម្មវិធីជ្រើសរើសមន្ត្រីឬបុគ្គលិក និងគុណវុឌ្ឍិ របាយការណ៍ប្រតិបត្តិការ តារាងសមតុល្យសារពើពន្ធសម្រាប់ឆ្នាំសារពើពន្ធចាស់និងបច្ចុប្បន្ននិងថវិកា។

គ- ស្នើឱ្យគ្រប់ប្រតិបត្តិករនិងបុគ្គលពាក់ព័ន្ធវិស័យអាកាសចរណ៍ស៊ីវិលដែលស្ថិតក្រោមច្បាប់នេះ ផ្តល់ឬបង្ហាញសៀវភៅចុះបញ្ជី និងឯកសារដែលពាក់ព័ន្ធនឹងរូបវន្តបុគ្គលឬនីតិបុគ្គលនោះ ទៅតាមកាលបរិច្ឆេទ ពេលវេលានិងនៅទីកន្លែង ដូចបាន បញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ហើយឯកសារពាក់ព័ន្ធដទៃនោះ ត្រូវរក្សាទុកនៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ឃ- ចាត់វិធានការបង្ការទុកជាមុន ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសុវត្ថិភាព ដែលបានរកឃើញទាក់ទងនឹងការថែទាំបច្ចេកទេសអាកាសយាន ប្រតិបត្តិការបច្ចេកទេស អាជ្ញាបណ្ណ និងការបណ្តុះបណ្តាលបុគ្គលិកអាកាសចរណ៍ស៊ីវិល ការហោះហើរ និងការទទួលខុសត្រូវដទៃទៀតរបស់ប្រតិបត្តិករអាកាសចរណ៍ រួមទាំងសកម្មភាពនានារបស់បុគ្គលិករបស់ប្រតិបត្តិករអាកាសចរណ៍។

ង- ចាត់វិធានការបង្ការទុកជាមុន ដើម្បីដោះស្រាយចំណុចខ្វះខាតនានា ក្នុងការថែទាំហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន និងឧបករណ៍នាំផ្លូវអាកាសនៅលើផ្ទៃដី ក្នុងដែនដីទាំងមូលដែលស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ច- ហាមឃាត់ប្រតិបត្តិករនិងបុគ្គលពាក់ព័ន្ធវិស័យអាកាសចរណ៍ស៊ីវិលដែលស្ថិតក្រោមច្បាប់នេះ ក្នុងការអនុវត្តបុព្វសិទ្ធិនៃឯកសារអាកាសចរណ៍ មានជាអាទិ៍អាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬឯកសារផ្សេងៗទៀត ដោយផ្អែកលើហេតុផលត្រឹមត្រូវ។

ឆ- ចូលទៅកាន់អាកាសយាន រួមទាំងបន្ទប់អាកាសយានិកនិងក្រុមហោះ ក្នុងពេលកំពុងហោះហើរ និងឋបនីយកណ្ឌអាកាសចរណ៍ មានជាអាទិ៍អាកាសយានដ្ឋាន អង្គភាពថែទាំបច្ចេកទេសអាកាសយាន និងឋបនីយកណ្ឌបញ្ជាចរាចរណ៍ផ្លូវអាកាស អាកាសយានឋបនីយកណ្ឌនានា ទីស្នាក់ការកណ្តាល ការិយាល័យ និងទីសំចតរបស់ប្រតិបត្តិករអាកាសយាន ស្ថានីយប្រេងឥន្ធនៈអាកាសចរណ៍ ទីតាំងសំចតអាកាសយាន គ្រឿងបរិក្ខារបម្រើនៅលើផ្ទៃដី តំបន់ឃ្លាំងស្តុកទំនិញ អង្គភាពថែទាំបច្ចេកទេសអាកាសយាន អង្គភាពបណ្តុះបណ្តាលអាកាសចរណ៍ និងអង្គភាពនានាចំណុះរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលដែលជាអ្នកផ្តល់សេវាកម្មអាកាសចរណ៍ ដោយមិនមានការរារាំងនិងមិនមានការដាក់កម្រិតកំណត់។

ជ- ក្នុងករណីពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមផ្លូវអាកាសៈ

- ត្រួតពិនិត្យអ្នកកាន់វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស អាចធានានូវការអនុវត្តលក្ខខណ្ឌវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស ដូចជាសុវត្ថិភាព សន្តិសុខ និងប្រសិទ្ធភាពនៃការហោះហើរ សមត្ថភាព ទម្រង់បែបបទ និងប្រក្រតីភាពនៃសេវាកម្មអ្នកដំណើរ និងដឹកទំនិញដែលស្របទៅតាមការអនុញ្ញាតហោះហើរ
- ត្រួតពិនិត្យកិច្ចព្រមព្រៀងរវាងអ្នកកាន់វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស និងអ្នកផ្តល់សេវាកម្មគាំទ្រអាកាសចរណ៍ និងសេវាកម្មផ្សេងទៀតដែលផ្តល់ដោយអ្នកផ្តល់សេវាកម្មគាំទ្រអាកាសចរណ៍
- ត្រួតពិនិត្យលើការអនុវត្តកម្រៃសេវាកម្ម រួមទាំងការរំលោភបំពានលើការប្រកួតប្រជែងដោយយុត្តិធម៌ ការគោរពកិច្ចព្រមព្រៀងអន្តរជាតិឬទ្វេភាគី
- ធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុនិងគុណភាពសេវាកម្ម។

បន្ទាប់ពីការធ្វើអធិការកិច្ចរួច មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលត្រូវៈ

- បញ្ជូនរបាយការណ៍ស្តីពីអនុលោមភាពទៅនឹងបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលនៃច្បាប់នេះ ទៅថ្នាក់លើរបស់ខ្លួនជាបន្ទាន់ និងទៅបុគ្គលឬប្រតិបត្តិករនៃវត្ថុដែលត្រូវធ្វើអធិការកិច្ច
- បង្ហាញជូនបុគ្គលឬប្រតិបត្តិករនៃកម្មវត្ថុស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួន នូវបញ្ហានានាដែលតម្រូវឱ្យអនុវត្តជាក់លាក់តាមទម្រង់ណាមួយឬហាមឃាត់នូវអំពើមួយចំនួនឬផ្តល់យោបល់ប្រឹក្សា ដើម្បីធានាអនុលោមភាព

- បញ្ជូនរបាយការណ៍ទៅថ្នាក់លើរបស់ខ្លួនជាបន្ទាន់អំពីអង្គហេតុដែលខ្លួនយល់ថាល្មើសនឹងច្បាប់នេះ និងអនុសញ្ញាអន្តរជាតិជាប់ទាក់ទងនឹងអាកាសចរណ៍ស៊ីវិលដែលព្រះរាជាណាចក្រកម្ពុជាជាភាគី និងដើម្បីផ្តល់ជូនអនុសាសន៍។

បែបបទនិងនីតិវិធីលម្អិតនៃការធ្វើអធិការកិច្ចអាកាសចរណ៍ស៊ីវិល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៦៩ .-** សិទ្ធិនិងភារកិច្ចរបស់មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌

ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ មានសិទ្ធិនិងភារកិច្ច ដូចខាងក្រោម៖

ក- ឆែកឆេរទីកន្លែងឬវត្ថុណាមួយដែលសង្ស័យថាមានពាក់ព័ន្ធនឹងបទល្មើស។

ខ- ចាប់យកវត្ថុតាង ដែលសង្ស័យថាពាក់ព័ន្ធនឹងបទល្មើស រួមទាំងទិន្នន័យកុំព្យូទ័រ ឧបករណ៍ផ្ទុកទិន្នន័យ ឬសំណៅចម្លងនៃទិន្នន័យនោះ ហើយត្រូវធ្វើបញ្ជីសារពើភណ្ឌវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាង និងគ្រប់ឯកសារទាំងអស់ដែលត្រូវបានចាប់យក។ ក្នុងករណីជួបការលំបាកក្នុងការអនុវត្ត ត្រូវសុំការណែនាំពីព្រះរាជអាជ្ញា។

គ- ឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស និងបុគ្គលដែលអាចផ្តល់ព័ត៌មានអំពីអង្គហេតុពាក់ព័ន្ធនឹងបទល្មើសដើម្បីធ្វើការសាកសួរនិងអនុវត្តនីតិវិធីបន្ត។

ឃ- អនុវត្តការពិន័យអន្តរការណ៍ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ង- ចាត់វិធានការផ្សេងទៀត នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តនៃច្បាប់នេះ។

ទម្រង់បែបបទនៃការធ្វើកំណត់ហេតុបទល្មើសអាកាសចរណ៍ស៊ីវិល ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**មាត្រា៧០ .-** វិធានការចំពោះករណីដែលអាកាសយាននិងផលិតផលអាកាសចរណ៍អាចបង្កគ្រោះថ្នាក់

មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវចាត់វិធានការចាំបាច់បន្ទាន់ ដើម្បីបង្ការគ្រោះថ្នាក់ដល់មនុស្ស ឬទ្រព្យសម្បត្តិ ក្នុងករណីពិនិត្យឃើញថា ប្រតិបត្តិការ ឬការប្រើប្រាស់អាកាសយាន ឬផលិតផលអាកាសចរណ៍ ឬប្រភេទអាកាសយាន ឬផលិតផលអាកាសចរណ៍ណាមួយអាចបង្កគ្រោះថ្នាក់ ដូចខាងក្រោម៖

ក- អាកាសយានអាចមិនមានលទ្ធភាពហោះហើរ។

ខ- ក្រុមអាកាសយានិក អាចមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬអសមត្ថភាពកាយសម្បទា ឬបញ្ញាស្មារតី ក្នុងការប្រតិបត្តិការការហោះហើរ។

គ- ប្រតិបត្តិការអាចបង្កឱ្យមានគ្រោះថ្នាក់ជាក់ស្តែងដល់មនុស្សនៅក្នុងអាកាសយាន ឬមនុស្សដទៃទៀត ឬទ្រព្យសម្បត្តិនៅលើផ្ទៃដី។

ឃ- ការអនុវត្តផ្ទុយ ឬអាចនឹងអនុវត្តផ្ទុយនៃច្បាប់នេះ បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល វិធានស្តង់ដារ គោលការណ៍ណែនាំ និងនីតិវិធីដែលអនុវត្តចំពោះអាកាសយាននោះ។

ក្នុងករណីណាមួយដូចមានរៀបរាប់ខាងលើ មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ អាចចាត់វិធានការ ដូចខាងក្រោម៖

- ហាមឃាត់ ឬដាក់លក្ខខណ្ឌទៅលើប្រតិបត្តិការរបស់អាកាសយានឬប្រភេទនៃអាកាសយាននោះ

- ហាមឃាត់ឬដាក់លក្ខខណ្ឌចំពោះការប្រើប្រាស់ផលិតផលអាកាសចរណ៍ ឬប្រភេទនៃផលិតផលអាកាសចរណ៍នោះ
- ឃាត់ទុកអាកាសយានណាមួយ ឬផលិតផលអាកាសចរណ៍ណាមួយ ដើម្បីអនុវត្តនីតិវិធីបន្ត។

ការចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើនេះ ត្រូវធ្វើឡើងសម្រាប់តែរយៈពេលចាំបាច់ និងជាប្រយោជន៍ចំពោះសុវត្ថិភាព ព្រមទាំងបម្រើដល់ការស៊ើបអង្កេតតែប៉ុណ្ណោះ។

ប្រសិនបើមានសំណើពីម្ចាស់ឬបុគ្គលទទួលបន្ទុកអាកាសយាន ឬផលិតផលអាកាសចរណ៍ មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវជូនដំណឹងស្តីពីមូលហេតុនៃការចាត់វិធានការខាងលើជាលាយលក្ខណ៍អក្សរដល់ម្ចាស់ ឬបុគ្គលទទួលបន្ទុកអាកាសយាន ឬផលិតផលអាកាសចរណ៍នោះ។

ដើម្បីធានាដល់ការអនុវត្តមាត្រានេះ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវជូនដំណឹងអំពីការចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើនេះ ទៅបុគ្គលពាក់ព័ន្ធដែលចាំបាច់ តាមគ្រប់មធ្យោបាយ។

## ជំពូកទី២២
## ទោសប្បញ្ញត្តិ

**មាត្រា៧១ .-** ទណ្ឌកម្ម

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមានទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

**មាត្រា៧២ .-** ទណ្ឌកម្មរដ្ឋបាល

ទណ្ឌកម្មរដ្ឋបាល រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាកសកម្មភាពពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការអាកាសចរណ៍ស៊ីវិលជាបណ្តោះអាសន្ន រួមទាំងការផ្អាកអាកាសយានមិនឱ្យហោះហើរជាបណ្តោះអាសន្ន
- ការតម្រូវឱ្យមានការប្រឡង ការធ្វើតេស្ត និងការបណ្តុះបណ្តាលឡើងវិញ
- ការផ្លាស់ប្តូរ ការព្យួរ ឬការដកហូតជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍នូវអាជ្ញាបណ្ណឬវិញ្ញាបនបត្ររបស់បុគ្គលណាមួយ ដែលត្រូវបានផ្តល់ឱ្យដោយអនុលោមតាមច្បាប់នេះ។

អំពើដែលត្រូវរងទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

បែបបទនិងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចអំពីទណ្ឌកម្មរដ្ឋបាល ក្រៅពីការព្រមានជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេច។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលលើពាក្យប្តឹង ក៏មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។ ការដាក់ពាក្យប្តឹងតវ៉ារបស់បុគ្គលខាងលើ មិនមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចអំពីទណ្ឌកម្មរដ្ឋបាលនោះទេ។

**មាត្រា៧៣ .–** ទណ្ឌកម្មព្រហ្មទណ្ឌ

ទណ្ឌកម្មព្រហ្មទណ្ឌ រួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

បទល្មើសដែលត្រូវពិន័យអន្តរការណ៍ស្របតាមច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យបណ្តឹងអាជ្ញារលត់។ ការបង់ប្រាក់ពិន័យអន្តរការណ៍មិនមែនជាឧបសគ្គដល់ការអនុវត្តទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងច្បាប់ព្រហ្មទណ្ឌជាធរមានផ្សេងទៀតឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងនៃបទល្មើស ហើយបញ្ជូនទៅតុលាការតាមនីតិវិធី។

បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

រាជរដ្ឋាភិបាល អាចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងការបង្ក្រាបបទល្មើស ដូចមានចែងនៅក្នុងច្បាប់នេះ។

**មាត្រា៧៤ .–** ទណ្ឌកម្មលើមន្ត្រី

មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិលឬមន្ត្រីមានសមត្ថកិច្ចដែលអនុវត្តបំពានបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀតក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ត្រូវទទួលខុសត្រូវផ្នែករដ្ឋបាលនេះស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ការទទួលខុសត្រូវផ្នែករដ្ឋបាលមិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់ ការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតឡើយ។

**មាត្រា៧៥ .–** ការមិនចុះបញ្ជីឬមិនបំពាក់សញ្ញាសម្គាល់សញ្ជាតិនិងសញ្ញាចុះបញ្ជីអាកាសយាន

ជនណាដែលធ្វើប្រតិបត្តិការហោះហើរអាកាសយាននៅក្នុងឬឆ្លងកាត់ដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនបានចុះបញ្ជីអាកាសយាន ឬមិនបានបំពាក់សញ្ញាសម្គាល់សញ្ជាតិនិងសញ្ញាចុះបញ្ជីអាកាសយាន ដូចមានចែងក្នុងមាត្រា១០(ការចុះបញ្ជីអាកាសយាននិងសញ្ញាសម្គាល់សញ្ជាតិ) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០ 000 000 (ម្ភៃលាន)រៀល ទៅ៥០ 000 000(ហាសិបលាន)រៀល។

**មាត្រា៧៦ .–** ការបំពានលក្ខខណ្ឌនៃវិញ្ញាបនបត្រលទ្ធភាពហោះហើរ

ជនណាដែលធ្វើប្រតិបត្តិការអាកាសយាន ឬបន្តធ្វើប្រតិបត្តិការអាកាសយាននៅក្នុងដែនអាកាស និងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនបានគោរពតាមលក្ខខណ្ឌនៃវិញ្ញាបនបត្រលទ្ធភាពហោះហើរ ដូចមានចែងក្នុងមាត្រា១៤(វិញ្ញាបនបត្រលទ្ធភាពហោះហើរ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០ (ហាសិបលាន)រៀល។

**មាត្រា៧៧ .–** ការមិនគោរពលក្ខខណ្ឌនៃឧបករណ៍វិទ្យុអាកាសចរណ៍

ជនណាដែលធ្វើប្រតិបត្តិការហោះហើរអាកាសយាននៅក្នុងដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ដែលមិនបានបំពាក់លើអាកាសយាននោះនូវឧបករណ៍វិទ្យុអាកាសចរណ៍ ដោយមិនស្របតាមលក្ខខណ្ឌ ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា១៦(ឧបករណ៍វិទ្យុអាកាសចរណ៍)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០ (ហាសិបលាន)រៀល។

ត្រូវផ្តន្ទាទោសដូចគ្នា ចំពោះជនណាដែលប្រើប្រាស់ដោយគ្មានការអនុញ្ញាតនូវឧបករណ៍បញ្ជូនឬទទួលសញ្ញាវិទ្យុពីអាកាសយាន ឬម៉ាស៊ីន ឬបរិក្ខារ ឬឧបករណ៍ដែលរំខានដល់វិទ្យុអាកាសចរណ៍។

**មាត្រា៧៨ .–** ការមិនអនុវត្តវិធានរក្សានិងកត់ត្រាសៀវភៅកត់ត្រា

ជនណាដែលធ្វើប្រតិបត្តិការហោះហើរអាកាសយាននៅក្នុងដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនបានរក្សាទុកសៀវភៅកត់ត្រាការហោះហើរឬបំពេញព័ត៌មានមិនត្រឹមត្រូវ ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា១៧(សៀវភៅកត់ត្រាការហោះហើរនិងឯកសារតម្រូវក្នុងពេលហោះហើរ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល។

**មាត្រា៧៩ .–** ការមិនយកតាមនូវសំណុំឯកសារតម្រូវក្នុងពេលហោះហើរ

ជនណាដែលធ្វើប្រតិបត្តិការហោះហើរអាកាសយាននៅព្រះរាជាណាចក្រកម្ពុជា ដោយមិនបានយកតាមជាមួយនូវឯកសារតម្រូវណាមួយក្នុងពេលហោះហើរ ដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា១៧(សៀវភៅកត់ត្រាការហោះហើរនិងឯកសារតម្រូវក្នុងពេលហោះហើរ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ១០ ០០០ ០០០ (ដប់លាន)រៀល។

**មាត្រា៨០ .–** ការធ្វើឱ្យខូចខាតឬបំផ្លិចបំផ្លាញដោយចេតនានូវសៀវភៅកត់ត្រាការហោះហើរឬឯកសារតម្រូវក្នុងពេលហោះហើរ

ជនណាដែលធ្វើឱ្យខូចខាតឬបំផ្លិចបំផ្លាញដោយចេតនានូវសៀវភៅកត់ត្រាការហោះហើរឬឯកសារតម្រូវណាមួយក្នុងពេលហោះហើរ ដែលមានចែងក្នុងមាត្រា១៧(សៀវភៅកត់ត្រាការហោះហើរនិងឯកសារតម្រូវក្នុងពេលហោះហើរ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល។

**មាត្រា៨១ .-** ការធ្វើប្រតិបត្តិការអាកាសយានដោយគ្មានអាជ្ញាបណ្ណឬវិញ្ញាបនបត្រ ឬដោយធ្វើសកម្មភាពហួសពីកម្រិតកំណត់នៃអាជ្ញាបណ្ណឬវិញ្ញាបនបត្រ

សមាជិកក្រុមអាកាសយានិកដែលធ្វើប្រតិបត្តិការអាកាសយាននៅក្នុងដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ដោយគ្មានអាជ្ញាបណ្ណឬវិញ្ញាបនបត្រ ឬដោយធ្វើសកម្មភាពហួសពីកម្រិតកំណត់នៃអាជ្ញាបណ្ណឬវិញ្ញាបនបត្រ ដូចមានចែងក្នុងមាត្រា១៨(បុគ្គលិកអាកាសចរណ៍ស៊ីវិល) និងមាត្រា១៩(អាជ្ញាបណ្ណឬវិញ្ញាបនបត្រ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល។

បុគ្គលិកអាកាសចរណ៍ស៊ីវិលក្រៅពីក្រុមអាកាសយានិកដែលធ្វើប្រតិបត្តិអាកាសយាននៅក្នុងដែនដីនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ដោយគ្មានអាជ្ញាបណ្ណឬវិញ្ញាបនបត្រ ឬដោយធ្វើសកម្មភាពហួសពីកម្រិតកំណត់នៃអាជ្ញាបណ្ណឬវិញ្ញាបនបត្រ ដូចមានចែងក្នុងមាត្រា១៨(បុគ្គលិកអាកាសចរណ៍ស៊ីវិល) និងមាត្រា១៩(អាជ្ញាបណ្ណឬវិញ្ញាបនបត្រ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៨២ .-** ការចាត់តាំងសមាជិកក្រុមអាកាសយានិកដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់

ជនណាដែលចាត់តាំងសមាជិកក្រុមអាកាសយានិកដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់ឱ្យធ្វើជាមេបញ្ជាការអាកាសយាន ឬជាជំនួយការមេបញ្ជាការអាកាសយាន ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា២០(មេបញ្ជាការអាកាសយាន)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៨៣ .-** ការមិនគោរពតាមបទបញ្ជាដែនអាកាសនិងការបញ្ជាណែនាំរបស់អ្នកបញ្ជាចរាចរណ៍ផ្លូវអាកាស

មេបញ្ជាការអាកាសយានដែលធ្វើប្រតិបត្តិការអាកាសយាននៅក្នុងឬឆ្លងកាត់ដែនអាកាស និងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនគោរពតាមបទបញ្ជាដែនអាកាស ឬការបញ្ជាណែនាំរបស់អ្នកបញ្ជាចរាចរណ៍ផ្លូវអាកាស ដូចមានចែងនៅក្នុងកថាខណ្ឌទី២នៃមាត្រា២០(មេបញ្ជាការអាកាសយាន)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៨៤ .-** ការបំពានកាតព្វកិច្ចរាយការណ៍

ជនណាដែលមិនបានបំពេញកាតព្វកិច្ចរាយការណ៍ ដូចមានចែងនៅក្នុងកថាខណ្ឌទី២នៃមាត្រា២១(ការរាយការណ៍)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៨៥ .-** ការមិនគោរពតាមបទបញ្ជាដែនអាកាសក្នុងពេលប្រតិបត្តិការនៅក្រៅព្រះរាជាណាចក្រកម្ពុជា

មេបញ្ជាការអាកាសយាននៃអាកាសយានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ដែលធ្វើប្រតិបត្តិការអាកាសយាននៅក្រៅព្រះរាជាណាចក្រកម្ពុជា ដោយមិនគោរពតាមបទបញ្ជាដែនអាកាស ដូចមានចែងនៅក្នុងកថាខណ្ឌទី[illegible]នៃមាត្រា២២(បទបញ្ជាដែនអាកាស)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៨៦ ._** ការបំពានអាកាសវិថី តំបន់ហាមឃាត់ តំបន់កម្រិតការហោះហើរនិងតំបន់គ្រោះថ្នាក់ និងការមិនគោរពតាមបទបញ្ជាចុះចតនៅអាកាសយានដ្ឋាន

មេបញ្ជាការអាកាសយានដែលធ្វើប្រតិបត្តិការហោះហើរឬធ្វើសកម្មភាពនៅក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនគោរពទៅតាម ឬហោះឃ្លាតពីអាកាសវិថី ឬដោយចូលតំបន់ហាមឃាត់ តំបន់កម្រិតការហោះហើរ ឬតំបន់គ្រោះថ្នាក់ ដូចមានចែងនៅក្នុងកថាខណ្ឌទី២និងកថាខណ្ឌទី៣នៃមាត្រា២៤(ការគ្រប់គ្រងដែនអាកាស)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល។

ត្រូវផ្តន្ទាទោសដូចគ្នា ចំពោះមេបញ្ជាការអាកាសយានដែលធ្វើប្រតិបត្តិការហោះហើរឬធ្វើសកម្មភាពនៅក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនគោរពបទបញ្ជាចុះចតនៅអាកាសយានដ្ឋាន ដូចមានចែងនៅក្នុងកថាខណ្ឌទី៤នៃមាត្រា២៤(ការគ្រប់គ្រងដែនអាកាស)នៃច្បាប់នេះ។

**មាត្រា៨៧ ._** ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាសដោយគ្មានការអនុញ្ញាត

ជនណាដែលដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាសដោយគ្មានការអនុញ្ញាត ដូចមានចែងនៅក្នុងមាត្រា៣០(ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាស)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ។

**មាត្រា៨៨ ._** ការបង្កើតឬធ្វើប្រតិបត្តិការរោងចក្រផលិតអាកាសយាននិងអង្គភាពថែទាំអាកាសយានដោយគ្មានការអនុញ្ញាត

ជនណាដែលបង្កើត ឬធ្វើប្រតិបត្តិការរោងចក្រផលិត កែច្នៃ ថែទាំបច្ចេកទេស ឬស្ថានីយជួសជុលអាកាសយាន ម៉ាស៊ីនអាកាសយាន ឬកង្ហារ រួមទាំងគ្រឿងបន្លាស់ និងផ្នែកសំខាន់ៗផ្សេងទៀតរបស់អាកាសយានណាមួយ ដោយគ្មានវិញ្ញាបនបត្រ ដូចមានចែងនៅក្នុងកថាខណ្ឌទី១នៃមាត្រា៣៨(រោងចក្រផលិតអាកាសយាននិងអង្គភាពថែទាំអាកាសយាន)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល។

**មាត្រា៨៩ ._** ការចុះចតខុសទីតាំងកំណត់

មេបញ្ជាការអាកាសយានដែលធ្វើប្រតិបត្តិការហោះហើរ ឬធ្វើសកម្មភាពនៅក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ដោយចុះចតខុសចំណាត់ថ្នាក់អាកាសយានដ្ឋាន ដូចមានចែងនៅក្នុងកថាខណ្ឌទី២នៃមាត្រា៣៩(ការកំណត់ទីតាំង)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល។

ត្រូវផ្តន្ទាទោសដូចគ្នា ចំពោះមេបញ្ជាការអាកាសយានដែលធ្វើប្រតិបត្តិការហោះហើរ ឬធ្វើសកម្មភាពនៅក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ដោយចុះចតក្រៅអាកាសយានដ្ឋានដែលបានកំណត់ ឬចុះចតខុសទីតាំងបណ្តោះអាសន្នដែលកំណត់សម្រាប់ធ្វើការចុះចតនិងហោះឡើង ដូចមានចែងនៅក្នុងកថាខណ្ឌទី៣នៃមាត្រា៣៩(ការកំណត់ទីតាំង)នៃច្បាប់នេះ។

**មាត្រា៩០ ._** ការធ្វើប្រតិបត្តិការ ការគ្រប់គ្រង ការប្រើប្រាស់ដី ឬការពង្រីកអាកាសយានដ្ឋានដោយគ្មានការអនុញ្ញាត

ជនណាដែលធ្វើប្រតិបត្តិការអាកាសយានដ្ឋាន គ្រប់គ្រងអាកាសយានដ្ឋាន ប្រើប្រាស់ចំណែកដីណាមួយធ្វើអាកាសយានដ្ឋាន ឬពង្រីកអាកាសយានដ្ឋាន ដោយគ្មានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ដូចមានចែងនៅក្នុងកថាខណ្ឌ[illegible](លក្ខខណ្ឌអាជ្ញាបណ្ណឬវិញ្ញាបនបត្រ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល។

**មាត្រា៩១ .-** ការបញ្ចាំងប្រភពពន្លឺទៅលើអាកាស

ជនណាដែលបំពាក់ភ្លើងបំភ្លឺដែលអាចបង្កគ្រោះថ្នាក់ដល់ប្រតិបត្តិការអាកាសយាន ឬបំពាក់ឧបករណ៍ចំណាំងផ្លាតដែលបង្កការរំខានដល់អាកាសយាននិងការបញ្ជាចរាចរណ៍ដែនអាកាសនៅក្នុងអាកាសយានដ្ឋាន ដូចមានចែងក្នុងចំណុច ខ នៃកថាខណ្ឌទី១នៃមាត្រា៤៥(សេចក្តីប្រកាសស្តីពីតំបន់គ្រប់គ្រងនិងបញ្ញត្តិកម្មលើសំណង់ ភ្លើងបំភ្លឺ ឧបករណ៍ចំណាំងផ្លាត រុក្ខជាតិ និងប្រភពនានាដែលអាចទាក់ទាញសត្វបង្កគ្រោះថ្នាក់)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ដល់២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ដល់២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៩២ .-** ការមិនអនុវត្តសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល

ជនណាមិនអនុវត្តតាមសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល ដូចមានចែងនៅក្នុងមាត្រា៥២(សេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល។

**មាត្រា៩៣ .-** ការចូលឬបន្តស្ថិតនៅក្នុងតំបន់ហាមឃាត់ដោយគ្មានការអនុញ្ញាត

ជនណាដែលចូលឬបន្តស្ថិតនៅក្នុងតំបន់ហាមឃាត់ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២នៃមាត្រា៥៦(វត្តមានអ្នកគ្មានសិទ្ធិអនុញ្ញាតនៅក្នុងតំបន់ហាមឃាត់)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពី១(មួយ)ខែ ដល់១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ដល់ ១០ ០០០ ០០០(ដប់លាន)រៀល។

**មាត្រា៩៤ .-** ការមិនគោរពលក្ខខណ្ឌនៃការជួសជុលនិងថែទាំអាកាសយាន

ជនណាដែលពុំបានបំពេញនូវលក្ខខណ្ឌនៃការជួសជុលនិងការថែទាំអាកាសយាន ដូចមានចែងក្នុងកថាខណ្ឌទី៥នៃមាត្រា៥៨(វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៩៥ .-** ការដឹកជញ្ជូនតាមផ្លូវអាកាសដោយសហគ្រាសដែលគ្មានវិញ្ញាបនបត្រ

ជនណាធ្វើប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស ដូចមានចែងក្នុងមាត្រា៥៨(វិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាស) ឬដោយគ្មានការធានារ៉ាប់រង ដូចមានចែងក្នុងមាត្រា៦៦(ការធានារ៉ាប់រង)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល។

**មាត្រា៩៦ .-** ការធ្វើប្រតិបត្តិការអាកាសចរណ៍ដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលតម្រូវ បណ្តាលឱ្យរងរបួសដល់អ្នកដទៃ

សមត្ថបុគ្គលិកអាកាសចរណ៍ស៊ីវិលដែលធ្វើប្រតិបត្តិការអាកាសចរណ៍ដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលតម្រូវ បណ្តាលឱ្យរងរបួសដល់អ្នកដទៃហើយបណ្តាលឱ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើឬលើសពី៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើតហេតុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៩៧ .-** ការរារាំងការបំពេញភារកិច្ចផ្លូវការ

ជនណារារាំងការបំពេញភារកិច្ចរបស់មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល ដែលមានចែងក្នុងមាត្រា៦៨ (សិទ្ធិនិងភារកិច្ចរបស់មន្ត្រីអធិការកិច្ចអាកាសចរណ៍ស៊ីវិល)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ដល់១០ ០០០ ០០០ (ដប់លាន)រៀល។

**មាត្រា៩៨ .-** ស្ថានទម្ងន់ទោស

អំពើដូចមានចែងក្នុងមាត្រា៧៦(ការបំពានលក្ខខណ្ឌនៃវិញ្ញាបនបត្រលទ្ធភាពហោះហើរ) មាត្រា៧៧ (ការមិនគោរពលក្ខខណ្ឌនៃឧបករណ៍វិទ្យុអាកាសចរណ៍) ពីមាត្រា៨១(ការធ្វើប្រតិបត្តិការអាកាសយានដោយគ្មានអាជ្ញាបណ្ណឬវិញ្ញាបនបត្រ ឬដោយធ្វើសកម្មភាពហួសពីកម្រិតកំណត់នៃអាជ្ញាបណ្ណឬវិញ្ញាបនបត្រ) ដល់មាត្រា៨៣ (ការមិនគោរពតាមបទបញ្ជាដែនអាកាសនិងការបញ្ជាណែនាំរបស់អ្នកបញ្ជាចរាចរណ៍ផ្លូវអាកាស) មាត្រា៨៥ (ការមិនគោរពតាមបទបញ្ជាដែនអាកាសក្នុងពេលប្រតិបត្តិការនៅក្រៅព្រះរាជាណាចក្រកម្ពុជា) មាត្រា៨៦ (ការបំពានអាកាសវិថី តំបន់ហាមឃាត់ តំបន់កម្រិតការហោះហើរនិងតំបន់គ្រោះថ្នាក់ និងការមិនគោរពតាមបទបញ្ជាចុះចតនៅអាកាសយានដ្ឋាន) មាត្រា៨៩(ការចុះចតខុសទីតាំងកំណត់) មាត្រា៩០(ការធ្វើប្រតិបត្តិការ ការគ្រប់គ្រង ការប្រើប្រាស់ដី ឬការពង្រីកអាកាសយានដ្ឋានដោយគ្មានការអនុញ្ញាត) និងពីមាត្រា៩៤(ការមិនគោរពលក្ខខណ្ឌនៃការជួសជុលនិងថែទាំអាកាសយាន) ដល់មាត្រា៩៦(ការធ្វើប្រតិបត្តិការអាកាសចរណ៍ដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិលតម្រូវ បណ្តាលឱ្យរងរបួសដល់អ្នកដទៃ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដោយមានស្ថានទម្ងន់ទោស ក្នុងករណី ដូចខាងក្រោម៖

- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ប្រសិនបើអំពើណាមួយដូចមានចែងខាងលើ បណ្តាលឱ្យមានការកាត់អវៈយវៈឬនាំឱ្យមានពិការភាពអចិន្ត្រៃយ៍ដល់ជនរងគ្រោះ
- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ ប្រសិនបើអំពើណាមួយដូចមានចែងខាងលើ បណ្តាលឱ្យមានមនុស្សស្លាប់
- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ទៅ៣០(សាមសិប)ឆ្នាំ ឬអស់មួយជីវិត ប្រសិនបើអំពើណាមួយ ដូចមានចែងខាងលើ បណ្តាលឱ្យមានមនុស្សស្លាប់ច្រើននាក់ ឬប្រសិនបើអំពើខាងលើត្រូវបានប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង។

អំពើដូចមានចែងក្នុងមាត្រា៨៧(ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាសដោយគ្មានការអនុញ្ញាត) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដោយមានស្ថានទម្ងន់ទោស ក្នុងករណី ដូចខាងក្រោម៖

- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ ប្រសិនបើអំពើ ដូចមានចែងខាងលើ បណ្តាលឱ្យមានមនុស្សស្លាប់។
- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ទៅ៣០(សាមសិប)ឆ្នាំ ឬអស់មួយជីវិត ប្រសិនបើអំពើដូចមានចែងខាងលើ បណ្តាលឱ្យមានមនុស្សស្លាប់ច្រើននាក់ ឬប្រសិនបើអំពើខាងលើត្រូវបានប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង។

**មាត្រា៩៩ .-** ការប្រើទោសបន្ថែមចំពោះរូបវន្តបុគ្គល

ចំពោះជនណាដែលប្រព្រឹត្តបទល្មើសដែលមានចែងក្នុងមាត្រា៧៥(ការមិនចុះបញ្ជីឬមិនបំពាក់សញ្ញាសម្គាល់សញ្ជាតិនិងសញ្ញាចុះបញ្ជីអាកាសយាន) ដល់មាត្រា៩៧(ការរារាំងការបំពេញភារកិច្ចផ្លូវការ)នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៣(ប្រភេទទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា១០០ .-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា៧៥ដល់មាត្រា៧៨(ការមិនអនុវត្តវិធានរក្សានិងកត់តាសៀវភៅកត់ត្រា) មាត្រា៨២(ការចាត់តាំងសមាជិកក្រុមអាកាសយានិកដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់) មាត្រា៨៤(ការបំពានកាតព្វកិច្ចរាយការណ៍) មាត្រា៨៧(ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវអាកាសដោយគ្មានការអនុញ្ញាត) មាត្រា៨៨(ការបង្កើតឬធ្វើប្រតិបត្តិការរោងចក្រផលិតអាកាសយាននិងអង្គភាពថែទាំអាកាសយានដោយគ្មានការអនុញ្ញាត) មាត្រា៩០(ការធ្វើប្រតិបត្តិការ ការគ្រប់គ្រង ការប្រើប្រាស់ដី ឬការពង្រីកអាកាសយានដោយគ្មានការអនុញ្ញាត) មាត្រា៩២(ការមិនអនុវត្តសេចក្តីណែនាំអនុវត្តស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល) មាត្រា៩៤(ការមិនគោរពលក្ខខណ្ឌនៃការជួសជុលនិងថែទាំអាកាសយាន) មាត្រា៩៥(ការដឹកជញ្ជូនតាមផ្លូវអាកាសដោយសហគ្រាសដែលគ្មានវិញ្ញាបនបត្រ) និងមាត្រា៩៧(ការរារាំងការបំពេញភារកិច្ចផ្លូវការ)នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១ ០០០ ០០០ ០០០(មួយពាន់លាន)រៀល ទៅ២ ០០០ ០០០ ០០០(ពីរពាន់លាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា១០១ .-** ការមិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត

ការអនុវត្តបញ្ញត្តិនៃជំពូកទី២២(ទោសប្បញ្ញត្តិ)នៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី២៣
## ការអនុវត្តសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ

**មាត្រា១០២ .-** ការអនុវត្តសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិ

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិដែលទាក់ទងនឹងវិស័យអាកាសចរណ៍ស៊ីវិលដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគី អាចយកមកអនុវត្តបានជាមួយនឹងច្បាប់នេះ។

## ជំពូកទី២៤
## អន្តរប្បញ្ញត្តិ

**មាត្រា១០៣ .-** អន្តរប្បញ្ញត្តិ

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ត្រូវនៅតែមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

អាជ្ញាប័ណ្ណដែលកំពុងកាន់កាប់ឬប្រើប្រាស់លិខិតគតិយុត្តស្ថិតក្រោមច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានមុនការចូលជាធរមាននៃច្បាប់នេះ ត្រូវបន្តអនុវត្តរហូតដល់ផុតសុពលភាព។ ការស្នើសុំបន្តសុពលភាពឬការស្នើសុំថ្មី ត្រូវអនុវត្តស្របតាមច្បាប់នេះ។

## ជំពូកទី២៥
## អវសានប្បញ្ញត្តិ

**មាត្រា១០៤ .-** បញ្ញត្តិអានុភាពអនុវត្ត

ច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានមុនការចូលជាធរមាននៃច្បាប់នេះ ត្រូវបាត់បង់អានុភាពនិងត្រូវជំនួសដោយច្បាប់នេះ លើកលែងតែបទប្បញ្ញត្តិនៃមាត្រា២១នៃច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ត្រូវបន្តមានអានុភាពអនុវត្តក្រោយការចូលជាធរមាននៃច្បាប់នេះ រហូតដល់មានបទប្បញ្ញត្តិនៃច្បាប់ថ្មីមកជំនួស។

បទប្បញ្ញត្តិដែលកំណត់អំពីបទល្មើសអាកាសចរណ៍ស៊ីវិលដូចមានកំណត់នៅក្នុងច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិល ដែលមានមុនការចូលជាធរមាននៃច្បាប់នេះ ត្រូវបន្តមានអានុភាពអនុវត្តក្រោយការអនុវត្តនៃច្បាប់នេះ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តមុនពេលច្បាប់នេះចូលជាធរមាន លើកលែងតែមានការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាងដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ។

ថ្ងៃ អង្គារ ២ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២៦

នរោត្តម សីហមុនី

ពរល . ២៦០១ . ១២៧

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល**

**ម៉ៅ ហាវណ្ណាល់**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

### សទ្ទានុក្រម

**១- ការងារពីលើអាកាស** សំដៅដល់ប្រតិបត្តិការអាកាសយានដែលអាកាសយានណាមួយត្រូវបានប្រើប្រាស់សម្រាប់សេវាកម្មជំនាញផ្សេងៗ មានជាអាទិ៍ កសិកម្ម ការសាងសង់ ការថតរូប ការវាស់វែង ការល្បាតនិងសង្កេតការណ៍ ការរុករកនិងសង្គ្រោះ និងការផ្សព្វផ្សាយពាណិជ្ជកម្មពីលើអាកាស។

**២- ការការពារខ្លួនជាធម្មានុរូប** សំដៅដល់សិទ្ធិក្នុងការចាត់វិធានការចាំបាច់នានាក្នុងការឆ្លើយតបទៅនឹងអំពើរំលោភបំពានជាមុនដែលកំពុងប្រព្រឹត្តឬនឹងប្រព្រឹត្ត ដែលអាចប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាពអាកាសចរណ៍ស៊ីវិល បូរណភាពដែនដីនិងអធិបតេយ្យភាពរបស់កម្ពុជា។

**៣- ការដឹកជញ្ជូនតាមផ្លូវអាកាស** សំដៅដល់ការដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងប្រទេសនិងអន្តរជាតិ។

**៤- ការដឹកជញ្ជូនតាមផ្លូវអាកាសក្នុងប្រទេស** សំដៅដល់ការដឹកជញ្ជូនតាមផ្លូវអាកាសពីកន្លែងមួយទៅកន្លែងមួយទៀតនៅក្នុងរង្វង់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

**៥- ការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ** សំដៅដល់ការដឹកជញ្ជូនតាមផ្លូវអាកាសរវាងកន្លែងមួយក្នុងព្រះរាជាណាចក្រកម្ពុជានិងកន្លែងដទៃទៀតនៅក្រៅប្រទេស។

**៦- ការនាំផ្លូវអាកាស** សំដៅដល់ដំណើរការនៃការរៀបចំផែនការ ការកត់ត្រា ការគ្រប់គ្រងចលនាអាកាសយានពីទីតាំងមួយទៅទីតាំងមួយផ្សេងទៀត តាមរយៈការប្រើប្រាស់ឧបករណ៍ជំនួយនាំផ្លូវ ផែនទី គំនូស ផ្លូវហោះ និង ឧបករណ៍និងប្រព័ន្ធអេឡិចត្រូនិកដើម្បីកំណត់ទីតាំងអាកាសយានតាមដំណាក់ផ្លូវហោះរបស់អាកាសយាននោះដើម្បីធានាសុវត្ថិភាពនិងប្រសិទ្ធភាពនៃការហោះហើរ។

**៧- កិច្ចព្រមព្រៀងស្តីពីមាត្រា៨៣ស្ទួន** សំដៅដល់កិច្ចព្រមព្រៀង ដែលធ្វើឡើងតាមមាត្រា៨៣ស្ទួននៃអនុសញ្ញាស៊ីកាហ្គោ។

**៨- ក្រុមហោះ** សំដៅដល់បុគ្គលិកអាកាសចរណ៍ដែលត្រូវបានប្រតិបត្តិករអាកាសយានចាត់តាំងឱ្យបំពេញភារកិច្ចនៅក្នុងប្រតិបត្តិការហោះហើរ។

**៩- ក្រុមអាកាសយានិក** សំដៅដល់មេបញ្ជាការអាកាសយាន ជំនួយការមេបញ្ជាការអាកាសយាននិងវិស្វករបច្ចេកទេស ដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចបញ្ជាអាកាសយាននៅក្នុងប្រតិបត្តិការហោះហើរ។

**១០- ក្រុមបាហុនិកា** សំដៅដល់បុគ្គលិកដែលបម្រើសេវាកម្មក្នុងអាកាសយាននិងអនុវត្តភារកិច្ចធានាសុវត្ថិភាពអ្នកដំណើរនៅក្នុងកំឡុងពេលប្រតិបត្តិការហោះហើរ តាមការបែងចែករបស់ប្រតិបត្តិករអាកាសយាន ឬមេបញ្ជាការអាកាសយាន។

**១១- ករណីប្រធានសក្តិ** សំដៅដល់បាតុភូតកើតឡើងដោយធម្មជាតិ ដែលមនុស្សមិនអាចដឹងមុននិងមិនអាចទប់ទល់បាន។

**១២- គ្រោះថ្នាក់** សំដៅដល់ការកើតឡើង ដែលជាប់ពាក់ព័ន្ធទៅនឹងប្រតិបត្តិការរបស់អាកាសយាន ដែលក្នុងករណីអាកាសយានមានមនុស្សបើក ព្រឹត្តិការណ៍កើតឡើងគិតចាប់ពីពេលដែលបុគ្គលណាម្នាក់ឡើងលើអាកាសយានក្នុងគោលបំណងដើម្បីហោះហើរ រហូតដល់ពេលដែលបុគ្គលទាំងនោះចាកចេញពីអាកាសយាន ឬក្នុងករណីអាកាសយានគ្មានមនុស្សបើក ព្រឹត្តិការណ៍កើតឡើងគិតចាប់ពីអាកាសយាននោះប្រុងប្រៀបត្រៀម

ធ្វើចលនា ក្នុងគោលបំណងហោះហើរ រហូតដល់ពេលអាកាសយាននោះឈប់នៅចុងបញ្ចប់នៃការហោះហើរ ហើយដែលប្រព័ន្ធម៉ាស៊ីនចម្បងត្រូវបានបិទ ដែលព្រឹត្តិការណ៍បណ្តាលឱ្យ៖

១- បុគ្គលណាម្នាក់បានបាត់បង់ជីវិត ឬរបួសធ្ងន់ធ្ងរដែលបណ្តាលមកពី៖

ក- ស្ថិតនៅក្នុងអាកាសយាន ឬ

ខ- ប៉ះពាល់ដោយផ្ទាល់នៅផ្នែកណាមួយនៃអាកាសយាន រួមមានទាំងផ្នែកនានាដែលបានដាច់ចេញពីតួអាកាសយាន ឬ

គ- ទទួលរងដោយផ្ទាល់ពីកម្លាំងខ្យល់ម៉ាស៊ីនអាកាសយាន។

លើកលែងតែ ចំពោះការរងរបួសដែលបណ្តាលមកពីហេតុផលធម្មជាតិ ការធ្វើឱ្យរបួសដោយខ្លួនឯង ឬដោយអ្នកដទៃ ឬចំពោះការរងរបួសនៃបុគ្គលដែលបានលាក់ខ្លួនក្នុងអាកាសយាននៅក្រៅតំបន់ដែលជាធម្មតាកំណត់សម្រាប់អ្នកដំណើរ និងសមាជិកក្រុមហោះ ឬ

២- អាកាសយានទទួលរងការខូចខាតឬមិនដំណើរការលើផ្នែកបង្គុំណាមួយដែល៖

ក- ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់កម្លាំងទ្រទ្រង់ ដំណើរការ ឬទម្រង់ហោះហើររបស់អាកាសយាន និង

ខ- ដែលជាធម្មតាតម្រូវឱ្យមានការជួសជុលទ្រង់ទ្រាយធំ ឬផ្លាស់ប្តូរផ្នែកដែលរងផលប៉ះពាល់។

លើកលែងតែចំពោះករណីម៉ាស៊ីនមិនដំណើរការឬការខូចខាត ដែលការខូចខាតនោះកំណត់ត្រឹមម៉ាស៊ីនតែមួយ រួមបញ្ចូលទាំងគម្របម៉ាស៊ីនឬគ្រឿងបរិក្ខារ កង្ហារ ស្លាប ចុងស្លាប អង់តែន រន្ធខ្យល់ វ៉ានបិទបើក សំបកកង់ ហ្វ្រាំងកង់ សន្ទះបិទបើក បន្ទះផាណែល ប្រព័ន្ធកង់សម្រាប់ចុះចត ទ្វារ ឧបករណ៍វាស់ខ្យល់ ស្បែកអាកាសយាន ដូចជាស្នាមកំពិតតូចៗឬស្នាមប្រេះឆ្លុះ ឬចំពោះការខូចខាតតូចតាចលើស្លាបកង្ហារសំខាន់ ស្លាបកង្ហារកន្ទុយ ប្រព័ន្ធកង់សម្រាប់ចុះចត និងការខូចខាតដែលបណ្តាលមកពីការប៉ះទង្គិចឬការវាយប្រហារដោយបក្សី។

៣- អាកាសយានបានបាត់ឬមិនអាចចូលទៅដល់ទាំងស្រុង។

**១៣- គ្រោះអាសន្ន** សំដៅដល់ស្ថានភាពដែលអាកាសយានជួបគ្រោះថ្នាក់ឬជួបស្ថានភាពដែលអាកាសយាន ឬអ្នកដំណើរនៅលើអាកាសយានមានគ្រោះភ័យដែលក្រុមហោះមិនអាចដោះស្រាយបាន ឬអាកាសយានបាត់ទំនាក់ទំនងហើយមិនអាចកំណត់ទីតាំងបាន។

**១៤- ដែនអាកាស** សំដៅដល់ដែនកំណត់នៅក្នុងលម្ហអាកាស ដែលស្ថិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាឬដែនសមុទ្រអន្តរជាតិ។

**១៥- ដែនដី** សំដៅដល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជារួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់ជាមួយនឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

**១៦- ឋបនីយកណ្តាលនាំផ្លូវអាកាស** សំដៅដល់ឧបករណ៍ គ្រឿងបរិក្ខារ ប្រព័ន្ធនិងកម្មវិធីគ្រប់គ្រងសេវាកម្មនាំផ្លូវអាកាសទាំងឡាយណា ដែលបម្រើដោយផ្ទាល់ឬគាំទ្រឱ្យសេវាកម្មនាំផ្លូវអាកាស សេវាកម្ម ចរាចរណ៍ដែនអាកាស សេវាកម្មផ្តល់ព័ត៌មានអាកាសចរណ៍ សេវាកម្មគំនូសផែនទីអាកាសចរណ៍ សេវាកម្ម ឌីហ្សាញបទដ្ឋានហោះហើរ សេវាកម្មទូរគមនាគមន៍អាកាសចរណ៍ សេវាកម្មឧតុនិយមអាកាសចរណ៍ សេវាកម្មរុករក និងសង្គ្រោះអាកាសចរណ៍។

**១៧- ឌីហ្សាញបទដ្ឋានហោះហើរ** សំដៅដល់ដំណើរការនៃការរចនាផ្លូវហោះនិងការគណនាបទដ្ឋានផ្លូវហោះហើរដោយផ្អែកលើទិន្នន័យឧបករណ៍នាំផ្លូវអាកាស សមត្ថភាពអាកាសយាននិងកម្ពស់ឧបសគ្គ អនុលោមតាម

បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល ដើម្បីធានាថាប្រតិបត្តិការហោះហើររបស់អាកាសយានប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

**១៨- ប្រតិបត្តិករអាកាសយាន** សំដៅដល់បុគ្គល អង្គភាព ឬសហគ្រាសដែលចូលរួមធ្វើប្រតិបត្តិការអាកាសយាន ហើយទទួលបានវិញ្ញាបនបត្រប្រតិបត្តិការតាមផ្លូវអាកាសដែលផ្តល់ឬទទួលស្គាល់សុពលភាពដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**១៩- ប្រតិបត្តិករអាកាសយានដ្ឋាន** សំដៅដល់បុគ្គល អង្គភាព ឬសហគ្រាសដែលចូលរួមធ្វើប្រតិបត្តិការអាកាសយានដ្ឋាន ហើយទទួលបានវិញ្ញាបនបត្រប្រតិបត្តិការអាកាសយានដ្ឋានដែលផ្តល់ឬទទួលស្គាល់សុពលភាពដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**២០- ប្រតិបត្តិការអាកាសចរណ៍ស៊ីវិល** សំដៅដល់ប្រតិបត្តិការអាកាសយាន ប្រតិបត្តិការអាកាសយានដ្ឋាន ប្រតិបត្តិការនាំផ្លូវអាកាស ព្រមទាំងសេវាកម្មផ្សេងៗទៀតដែលពាក់ព័ន្ធដោយផ្ទាល់ឬមានផ្នែកពាក់ព័ន្ធទៅនឹងប្រតិបត្តិការទាំងនោះ។

**២១- បុគ្គលិកអាកាសចរណ៍ស៊ីវិល** សំដៅដល់បុគ្គលណាមួយដែលអនុវត្តការងារប្រតិបត្តិការអាកាសចរណ៍ស៊ីវិល ដែលក្នុងនោះមានជាអាទិ៍ ក្រុមអាកាសយានិក បាហុនិកា អ្នកបច្ចេកទេសថែទាំអាកាសយាន អ្នកឯកទេសសេវាកម្មផ្ទៃដី អ្នកបញ្ជាចរាចរណ៍ផ្លូវអាកាស បុគ្គលិកនាំផ្លូវអាកាស ឬនិយោជិតរបស់ក្រុមហ៊ុនដឹកជញ្ជូនតាមផ្លូវអាកាសឬនិយោជិតរបស់អាកាសយានដ្ឋាន ដែលតម្រូវឱ្យមានអាជ្ញាបណ្ណឬវិញ្ញាបនបត្របញ្ជាក់សមត្ថភាពសមស្របតាមភារកិច្ចរបស់ខ្លួន។

**២២- បុគ្គលិកជំនាញឯកទេសអាកាសចរណ៍ស៊ីវិល** សំដៅដល់ អ្នកបញ្ជាចរាចរណ៍ផ្លូវអាកាស អ្នករៀបចំផែនការហោះហើរ បុគ្គលិកនាំផ្លូវអាកាស និងអ្នកបច្ចេកទេសថែទាំអាកាសយាន តែមិនគ្របដណ្តប់លើក្រុមអាកាសយានិក និងក្រុមបាហុនិកាទេ។

**២៣- ប្រតិបត្តិការអាកាសយាន** សំដៅដល់សកម្មភាពនិងនីតិវិធីនានាពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអនុវត្តប្រតិបត្តិការការហោះហើរអាកាសយានក្នុងគោលបំណងពាណិជ្ជកម្ម ឯកជន ការកំសាន្ត និងកីឡាជាដើម។

**២៤- ប្រតិបត្តិការហោះហើរ** សំដៅដល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការបញ្ជាអាកាសយានក្នុងពេលហោះហើរ។

**២៥- ប្រតិបត្តិករសេវាកម្មនាំផ្លូវអាកាស** សំដៅដល់នីតិបុគ្គលសាធារណៈ ឬនីតិបុគ្គលឯកជនដែលជាអ្នកផ្តល់សេវាកម្មចរាចរណ៍ដែនអាកាស សេវាកម្មផ្តល់ព័ត៌មានអាកាសចរណ៍ សេវាកម្មគំនូសផែនទី អាកាសចរណ៍ សេវាកម្មឱហ្សាញបទដ្ឋានហោះហើរ សេវាកម្មទូរគមនាគមន៍អាកាសចរណ៍ សេវាកម្មឧតុនិយមអាកាសចរណ៍ សេវាកម្មរុករក និងសង្គ្រោះអាកាសចរណ៍។

**២៦- បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល** សំដៅដល់ស្តង់ដានិងវិធាននានាដែលបង្កើតឡើងដើម្បីត្រួតពិនិត្យកិច្ចប្រតិបត្តិការបច្ចេកទេសអាកាសចរណ៍ស៊ីវិល ដោយអនុលោមតាមឧបសម្ព័ន្ធនានានៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

**២៧- បទប្បញ្ញត្តិបច្ចេកទេសសេដ្ឋកិច្ចអាកាសចរណ៍ស៊ីវិល** សំដៅដល់គោលនយោបាយនិងវិធាននានាដែលបង្កើតឡើងដើម្បីគ្រប់គ្រងទិដ្ឋភាពហិរញ្ញវត្ថុនិងពាណិជ្ជកម្មនៅក្នុងវិស័យអាកាសចរណ៍ស៊ីវិល។

**២៨- បុព្វសិទ្ធិ** សំដៅដល់សិទ្ធិឬកម្រិតអនុញ្ញាតដែលផ្តល់ឱ្យបុគ្គលកាន់ឯកសារអាកាសចរណ៍ក្នុងការអនុវត្តតួនាទីឬប្រភេទការងារណាមួយជាក់លាក់។

**២៩- ផលិតផលអាកាសចរណ៍** សំដៅដល់អាកាសយាន ម៉ាស៊ីនអាកាសយាន កង្ហារអាកាសយាន ឬគ្រឿងបន្លាស់អាកាសយានទាំងឡាយណាដែលត្រូវបានប្រើប្រាស់សម្រាប់ជំទើង។

**៣០- មន្ត្រីសន្តិសុខអាកាសយានដ្ឋាន** សំដៅដល់មន្ត្រីមុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ឬនិយោជិតសហគ្រាសឯកជនដែលមានតួនាទីធានានូវសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយនៅអាកាសយានដ្ឋាន។

**៣១- មន្ត្រីមានសមត្ថកិច្ច** សំដៅដល់មន្ត្រីនគរបាលទទួលបន្ទុកផ្នែកទិដ្ឋាការ អន្តោប្រវេសន៍ សណ្តាប់ធ្នាប់ មន្ត្រីកងរាជអាវុធហត្ថ មន្ត្រីគយនិងរដ្ឋាករ មន្ត្រីចត្តាឡីស័ក និងមន្ត្រីសាធារណៈដទៃទៀតដែលមានតួនាទីធានាសណ្តាប់ធ្នាប់និងគ្រប់គ្រងការចេញចូលអាកាសយានដ្ឋានរបស់អ្នកដំណើរតាមផ្លូវអាកាស។

**៣២- តំបន់ជុំវិញអាកាសយានដ្ឋាន** សំដៅដល់តំបន់គ្រប់គ្រងប្រតិបត្តិការអាកាសយានដ្ឋានដែលមានរង្វង់ប្រតិបត្តិការកំណត់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

**៣៣- តំបន់គ្រប់គ្រងព័ត៌មានហោះហើរ** សំដៅដល់តំបន់ដែលមានខ្សែបន្ទាត់កំណត់នៅក្នុងលម្ហអាកាសដែលនៅក្នុងតំបន់នោះ មានផ្តល់សេវាកម្មព័ត៌មានហោះហើរនិងសេវាកម្មផ្តល់សញ្ញាគ្រោះអាសន្ន។

**៣៤- ពេលកំពុងហោះហើរ** សំដៅដល់រយៈពេលចាប់ពីពេលដែលទ្វារក្រៅរបស់អាកាសយានត្រូវបានបិទបន្ទាប់ពីបានផ្ទុករួចរាល់រហូតដល់ទ្វារក្រៅនោះត្រូវបានបើកឡើងដាក់ចុះ។

**៣៥- រដ្ឋភាគីកិច្ចសន្យា** សំដៅដល់រដ្ឋនានាដែលជាភាគីនៃអនុសញ្ញាស៊ីកាហ្គោ ឆ្នាំ១៩៤៤។

**៣៦- រដ្ឋចុះបញ្ជី** សំដៅដល់រដ្ឋដែលអាកាសយានត្រូវបានកត់ត្រាចូលក្នុងបញ្ជីកត់ត្រាអាកាសយានរបស់ខ្លួន។

**៣៧- រដ្ឋប្រតិបត្តិករ** សំដៅដល់រដ្ឋដែលជាទីតាំងអាជីវកម្មចម្បងឬទីលំនៅអចិន្ត្រៃយ៍របស់ប្រតិបត្តិករក្នុងករណីគ្មានទីតាំងអាជីវកម្ម។

**៣៨- លំដាប់ថ្នាក់អាកាសយានដ្ឋាន** សំដៅដល់ការបែងចែកកម្រិតសមត្ថភាពឬទំហំអាកាសយានដ្ឋានដែលអាចឱ្យអាកាសយានមានទំហំស្របតាមកម្រិតអាកាសយានដ្ឋាននោះចុះចតបាន។ នៅក្នុងស្តង់ដាអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ លំដាប់ថ្នាក់អាកាសយានដ្ឋាន មានលេខកូដ1 2 3 និង4 សម្រាប់សម្គាល់ប្រវែងផ្លូវរត់ ហើយអក្សរកូដ A B C D E និងF សម្រាប់សម្គាល់ទទឹងផ្លូវរត់។

**៣៩- វត្ថុទាំងឡាយ** សំដៅដល់ឧបករណ៍ គ្រឿងបរិក្ខារ និងវត្ថុដទៃទៀតដែលបម្រើដោយផ្ទាល់ឬគាំទ្រដល់ប្រតិបត្តិការអាកាសចរណ៍ស៊ីវិល។

**៤០- សហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាស** សំដៅដល់អ្នកដឹកជញ្ជូនតាមផ្លូវអាកាសមានសញ្ជាតិខ្មែរឬសញ្ជាតិបរទេស។

**៤១- សហភាពទូរគមនាគមន៍អន្តរជាតិ** សំដៅដល់ភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគន៍ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៦៥។

**៤២- សញ្ញាសម្គាល់សញ្ជាតិ** សំដៅដល់សញ្ញាសម្គាល់ជាអក្សរឬលេខ ឬការរួមផ្សំគ្នារវាងអក្សរនិងលេខ ដែលកំណត់ដោយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ សម្រាប់បញ្ជាក់សញ្ជាតិអាកាសយាននីមួយៗ។ ឧទាហរណ៍ សញ្ញាXU សម្រាប់សម្គាល់អាកាសយានសញ្ជាតិកម្ពុជា 9V សម្រាប់សម្គាល់អាកាសយានសិង្ហបុរី ជាដើម។

**៤៣- សញ្ញាសម្គាល់ការចុះបញ្ជី** សំដៅដល់សញ្ញាសម្គាល់អាកាសយានបានចុះបញ្ជីនៅក្នុងប្រទេសមួយ ដែលជាសមាជិករបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

**៤៤- ស្លុតហោះហើរ** សំដៅដល់ម៉ោងហោះឡើងនិងចុះចតរបស់អាកាសយានណាមួយ។

**៤៥- សេវាកម្មនាំផ្លូវអាកាស** សំដៅដល់សេវាកម្មចរាចរណ៍ដែនអាកាស សេវាកម្មផ្តល់ព័ត៌មានអាកាសចរណ៍ សេវាកម្មគំនូសផែនទីអាកាសចរណ៍ សេវាកម្មឪហ្សាញបទដ្ឋានហោះហើរ សេវាកម្មទូរគមនាគមន៍អាកាសចរណ៍ សេវាកម្មឧតុនិយមអាកាសចរណ៍ សេវាកម្មរុករក និងសង្គ្រោះអាកាសចរណ៍។

**៤៦- អាកាសយាន** សំដៅដល់យានទាំងឡាយណា ដែលអាចរក្សាទម្របានក្នុងលម្ហអាកាសដោយបានមកពីផលនៃប្រតិកម្មខ្យល់ក្នុងសម្ពាធបរិយាកាស។

**៤៧- អាកាសយានគ្មានមនុស្សបើក** សំដៅដល់អាកាសយានដែលត្រូវបានបង្កើតឡើងដើម្បីហោះហើរបាន ដោយគ្រប់គ្រងតាមរយៈឧបករណ៍បញ្ជាពីចម្ងាយ ដោយពុំមានអ្នកបើកបរនៅក្នុងយាននោះ។

**៤៨- អាកាសយានរដ្ឋ** សំដៅដល់អាកាសយានរបស់ស្ថាប័នយោធា គយ នគរបាល និងអាកាសយានដទៃទៀត ដែលប្រើប្រាស់ក្នុងគោលបំណងបម្រើសេវាសាធារណៈរបស់រដ្ឋ។

**៤៩- អាកាសយានដ្ឋាន** សំដៅដល់តំបន់ជាក់លាក់នៅលើដីឬទឹក ហើយត្រូវបានប្រើប្រាស់ទាំងស្រុងឬមួយផ្នែក ដើម្បីហោះហើរឡើងឬចុះចត ឬការធ្វើសកម្មភាពរបស់អាកាសយាន និងរួមមានការកសាងឬការរៀបចំបោះទីតាំងនៃអគារនិងបំពាក់ឧបករណ៍នៅក្នុងតំបន់នោះ ព្រមទាំងទីជិតខាងផងដែរ។

**៥០- អាកាសវិថី** សំដៅដល់តំបន់និងកម្រិតកម្ពស់ក្នុងលម្ហអាកាសដែលមានខ្សែបន្ទាត់កំណត់ច្បាស់លាស់ សម្រាប់ការហោះហើររបស់អាកាសយាន។

**៥១- អាជ្ញាបណ្ណឬវិញ្ញាបនបត្រ** សំដៅដល់លិខិតបញ្ជាក់អំពីសមត្ថភាពការងារឬរយៈពេលនៃបេសកកម្ម។ អាជ្ញាបណ្ណឬវិញ្ញាបនបត្រទាំងអស់នេះគឺអាស្រ័យទៅលើប្រទេសដែលផ្តល់ឯកសារអាកាសចរណ៍ទាំងនេះ។

**៥២- អនុសញ្ញាម៉ុងរេអាល់ ឆ្នាំ១៩៩៩** សំដៅដល់អនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស ដែលបានធ្វើឡើងនៅទីក្រុងម៉ុងត្រេអាល់ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩។

**៥៣- អ្នកឯកទេសសេវាកម្មផ្ទៃដី** សំដៅដល់បុគ្គលិកអាកាសចរណ៍ដែលទទួលខុសត្រូវក្នុងការធានាសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការនិងសេវាកម្មរបស់អាកាសយាននៅលើផ្ទៃដីក្នុងអាកាសយានដ្ឋាន។

**៥៤- អនុសញ្ញាស៊ីកាហ្គោ** សំដៅដល់អនុសញ្ញាអាកាសចរណ៍ស៊ីវិលអន្តរជាតិដែលបានអនុម័តនៅទីក្រុងស៊ីកាហ្គោ ថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤៤ និងត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ រួមទាំងឧបសម្ព័ន្ធទាំងអស់ផងដែរ។

**៥៥- អ្នកបញ្ជាចរាចរណ៍ផ្លូវអាកាស** សំដៅដល់អ្នកសម្របសម្រួលនិងកំណត់ទិសដៅចលនាអាកាសយានទាំងនៅលើដីនិងនៅលើអាកាសដើម្បីធានាលំហូរចរាចរផ្លូវអាកាសប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព។

**៥៦- ឧបករណ៍វិទ្យុអាកាសចរណ៍** សំដៅដល់ឧបករណ៍ដែលអាចទទួលនិងបញ្ជូនរលកសញ្ញាជាសំឡេង ជារូបភាព និងជាទិន្នន័យ ដែលបម្រើឱ្យការនាំផ្លូវអាកាស។ ឧបករណ៍វិទ្យុអាកាសចរណ៍ រួមមាន ឧបករណ៍វិទ្យុអាកាសចរណ៍ក្នុងអាកាសយាននិងឧបករណ៍វិទ្យុអាកាសចរណ៍ផ្ទៃដី។

**៥៧- ឧបករណ៍ហោះត្រាប់** សំដៅដល់ឧបករណ៍សិប្បនិម្មិតដែលមានបន្ទប់បើកយន្តហោះប្រើប្រាស់ នៅលើផ្ទៃដីសម្រាប់គោលបំណងហ្វឹកហាត់ការហោះហើរត្រាប់តាមស្ថានភាពហោះហើរជាក់ស្តែងរបស់អាកាសយាន។

**៥៨- ឧប្បត្តិហេតុធ្ងន់ធ្ងរ** សំដៅដល់ឧប្បត្តិហេតុមួយពាក់ព័ន្ធនឹងស្ថានភាពដែលបង្ហាញថា មានលទ្ធភាពខ្ពស់នៃគ្រោះថ្នាក់ ហើយដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់អាកាសយាន ដែលក្នុងករណីអាកាសយានមានមនុស្សបើក ព្រឹត្តិការណ៍កើតឡើងគិតចាប់ពីពេលដែលបុគ្គលណាម្នាក់ឡើងលើអាកាសយាន ក្នុងគោលបំណងដើម្បីហោះហើររហូតដល់ពេលដែលបុគ្គលទាំងនោះចាកចេញពីអាកាសយាន ឬក្នុងករណីអាកាសយានគ្មានមនុស្សបើក ព្រឹត្តិការណ៍កើតឡើងគិតចាប់ពីអាកាសយាននោះប្រុងប្រៀបត្រៀមធ្វើចលនា ក្នុងគោលបំណងហោះហើរ រហូតដល់ពេលអាកាសយាននោះឈប់នៅចុងបញ្ចប់នៃការហោះហើរ ហើយដែលប្រព័ន្ធម៉ាស៊ីនចម្បងត្រូវបានបិទ។

**៥៩- ឯកសារអាកាសចរណ៍** សំដៅដល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត ការទទួលស្គាល់វិញ្ញាបនបត្រ ឬឯកសារដទៃទៀតដែលចេញដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ជូនទៅបុគ្គលណាមួយ ឬចំពោះផលិតផលអាកាសចរណ៍ អាកាសយានដ្ឋាន បរិនីយភណ្ឌ ឬសេវាកម្មណាមួយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ព្រះរាជក្រឹត្យ**

នស/រកត/០១២៦/០៧៦

**ស្តីពី**

**ការតែងតាំងសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩២ ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩៣ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០១៧ ស្តីពីការតែងតាំងសមាសភាពថ្នាក់ដឹកនាំក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១១៨/០៩៧ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៨ ស្តីពីក្របខណ្ឌគោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម** ជាសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជា **បណ្ឌិតសភាចារ្យ** ។

**មាត្រា២** : សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*នស.រកត០១. ០៧១*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/០៧២

## ស្តីពី

## ការតែងតាំងសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩២ ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩៣ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០១៧ ស្ដីពី ការតែងតាំងសមាសភាពថ្នាក់ដឹកនាំក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១១៨/០៩៧ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៨ ស្ដីពី ក្របខណ្ឌគោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តមបណ្ឌិត **ម៉ា ឈឿន** ជាសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជា **បណ្ឌិតសភាចារ្យ** ។

**មាត្រា២ :** សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*នស. ២៦០១. ០៧២*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/០៧៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងក្រុមអ្នកច្បាប់ប្រចាំក្រសួងការពារជាតិ ជា ទីប្រឹក្សា ក្រសួងការពារជាតិ ដោយពុំទទួល ប្រាក់បំណាច់មុខងារ៖

១-ឯកឧត្តម **ណាច ទ្រី**
២-ឯកឧត្តម **ឆួច ណាយ**
៣-ឯកឧត្តម **ហ៊ីង ម៉ុនដា**

**មាត្រា២** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

*ភពល. ២៦០១. ០៧៣*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៦*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី

# ព្រះរាជក្រឹត្យ

នស/រកត/០១២៦/ ០៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងមុខតំណែងឯកឧត្តមឧត្តមសេនីយ៍ទោ **ដួង ច័ន្ទ** អត្តលេខ ០០២៩៨៣ ជា អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ។

**មាត្រា២** : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តមសីហមុនី

ពរស. ២៦០១. ០៧៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៦

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០១ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការធ្វើអនុប្បយោគ និងប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៥៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្ដីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នូវដីបរិវេណសាលាខេត្តពោធិ៍សាត់ ដែលមានអាសយដ្ឋានស្ថិតនៅភូមិពាលញែក២ សង្កាត់ផ្ទះរៃ្រព ក្រុងពោធិ៍សាត់ ជូនប្រជាពលរដ្ឋចំនួន ៤០ គ្រួសារ និងមន្ទីរអង្គភាពចំនួន ៥ មានផ្ទៃដីសរុបចំនួន ១៩ ៦០៨(ដប់ប្រាំបួនពាន់ប្រាំមួយរយប្រាំបី )ម៉ែត្រការ៉េ និងដីបរិវេណផ្សារចាស់ដែលមានអាសយដ្ឋានស្ថិតនៅភូមិពាលញែក១ សង្កាត់ផ្ទះរៃ្រព ក្រុងពោធិ៍សាត់ ជូនប្រជាពលរដ្ឋស្នាក់នៅចំនួន ៥៦ គ្រួសារ មានផ្ទៃដីសរុប ២ ៩១១ (ពីរពាន់ប្រាំបួនរយដប់មួយ )ម៉ែត្រការ៉េ ព្រមទាំងដីវាលយន្តហោះដែលមានអាសយដ្ឋានស្ថិតនៅភូមិចំការចេកខាងជើង សង្កាត់ផ្ទះរៃ្រព ក្រុងពោធិ៍សាត់ ជូនប្រជាពលរដ្ឋស្នាក់នៅចំនួន ១៤០ គ្រួសារ និងមន្ទីរ អង្គភាពចំនួន ៤ មានផ្ទៃដីសរុបចំនួន ៨៥ ៨៣២ (ប៉ែតសិបប្រាំពាន់ប្រាំបីរយសាមសិបពីរ) ម៉ែត្រការ៉េ។

**មាត្រា២.-**

ត្រូវបានលុបទំហំដី ដូចកំណត់ក្នុងមាត្រា ១ ខាងលើ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តពោធិ៍សាត់។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ២រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា៤
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងអ្នកស្ម័គ្រចិត្ត ចំនួន ៤ ៤៣៧រូប ដែលមានស្នាដៃល្អក្នុងការចូលរួមក្នុងយុទ្ធនាការចុះបញ្ជីដីបង្កើយ កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

| | |
|---|---|
| ១- លោកស្រី ឌី ឌីនណា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ឆ្នាំង |
| ២- លោកស្រី ប៉ូ ចន្ថា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ឆ្នាំង |

| | | |
|---|---|---|
| ៣- លោក | សុខ សម្បត្តិ | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកទឹកផុស |
| ៤- លោកស្រី | ហេង ចាន់រស្មី | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ៥- លោក | បឿន ចំរើន | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ៦- លោក | ទុយ មិនា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ៧- លោក | វ៉ែន វាសនា | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកកំពង់ត្រឡាច |
| ៨- លោក | លន់ ទ្រី | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកបរិបូណ៌ |
| ៩- លោក | ប៉ាង ខែត្រ | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលក្រុងកំពង់ឆ្នាំង |
| ១០- លោក | ឈឹម ចំរើន | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុករលាប្អៀរ |
| ១១- លោកស្រី | វង្ស សូវីណា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ១២- លោកស្រី | ស៊ុន រតនា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ១៣- លោក | ហើង ពុទ្ធារិត | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកបរិបូណ៌ |
| ១៤- លោកស្រី | ជា វណ្ណធរី | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ១៥- លោក | ជុំ បូភ័ណ្ឌ | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ១៦- លោក | ម៉ៅ សុ៉ាវី | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ១៧- លោក | កុយ ធីរុន | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលក្រុងកំពង់ឆ្នាំង |
| ១៨- លោក | អ៊ិត វិន | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកសាមគ្គីមានជ័យ |
| ១៩- លោក | តឹក ដាវ៉ារុជ | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ២០- លោក | រ៉ុង រិទ្ធីវង្ស | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |

| | | |
|---|---|---|
| ២១- លោក | កែ ហ៊ីម | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុករលាប្អៀរ |
| ២២- លោក | ជិន សុវណ្ណារិទ្ធ | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ២៣- លោក | វ៉ាត វណ្ណៈ | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ២៤- លោក | ឃឹម សុជារិទ្ធិ | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ២៥- លោក | ទឹម បូរ៉េត | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ២៦- លោកស្រី | លន ស៊ីណា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ២៧- លោក | ហេង ណុល | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ២៨- លោក | ណម ណូ | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកជលគិរី |
| ២៩- លោកស្រី | តាត សុណា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង |
| ៣០- លោក | ប៉ែន សុវណ្ណារ៉ា | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកជំណាក់ចង្អើរ |
| ៣១- លោក | អុន ឌីម៉ង់ | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៣២- លោក | ផាត់ បារាំង | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៣៣- លោក | ហែម សិទ្យា | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកកែវសីមា |
| ៣៤- លោកស្រី | លីន បូវណ្ណារី | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៣៥- លោក | ចាន់ សុភ័ក្ត្រ | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលក្រុងសែនមនោរម្យ |
| ៣៦- លោក | កង សក្កដា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៣៧- លោក | សេង អមរា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៣៨- លោក | រស់ គីរ៉ា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |

| | | |
|---|---|---|
| ៣៩- លោក | ង៉ាំ សម្បត្តិ | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៤០- លោក | ជី រតនា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៤១- លោក | ជុន លី | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៤២- លោក | សុខ សុវត្ថិឌី | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៤៣- លោក | លី ម៉េងឡេង | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី |
| ៤៤- លោក | ប៉ូ សុខា | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកអង្គស្នួល |
| ៤៥- លោក | ហែម ហង្ស | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកអង្គស្នួល |
| ៤៦- លោក | រឿន ជាតិ | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកអង្គស្នួល |
| ៤៧- លោក | ស៊ឹម វុទ្ធី | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកអង្គស្នួល |
| ៤៨- លោកស្រី | ម៉ាញ សុកញ្ញា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល |
| ៤៩- លោកស្រី | ឈឺន ស្រីលៃ | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកមុខកំពូល |
| ៥០- លោក | នី ដារ៉ាវិទ្ធ | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល |
| ៥១- លោក | គឹម សត្យា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល |
| ៥២- លោកស្រី | សេង រតនា | មន្ត្រីរាជការនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល |
| ៥៣- លោកស្រី | សៅ សារ៉ាត់ | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកស្អាង |
| ៥៤- លោក | ម៉ែន សាមិទ្ធិ | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកស្អាង |
| ៥៥- លោក | ឡាយ គឹមតិច | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកស្អាង |
| ៥៦- លោក | អ៊ីត ឡាំសុផាត | មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកស្អាង |

៥៧- លោក ផុន ផាត មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកស្អាង

៥៨- លោក មាស ពន្លឺ មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកស្អាង

៥៩- លោក ច័ន្ទ ម៉ក់មុន្នី មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកស្អាង

៦០- លោក រ័ត្ន បូរ៉ាមី មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកកៀនស្វាយ

៦១- លោក នឹម សុភាព មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកកៀនស្វាយ

៦២- លោក ហ៊ោង ចន្ថា មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកកៀនស្វាយ

៦៣- លោក ឃឿន សុន មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកកៀនស្វាយ

៦៤- លោក មាឃ រ៉ានី មន្ត្រីរាជការនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល រដ្ឋបាលស្រុកកៀនស្វាយ

